ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យកសិកម្ម ២០០៩-២០១៣

រៀបចំដោយៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខែធ្នូ ឆ្នាំ២០១១

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៩ / ៧២៦ ១២៨ ទូរសារលេខៈ (៨៥៥) ២៣ ២១៧ ៣២០ គេហទំព័រៈ http://www.maff.gov.kh

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាដើម្បីជំរុញការអនុវត្ត «***យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២***» និងបានដឹកនាំប្រទេសជាតិឱ្យឆ្លងផុតពីដំណាក់កាលលំបាក ដែលបណ្ដាលមកពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអន្តរជាតិនាពេលកន្លងមក។ ក្នុងបរិបទនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យកសិកម្ម ជាវិស័យអាទិភាពនៅគ្រប់កាលៈទេសៈ ដោយបានកំណត់យ៉ាងច្បាស់ថា ការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម ការកែទម្រង់ដីធ្លីនិងបោសសំអាតមីន ការកែទម្រង់វិស័យជលផល និងការកែទម្រង់វិស័យព្រៃឈើ គឺជាមុខព្រួញស្នូលដ៏សំខាន់ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។ ជាមួយនេះយើងក៏ទទួលស្គាល់ដែរថា ប្រព័ន្ធកសិកម្មនៅកម្ពុជាច្រើនជាកសិកម្មផ្គត់ផ្គង់ក្នុងក្រុមគ្រួសារខ្លួនឯង និងពឹងផ្អែកទៅលើទឹកភ្លៀង ដោយតែងតែទទួលនូវផលប៉ះពាល់ពីបាតុភូតអវិជ្ជមាន នៃបម្រែបម្រួលអាកាសធាតុស្ទើរតែរាល់ឆ្នាំ ជាហេតុធ្វើឲ្យផលិតកម្មកសិកម្មមានការប្រែប្រួលផងដែរ។

ក្នុងន័យនេះ ដើម្បីសម្រេចបាននូវចក្ខុវិស័យនៃការអភិវឌ្ឍវិស័យកសិកម្ម រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យុទ្ធសាស្ត្រសំខាន់ចំនួន៣គឺ៖ ***ការបង្កើនផលិតភាព ការធ្វើពិពិធកាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម*** ដោយជំរុញការអនុវត្តនូវវិធានការចាំបាច់មួយចំនួនរួមមាន៖ ការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធដែលបម្រើដល់ផលិតកម្មកសិកម្ម ដូចជា ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ ថាមពលអគ្គិសនី បច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មាន ការផ្ដល់សេវាបច្ចេកទេសកសិកម្ម ការគ្រប់គ្រងដីកសិកម្ម ការផ្ដល់ឥណទានជនបទដល់កសិករ ការស្វែងរកទីផ្សារលក់ផលិតផលកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ការកសាងនិងពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មជាដើម។

យ៉ាងណាមិញ ដើម្បីអនុវត្តនិងសម្រេចបាននូវទិសដៅគោលនយោបាយ ដែលរាជរដ្ឋាភិបាលបានកំណត់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកសាងនិងអនុវត្តនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៦-២០១០ និងជាបន្តបានកសាងនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣ ដែលត្រូវបានចាត់ទុកជាឯកសារផែនការយុទ្ធសាស្ត្រដ៏សំខាន់មួយ ក្នុងការកំណត់និងតម្រង់ទិសដៅសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មរយៈពេលមធ្យម។ ឯកសារនេះត្រូវបានកំណត់ និងពិនិត្យមើលនូវផ្នែកអាទិភាពសំខាន់ៗនៃកិច្ចអភិវឌ្ឍវិស័យកសិកម្ម ដែលនឹងបង្ហាញច្បាស់លាស់នូវទិសដៅ គោលបំណង លទ្ធផលសម្រេចបានក្នុងឆ្នាំ លទ្ធផលចុងក្រោយ សូចនាករសំខាន់ៗ និងសកម្មភាពនានាដែលគ្រោងអនុវត្តក្នុងរយៈពេល៥ឆ្នាំ២០០៩-២០១៣។

ជាការពិត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣នេះ គឺត្រូវបានរៀបចំឡើងស្របតាមទិសដៅ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ដែលនឹងអាចចូលរួមចំណែកធ្វើឱ្យសម្រេចបាន នូវទិសដៅគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច ហើយស្របនឹងក្របខ័ណ្ឌនៃការអភិវឌ្ឍជាតិក្នុងអាណត្តិទីបួន របស់រាជរដ្ឋាភិបាលកម្ពុជា។

បន្ថែមលើនេះទៀត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣ ដែលបានរៀបចំមកនេះ ក៏មានលក្ខណៈសង្គតិភាពផងដែរទៅនឹងឯកសារគោលនយោបាយស្តីពី «***ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ***» ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ ដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងឯកសារពាក់ព័ន្ធផ្សេងទៀត ពិសេស «***យុទ្ធសាស្ត្រកសិកម្មនិងទឹក***» ។

ម្យ៉ាងទៀតដោយសារកម្ពុជាមានសក្តានុពលខ្លាំងក្នុងការផលិតស្រូវ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ចក្ខុវិស័យវែងឆ្ងាយ ដូចមានចែងច្បាស់ក្នុងឯកសារគោលនយោបាយស្តីពី «***ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ***» គឺសំដៅប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសនាំចេញអង្ករមួយដ៏សំខាន់ក្នុងតំបន់នាពេលខាងមុខ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកឆ្នាំ២០១៥ ជាឆ្នាំគោលដៅ ដើម្បីសម្រេចធ្វើយ៉ាងណាឱ្យអតិរេកស្រូវមានជាង៤លានតោន ហើយដែលអាចកែច្នៃជាអង្ករនាំចេញជាផ្លូវការយ៉ាងតិចជាង១លានតោន និងធ្វើយ៉ាងណាឱ្យអង្ករកម្ពុជាត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ។

ដើម្បីសម្រេចបាននូវទិសដៅគោលនយោបាយទាំងអស់ខាងលើ កិច្ចការជាច្រើននឹងត្រូវអនុវត្ត និងត្រូវសម្រេចឱ្យបាននាពេលខាងមុខ។ គ្រប់អង្គភាពជំនាញពាក់ព័ន្ធក្នុងអនុវិស័យនីមួយៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវតែខិតខំអនុវត្តឱ្យបានសកម្មនិងខ្លាំងក្លានូវបណ្តាសកម្មភាពទាំងឡាយ ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣នេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្តេជ្ញាយ៉ាងមុតមាំក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នៅក្នុងមធ្យោបាយដ៏ប្រសើរបំផុតមួយ ដើម្បីប្រែក្លាយផែនការសកម្មភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ឱ្យទៅជាការអនុវត្តជាក់ស្តែងតាមរយៈការខិតខំបង្កើនធនធានក្នុងស្រុក និងកៀងគរធនធានពីបណ្តាដៃគូអភិវឌ្ឍន៍នានា ក៏ដូចជាការធ្វើសមាហរណ-កម្មឲ្យតួអង្គពាក់ព័ន្ធសំខាន់ៗទាំងអស់ ចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រនេះ ឱ្យសម្រេចបាននូវសមិទ្ធផលប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់ ។

ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័នអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ចូលរួមនិងសហការអនុវត្តសកម្មភាពការងារ ពិសេសសហគមន៍អន្តរជាតិ បន្តផ្តល់ជំនួយទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ ចូលរួមចំណែកក្នុងដំណើរការ

អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣នេះ ឱ្យទទួលបានលទ្ធផលផ្លែផ្កាជាវិជ្ជមាន និងប្រកបដោយភាពស័ក្តិសិទ្ធិនាពេលខាងមុខ ពិសេសនិរន្តរភាពនៃកសិកម្មខ្នាតតូចដែលមានប្រជាជនដ៏ច្រើនលើសលុបរស់នៅតំបន់ជនបទ និងការតម្រង់ទិសឆ្ពោះទៅរកពាណិជ្ជូបនីយកម្មកសិកម្ម។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រ ដល់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ដែលបានចូលរួមក្នុងដំណើរកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣នេះ និងប្តេជ្ញាចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអនុវត្តដើម្បីសម្រេចបានគោលដៅកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ប្រទេសកម្ពុជានាពេលអនាគត។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០១..

**រដ្ឋមន្ត្រី**

# មាតិកា

**អារម្ភកថា** **ទំព័រ**

## ផ្នែកទី ១
## សមិទ្ធផល និងបញ្ហាប្រឈមចម្បងៗ ក្នុងការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០០៦-២០១០)


I- **សេចក្តីផ្តើម** ........ ៦

II- **សមិទ្ធផលសម្រេចបាននិងបញ្ហាប្រឈមចម្បងៗក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យកសិកម្ម (២០០៦-២០១០)** ៧

ក- ស្ថានភាពទូទៅ ........ ៧

ខ- សមិទ្ធផល ៩

និងការរីកចម្រើននៃវិស័យកសិកម្មតាមផ្នែក........

១- ការធ្វើឱ្យប្រសើរឡើងផលិតភាព និងពិពិធកម្មកសិកម្ម ........ ៩

២- ផលិតកម្មដំណាំកៅស៊ូ ........ ១២

៣- ផលិតកម្មសត្វនិងបសុព្យាបាល ........ ១៣

៤- អាជីវកម្មនេសាទ និងកំណែទម្រង់ជលផល ........ ១៥

៥- រុក្ខកម្ម និងកំណែទម្រង់ព្រៃឈើ........ ១៧

៦- សេវាកម្មគាំទ្រ ........ ២០

គ- ការវាយតម្លៃ និងសន្និដ្ឋាន ........ ២១

១- ភាពខ្លាំង បញ្ហាប្រឈម និងឧបសគ្គ ........ ២១

២- ការវាយតម្លៃ និងសន្និដ្ឋាន ........ ២៤


## ផ្នែកទី ២
## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣


III- **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣** ........ ២៦

ក- សារតារ........ ២៦

ខ- ចក្ខុវិស័យរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........ ២៧

គ- បេសកកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........ ២៧

ឃ- ទិសដៅគោលនយោបាយរបស់ក្រសួងកសិកម្ម ........ ២៧

ង- អភិក្រមដើម្បីសម្រេចបានទិសដៅគោលនយោបាយ ........ ២៩

ច- កម្មវិធីលម្អិតតាមវិស័យ និងអនុវិស័យ ........ ៣៣

ឆ- សកម្មភាពអាទិភាពរបស់ក្រសួង (២០០៩-២០១៣) ........ ៣៨

ជ- ផែនការថវិកាសំរាប់ដំណើរការអនុវត្ត ...................................................... ៧០
ឈ- ការពិនិត្យតាមដាន និងវាយតម្លៃ ........................................................... ៧១
ញ- សេចក្តីសន្និដ្ឋាន ............................................................................................ ៧១

IV- **ឧបសម្ព័ន្ធ** .........................................................................................................
ឧបសម្ព័ន្ធៈ ១ តារាងសូចនាករសំខាន់ៗ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០០៩-២០១៣)
ឧបសម្ព័ន្ធៈ ២ តារាងម៉ាទ្រិចនៃសកម្មភាពសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០០៩-២០១៣)

# ផ្នែកទី ១
# សមិទ្ធផល និងបញ្ហាប្រឈមចម្បងៗ
# ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០០៦-២០១០)

## I- សេចក្តីផ្តើម

ប្រទេសកម្ពុជាគឺជាប្រទេសដែលមានខឿនសេដ្ឋកិច្ចជាតិពឹងផ្អែកមួយភាគធំលើវិស័យកសិកម្ម និងមានប្រជាពលរដ្ឋប្រមាណជាង៨០ភាគរយរស់នៅជនបទ ដែលក្នុងនោះភាគច្រើនលើសលុបរស់នៅទីជនបទ និងប្រកបរបរកសិកម្មសម្រាប់ចិញ្ចឹមជីវិត។ ក្នុងលក្ខខណ្ឌនៃដំណើរការវិវឌ្ឍន៍សេដ្ឋកិច្ចសង្គមបែបនេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងចាត់ទុកវិស័យកសិកម្ម គឺជាវិស័យដែលមានអាទិភាពខ្ពស់នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍប្រទេស។

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ដាក់ ចេញនូវការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវយុទ្ធសាស្ត្រជាគន្លឹះ ដើម្បីរៀបចំកសាងផែនការអភិវឌ្ឍន៍ ដោយផ្តោតលើការជំរុញការអភិវឌ្ឍកសិកម្មនិងជនបទ រួមមានៈ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមលើកទី១និងទី២ (១៩៩៦-២០០០ និង២០០១-២០០៥) យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ២០០៣-២០០៥ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១និងទី២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣។

រហូតមកទល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចនូវគោលដៅកាត់បន្ថយភាពក្រីក្រគួរជាទីពេញចិត្ត តាមរយៈការជំរុញកំណើនសេដ្ឋកិច្ច ពិសេសការជំរុញការអភិវឌ្ឍវិស័យកសិកម្មដោយផ្អែកលើការបង្កើនផលិតភាពកសិកម្ម ធានាបាននូវសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋទូទៅ បង្កើតការងារ បង្កើនប្រាក់ចំណូលដល់គ្រួសារ និងការនាំចេញផលិតផលកសិកម្ម ទៅកាន់ទីផ្សារតំបន់ និងអន្តរជាតិ។

ការរីកចម្រើននៃវិស័យកសិកម្មគឺជាកត្តាគន្លឹះសម្រាប់ការកាត់បន្ថយភាពក្រីក្រ ដែលវិស័យនេះបានចូលរួមចំណែកយ៉ាងច្រើនក្នុងកំណើនផលិតផលសរុបក្នុងស្រុក (GDP) និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។ បច្ចុប្បន្ននេះ វិស័យកសិកម្មបានទ្រទ្រង់ដល់ការអភិវឌ្ឍជាតិ និងបានធ្វើឱ្យមានស្ថេរភាពដោយសារការរីកចម្រើននូវប្រព័ន្ធធារាសាស្ត្រ ការចាប់យកនូវបច្ចេកវិជ្ជាកសិកម្ម ការខិតខំប្រឹងប្រែងនានា ពិសេសសកម្មភាពស្រាវជ្រាវកសិកម្មដើម្បីបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ។ ទន្ទឹមនោះ រាជរដ្ឋាភិបាលកម្ពុជាក៏បានខិតខំធ្វើកិច្ចការយ៉ាងច្រើន សំដៅពង្រឹងកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ដើម្បីកៀងគរថវិកានិងធនធានពីខាងក្រៅ សម្រាប់ជំរុញការលើកកម្ពស់បង្កើនផលិតភាពកសិកម្ម ធានាឱ្យបាននូវបរិមាណស្បៀងសម្រាប់សន្តិសុខស្បៀងក្នុងប្រទេស និងសំដៅធានាការផ្គត់ផ្គង់ផលិតផលកសិកម្មលើទីផ្សារក្នុងនិងក្រៅប្រទេសផងដែរ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣នេះគឺជាឯកសារគោលនយោបាយយុទ្ធសាស្ត្រមួយដ៏សំខាន់សម្រាប់រយៈពេលមធ្យមនិងជាផែនទីបង្ហាញផ្លូវដែលបានបង្ហាញអំពីទិសដៅអភិវឌ្ឍន៍វិស័យកសិកម្ម ជាមួយនឹងគោលបំណង លទ្ធផលរំពឹងទុក សូចនាករ និងចង្កោមសកម្មភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់អនុវត្តក្នុងរយៈពេល៥ឆ្នាំពីឆ្នាំ២០០៩ដល់ឆ្នាំ២០១៣ និងបានឆ្លុះបញ្ចាំងពីឆន្ទៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ សំដៅរួមចំណែកដល់ការរីកចម្រើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ តាមរយៈការធ្វើឱ្យប្រសើរឡើង និងការបង្កើនផលិតភាពនិងពិពិធកម្មកសិកម្ម ។

## II- សមិទ្ធផលសម្រេចបាន និងបញ្ហាប្រឈមចម្បងៗ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០០៦-២០១០)

### ក. ស្ថានភាពទូទៅ

ជាការពិតណាស់ថា វិស័យកសិកម្មមានសារៈសំខាន់បំផុតក្នុងការចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិព្រោះវិស័យនេះអាចផ្តល់នូវប្រភពស្បៀងអាហារសម្រាប់ជីវភាពប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ជាប្រភពផ្គត់ផ្គង់វត្ថុធាតុដើមចម្បងសម្រាប់ការអភិវឌ្ឍផ្នែកកសិឧស្សាហកម្ម និងជាប្រភពចំណូលជាតិសំខាន់ ដែលទទួលបានពីការធ្វើផលិតកម្ម និងការនាំចេញផលិតផលកសិកម្មចូលទៅក្នុងទីផ្សារអន្តរជាតិ។ នេះគឺជាចំណុចគន្លឹះចម្បងបំផុត ដែលអាចបញ្ជាក់បានថាវិស័យកសិកម្មមានតួនាទីក្នុងការជំរុញការរីកលូតលាស់ផ្នែកសេដ្ឋកិច្ច។

ការលើកស្ទួយវិស័យកសិកម្ម គឺជាមុំមួយដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ចជាតិ។ ការលើកកម្ពស់ផលិតភាពនិងពិពិធកម្មកសិកម្ម ការកែទម្រង់ដីធ្លីនិងបោសសំអាតមីន ការកែទម្រង់វិស័យជលផល និងការកែទម្រង់វិស័យព្រៃឈើ គឺជាមុខព្រួញស្នូលដើម្បីចូលរួមជំរុញសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាមនិងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជំនះដោះស្រាយបាននូវការលំបាកផ្សេងៗ ដែលរួមមាន កត្តាអវិជ្ជមាននៃធម្មជាតិ ពិសេសកង្វះខាតទឹកដោយសារឥទ្ធិពលកូនរដូវប្រាំង និងគ្រោះទឹកជំនន់ដោយទឹកភ្លៀងដែលតែងតែកើតមានជារៀងរាល់ឆ្នាំ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញផលិតកម្មកសិកម្មលើគ្រប់មុខព្រួញជាពិសេស ការបង្កបង្កើនផលដំណាំជាយុទ្ធសាស្ត្រជាអាទិ៍ ដំណាំស្រូវ កៅស៊ូ ដំណាំរួមផ្សំ និងដំណាំកសិឧស្សាហកម្ម ការចិញ្ចឹមសត្វ និងនេសាទ មិនត្រឹមតែអាចឆ្លើយតបបានទៅនឹងតម្រូវការស្បៀងក្នុងស្រុកប៉ុណ្ណោះទេ ថែមទាំងអាចនៅសល់ស្បៀងសម្រាប់នាំចេញទៀតផង។ នៅពេលដែលពិភព

លោកកំពុងជួបប្រទះវិបត្តិស្បៀងនិងការធ្លាក់ចុះនៃសេដ្ឋកិច្ច កម្ពុជាបានខិតខំបង្កើននូវផលិតកម្មដំណាំស្បៀង សំដៅរួមចំណែកដោះស្រាយបញ្ហានេះ ដោយសារយើងមានសក្តានុពលអំណោយផលយ៉ាងធំធេងរបស់វិស័យកសិកម្មនេះ ជាពិសេសផលិតកម្មដំណាំស្រូវអាចពង្រីកសក្តានុពលផលិតកម្មនិងជំរុញការនាំចេញ លើកស្ទួយជីវភាពប្រជាពលរដ្ឋតាមជនបទ និងបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

រយៈពេល៥ឆ្នាំកន្លងទៅនេះ ប្រជាពលរដ្ឋគ្រប់តំបន់និងទីប្រជុំជន បានខិតខំប្រកបមុខរបរយ៉ាងមមាញឹក ប្រកបដោយលក្ខណៈប្រកួតប្រជែង ក្នុងបរិបទនៃពាណិជ្ជូបនីយកម្មកសិកម្ម ដែលធ្វើឱ្យវិស័យកសិកម្មកាន់តែមានភាពសកម្ម និងមានសារៈសំខាន់ក្នុងជីវភាពសង្គម ក៏ដូចជាការគាំទ្រសេដ្ឋកិច្ចជាតិ ទន្ទឹមនឹងរាជរដ្ឋាភិបាលបាននិងកំពុងបង្កើនផ្តោតការយកចិត្តទុកដាក់ និងវិនិយោគកាន់តែខ្លាំងក្លាលើវិស័យកសិកម្មនេះ។

ការរីកចំរើននៃវិស័យកសិកម្ម គឺជាកត្តាគន្លឹះសម្រាប់ការកាត់បន្ថយភាពក្រីក្រ ដែលរួមបានចំណែកយ៉ាងច្រើនក្នុងកំណើនផលិតផលសរុបក្នុងស្រុក (GDP) និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។ ដំណើរការអភិវឌ្ឍគ្រប់វិស័យ ការគ្រប់គ្រងបែងចែក និងការប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ រួមនឹងការខិតខំដោះស្រាយនូវរាល់បញ្ហាដែលមានចំពោះមុខ និងការទប់ស្កាត់សកម្មភាពរំលោភបំពានយកដីដោយខុសច្បាប់ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលខិតខំពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍នៃប្រទេសអ្នកផ្តល់ជំនួយ ក្នុងក្របខ័ណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រកសិកម្មនិងទឹក សំដៅជំរុញលើកកម្ពស់បង្កើនផលិតភាពកសិកម្ម ធានាឱ្យបាននូវបរិមាណនិងគុណភាព ធានាសន្តិសុខស្បៀង និងទីផ្សារក្នុងនិងក្រៅប្រទេស។ មិនតែប៉ុណ្ណោះ វិស័យកសិកម្មបាននិងកំពុងស្រូបទាញបាននូវទុនវិនិយោគ ទាំងពីអ្នកវិនិយោគក្នុងនិងក្រៅប្រទេសកាន់តែច្រើនឡើងជាលំដាប់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ការចូលរួមចំណែកជាភាគរយនៃផ្នែកកសិកម្មក្នុងផលិតផលសរុបក្នុងស្រុក (GDP) ជារួមមាននិន្នាការថយចុះពី ៣៤,៤% នាឆ្នាំ២០០១ មកនៅត្រឹម ២៨,១% នៅឆ្នាំ២០០៦ និងបន្តការថយចុះប្រមាណ ២៦,៧% នៅឆ្នាំ២០០៧ និងបានកើនឡើងវិញចំនួន ២៨% នៅឆ្នាំ២០០៩។ សភាពការណ៍នេះ បង្ហាញអំពីភាពប្រកួតប្រជែងរីកចម្រើនរួម នៃវិស័យសេដ្ឋកិច្ចទាំងបីរបស់កម្ពុជា ហើយក្នុងនោះ វិស័យកសិកម្មនៅតែបន្តរីកចម្រើនទាំងបរិមាណនិងគុណភាព។ នាឆ្នាំ២០១០ កន្លងទៅនេះ ការចូលរួមចំណែករបស់កសិកម្មក្នុង GDP បានបន្តកើនឡើងដល់ ២៩% ។ តម្លៃបន្ថែមសរុបនៃផលិតផលកសិកម្ម (Gross Value Added-GVA) បានកើនឡើងពី ៥.០៧៨ ពាន់លានរៀល នៅឆ្នាំ១៩៩៩ រហូតដល់ ៧.៩៩៤ ពាន់លានរៀល នៅឆ្នាំ២០០៩ (កើនប្រហែលជាង ៤០%) និងបានបន្តកើនថែមទៀតដល់ ៨.៣១៣ ពាន់លានរៀលឆ្នាំ២០១០នេះ (តម្លៃគិតតាមថ្លៃស្ថេរឆ្នាំ ២០០០)។

ជារួមកំណើន (%) នៃវិស័យកសិកម្ម មានការកើនឡើងជាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៤,៥-៥,៧% (២០០៦-២០១០) កំណើនមានការប្រែប្រួលយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ហើយការប្រែ

ប្រែប្រួលនេះ មានពាក់ព័ន្ធទៅនឹងស្ថានភាពអាកាសធាតុនៃឆ្នាំនីមួយៗ។ ដូចនេះ វិស័យកសិកម្មពឹងផ្អែកច្រើននៅឡើយលើកត្តាធម្មជាតិ ដែលជះឥទ្ធិពលដល់ផលិតកម្មកសិកម្ម។ នៅឆ្នាំ២០០៦ វិស័យកសិកម្មបានកើនប្រមាណ ៥,៥% និងឆ្នាំ២០០៩ មានកំណើនប្រហែល ៥,៤%។ ដោយឡែកឆ្នាំ២០១០នេះ កំណើនមានប្រហែលជាង ៤% ។ គួរកត់សំគាល់ដែរថានៅឆ្នាំ២០០០ ២០០២ និង ២០០៤ កំណើនផ្នែកកសិកម្មជាចំនួនអវិជ្ជមាន នេះគឺអាស្រ័យដោយការជួបប្រទះធ្ងន់ធ្ងរពីកត្តាធម្មជាតិ ដែលរួមមានទឹកជំនន់ រាំងស្ងួត និងការបំផ្លាញដំណាំដោយសត្វចង្រៃ។

គួរកត់សម្គាល់ថា ផ្នែកដំណាំមានការកើនឡើងយ៉ាងខ្លាំង ដោយសមាសភាគរបស់ផ្នែកនេះមានចំនួន ៥០,៨% នៅឆ្នាំ២០០៦ និងមាននិន្នាការកើនឡើង ៥២,២% នៅឆ្នាំ២០០៧ និង កើនឡើងរហូតដល់ ៥៣,៨% នៅឆ្នាំ២០១០។ សមាសភាគនៃផ្នែកផលិតកម្មដំណាំនេះ បានកើនប្រហែល ៣% បើប្រៀបធៀបនឹងឆ្នាំ២០០៦។ ចំពោះសមាសភាគផ្នែកជលផលមានការប្រែប្រួលពី ២៥,៩% នៅឆ្នាំ២០០៦ រហូតដល់ ២៧,៣% នាឆ្នាំ២០១០ ហើយផ្នែកនេះបានទទួលរងនូវកត្តាជះឥទ្ធិពលទឹកទន្លេនៅឆ្នាំ២០០៧ ដែលធ្វើឱ្យការចូលរួមថយត្រឹម២៤,៨% និងបានកើនឡើងវិញពី២៥% នៅឆ្នាំ ២០០៨ ដល់ ២៧,៣% នាឆ្នាំ២០១០នេះ។ ដោយឡែកសមាសភាគចូលរួមផ្នែកអាជីវកម្មព្រៃឈើមានការថយចុះជាបន្តបន្ទាប់បើធៀបនិងឆ្នាំ២០០៦ ពី ៧,៥% មកត្រឹមតែ ៦,១% នៅឆ្នាំ២០១០។ រីឯសមាសភាគផ្នែកបសុសត្វមានការប្រែប្រួលនិងថយចុះ បើធៀបរយៈពេលឆ្នាំ៥កន្លងទៅនេះ (១៥,៨% ឆ្នាំ២០០៦ ថយមកត្រឹម ១៥,៣% ឆ្នាំ២០០៩ និង ១២,៨% ឆ្នាំ២០១០)។

## ខ. សមិទ្ធផល និង ការរីកចម្រើននៃវិស័យកសិកម្មតាមផ្នែក

សមទ្ធិផលផ្នែកកសិកម្មសម្រេចបានក្នុងរយៈពេល៥ឆ្នាំ (២០០៦-២០១០) កន្លងទៅនេះ អាចវាយតម្លៃបានថា មានការរីកលូតលាស់គួរជាទីមោទនៈ ដែលការវិវឌ្ឍតាមបណ្តាអនុវិស័យនីមួយៗមានបង្ហាញលំអិតដូចខាងក្រោមៈ

## ១. ការធ្វើឱ្យប្រសើរឡើងផលិតភាព និងពិពិធកម្មកសិកម្ម

### ១.១ ផលិតកម្មដំណាំស្រូវ

ផលិតកម្មដំណាំស្រូវអនុវត្តបាននាឆ្នាំ២០០៦ មានចំនួនសរុប ២,៥៤ លានហិកតា និងបានកើនដល់ ២,៧៩ លានហិកតា នាឆ្នាំ២០១០ (កើនលើសឆ្នាំ២០០៦ ប្រមាណជា ១០%)។ ផ្ទៃដីអាចប្រមូលផលបានកើនពី ២,៥១ លានហិកតា ឆ្នាំ២០០៦ ដល់ ជាង ២,៧៨ លានហិកតា នាឆ្នាំ២០១០ និងទិន្នផលមធ្យមប្រចាំឆ្នាំ២០១០ ទទួលបានគិតទាំងប្រាំងនិងវស្សាចំនួន ២,៩៧ តោន/ហិកតា កើនលើសឆ្នាំ២០០៦ ប្រមាណ១៩% (ទិន្នផលស្រូវឆ្នាំ២០០៦ ទទួលបានត្រឹមតែ ២,៤៨ តោន/ហិកតា)។ ផ្ទៃដីដំណាំស្រូវតែងតែទទួលរងដោយគ្រោះធម្មជាតិនារយៈពេល៥ឆ្នាំកន្លងទៅនេះ ពិសេសគ្រោះជំនន់ទឹកភ្លៀង ការរាំងស្ងួត និងសត្វចង្រៃបំផ្លាញ។

តែទោះជាយ៉ាងណាក្តី ក្នុងឆ្នាំ២០១០កន្លងទៅនេះ កម្ពុជាអាចទទួលបានបរិមាណផលស្រូវជាង ៨,២៥ លានតោន កើនលើសឆ្នាំ២០០៦ ចំនួន៣២% (ឆ្នាំ២០០៦ សម្រេចបានតែត្រឹម

៦,២៦ លានតោន) និងអាចសល់ស្បៀងជាអង្ករសរុបចំនួនជាង ២,៥ លានតោន ឬគិតជាស្រូវនៅសល់ប្រមាណជា ៣,៩ លានតោន (កើនលើសឆ្នាំ២០០៦ ប្រមាណជាង ៧៥,៥% ដែលស្រូវនៅសល់នាឆ្នាំ២០០៦ មានតែប្រមាណជា ២,២៤ លានតោន) ។

គួរកត់សម្គាល់ថា រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកឆ្នាំ២០១៥ជាឆ្នាំគោល ដើម្បីជំរុញការផលិតស្រូវលើសឲ្យបានច្រើនជាង៤លានតោន និងគិតជាបរិមាណអង្ករសម្រាប់នាំចេញជាផ្លូវការត្រូវសម្រេចឱ្យបានយ៉ាងតិច១លានតោន (ចំណុចទី៧នៃឯកសារគោលនយោបាយ) និងតាមការកំណត់សូចនាករអតិរេកស្រូវសម្រាប់ឆ្នាំ២០១០ ត្រូវសម្រេចឲ្យបាន ៣,៣២ លានតោនស្រូវ ប៉ុន្តែអតិរេកស្រូវសម្រេចបានដល់ ៣,៩ លានតោន នាឆ្នាំ២០១០ គឺលើសផែនការកំណត់។ នេះជាជោគជ័យមួយគួរជាទីមោទនៈបំផុតសម្រាប់កម្ពុជា។

**តារាងប្រៀបធៀបកំណើនដំណាំស្រូវប្រចាំឆ្នាំ ២០០៦/២០១០**

| **បរិយាយ** | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ប្រៀបធៀប កំណើន ២០០៦/២០១០ |
|---|---|---|---|---|---|---|
| *ផ្ទៃដីដាំដុះ* (ហត) | 2,541,433 | 2,585,905 | 2,615,741 | 2,719,080 | 2,795,892 | 10.01 |
| *ផ្ទៃដីប្រមូលផល* (ហត) | 2,516,415 | 2,566,952 | 2,613,363 | 2,674,603 | 2,777,323 | 10.37 |
| *ទិន្នផល* (ត/ហត) | 2.489 | 2.621 | 2.746 | 2.836 | 2.97 | 19.33 |
| *បរិមាណផល* (ត) | 6,264,123 | 6,727,127 | 7,175,473 | 7,585,870 | 8,249,452 | 31.69 |
| *ស្បៀងសល់* (អង្ករ) | 1,433,880 | 1,649,640 | 2,025,033 | 2,244,598 | *2,516,752* | 75.52 |
| *ស្បៀងសល់* (ស្រូវ) | 2,240,438 | 2,577,562 | 3,164,114 | 3,507,185 | *3,932,425* | 75.52 |

ផ្អែកលើសមិទ្ធផលខាងលើនេះ យើងអាចវាយតម្លៃបានថា ជារួមពីមួយឆ្នាំទៅមួយឆ្នាំ ទាំងផ្ទៃដីអនុវត្តផ្ទៃដីប្រមូលផលនិងបរិមាណផល មានការវិវឌ្ឍឈានឡើងជាលំដាប់ ហើយសមិទ្ធផលទទួលបានទាំងនេះ គឺអាស្រ័យដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា អង្គការជាតិនិងអន្តរជាតិជាដៃគូ អាជ្ញាធរមូលដ្ឋាន និងការចូលរួមយ៉ាងសកម្មពីកសិករ ជាពិសេស ការដាក់ចេញឱ្យអនុវត្តនូវគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ របស់រាជរដ្ឋាភិបាលកម្ពុជានាពេលថ្មីៗកន្លងមក ដែលជាយន្តការមួយដ៏ស័ក្តិសិទ្ធធ្វើឱ្យផលិតកម្មដំណាំស្រូវមានដំណើរការរីកលូតលាស់បន្ថែមទៀត តាមរយៈការបង្កើនផលិតភាពពិសេស ការបង្កើនផលិតផលស្រូវដូចជា: ការដូរពូជពីពូជស្រូវធ្ងន់មកពូជស្រូវកណ្តាលនិងស្រាលការផ្ទេរបច្ចេកទេសសមស្របដល់កសិករ តាមរយៈការចុះស្រែជាមួយកសិករ ជាពិសេសតាមរយៈភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ការពង្រីកធ្វើស្រែបង្ហាញតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាម

គោលការណ៍ធម្មជាតិ ការបើកសាលារៀនស្រែកសិករ ការប្រើបច្ចេកទេសដំណាំគ្របដី ដើម្បីបង្កើនជីជាតិដីនិងទិន្នផល សហគមន៍កសិកម្មដែលមានជាង ២០០ សហគមន៍ត្រូវបានបង្កើតនិងពង្រឹងការបង្កើនការស្រាវជ្រាវនិងអភិវឌ្ឍពូជស្រូវដែលស្របនឹងលក្ខណៈដី អាកាសធាតុ ការកំណត់ប្រភេទពូជសំខាន់ៗ ស្របតាមតម្រូវការទីផ្សារចង់បាន ការកសាងចំណេះដឹងដល់កសិករ ក្នុងការប្រើប្រាស់ឧបករណ៍មធ្យោបាយផលិតកម្ម និងធាតុចូលកសិកម្មផ្សេងៗទៀត ជាពិសេសការប្រើប្រាស់ពូជស្រូវសំខាន់ៗទាំង ១០ ពូជ ដែលបានទទួលនូវការវាយតម្លៃជាវិជ្ជមានពីសំណាក់សម្តេចតេជោនាយករដ្ឋមន្ត្រីរួចហើយ ព្រមទាំងការទទួលយកពីវិស័យឯកជនផងដែរ។ល។ ដែលទាំងអស់នេះជាបទពិសោធន៍ជាវិជ្ជមាននឹងជំរុញឱ្យផលិតកម្មស្រូវរបស់យើង មានការរីកលូតលាស់តាមការរំពឹងទុកជាក់ជាមិនខាន ជាពិសេស ការបំផុសចលនាកសិករឲ្យចេះធ្វើកសិកម្មចម្រុះ និងប្រែក្លាយទឹកដី ដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ឲ្យទៅជាតំបន់ដែលមានពណ៌បៃតងជាអចិន្ត្រៃយ៍។

### ១.២ ផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម

ដំណាំរួមផ្សំនិងឧស្សាហកម្ម ដូចជា ពោត ដំឡូងមី សណ្តែកបាយ សណ្តែកសៀង ជារួមផ្ទៃដីដាំដុះមានការប្រែប្រួលចុះឡើងទៅតាមប្រភេទដំណាំនីមួយៗ អាស្រ័យទៅតាមឥទ្ធិពលនៃកត្តាថ្លៃនិងទីផ្សារ។ ផ្ទៃដីដាំដុះដំណាំរួមផ្សំនិងឧស្សាហកម្មទូទាំងប្រទេសសម្រាប់ឆ្នាំ២០១០ សម្រេចបានប្រហែលជាង ៧៥២ ពាន់ហិកតា កើនលើសឆ្នាំ២០០៦ ប្រមាណ ៤៨% និងបរិមាណផលសរុបប្រចាំឆ្នាំកើនឡើងពី ៣,២ លានតោន ឆ្នាំ២០០៦ ដល់ជាង ៦,១ លានតោន ឆ្នាំ២០១០ កើនប្រមាណ ៨៩%។

**តារាងបង្ហាញពីការរីកចម្រើនរបស់ផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម ២០០៦-២០១០**

| ដំណាំរួមផ្សំនិងឧស្សាហកម្ម | 2006 | 2007 | 2008 | 2009 | 2010 | (%) 2006/2010 |
|---|---|---|---|---|---|---|
| ពោត | 108,836 | 142,391 | 163,106 | 221,287 | 213,622 | 96 |
| ដំឡូងឈើ | 97,918 | 108,122 | 179,945 | 160,326 | 206,226 | 111 |
| ដំឡូងជ្វា | 10,402 | 8,620 | 8,246 | 9,283 | 11,452 | 10 |
| បន្លែ | 43,327 | 42,360 | 47,781 | 50,278 | 52,732 | 22 |
| សណ្តែកបាយ | 85,140 | 65,261 | 45,605 | 49,599 | 69,206 | -19 |
| សណ្តែកដី | 12,990 | 21,466 | 18,183 | 16,474 | 20,041 | 54 |
| សណ្តែកសៀង | 75,053 | 76,981 | 74,413 | 96,388 | 103,198 | 38 |
| ល្ង | 56,263 | 47,810 | 35,874 | 43,206 | 48,299 | -14 |
| អំពៅ | 8,358 | 10,458 | 13,297 | 13,533 | 17,207 | 106 |
| ក្រចៅ | 449 | 461 | 397 | 347 | 594 | 32 |
| ថ្នាំជក់ | 8,768 | 7,277 | 9,447 | 9,269 | 10,062 | 15 |
| **សរុបរួម (ហ.ត)** | **507,504** | **531,207** | **596,294** | **669,990** | **752,639** | **48** |
| **សរុបបរិមាណផល (តោន)** | **3,249,320** | **3,538,526** | **5,190,070** | **5,425,310** | **6,138,532** | **89** |

ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ (២០០៦-២០១០) ដំណាំឈើហូបផ្លែ ដូចជា ចេក ដូង មៀន ស្វាយ ទឹកដោះ ល្មុត ធូរេន ខ្នុរ ទៀប ក្រូច សាវម៉ាវ ត្របែក ម្នាស់ និងដំណាំអចិន្ត្រៃយ៍ (ស្វាយចន្ទី ដូងប្រេង កាហ្វេ ម្រេច) មាននិន្នាការរីកលូតលាស់គួរឱ្យកត់សម្គាល់។ ជាក់ស្តែង ផ្ទៃដីដាំដុះដំណាំឈើហូបផ្លែនិងដំណាំអចិន្ត្រៃយ៍ សម្រេចបានសរុបចំនួនជាង ១៩០ ពាន់ហិកតា ក្នុងឆ្នាំ២០១០ កើនលើសឆ្នាំ២០០៦ ប្រមាណ ៣២ % (ឆ្នាំ២០០៦ សម្រេចបានត្រឹមតែ ១៤៥ ពាន់ហិកតា)។

ដូចនេះ ផ្ទៃដីដាំដុះដំណាំស្រូវ ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម ដំណាំឈើហូបផ្លែ និងដំណាំអចិន្ត្រៃយ៍នៅទូទាំងប្រទេសសម្រេចបាន ៣,៧៣ លានហិកតា នៅឆ្នាំ២០១០ (ផ្ទៃដីដាំដុះដំណាំស្រូវចំនួន ២,៧៩ លានហិកតា ផ្ទៃដីដាំដុះដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មចំនួន ០,៧៥ លានហិកតា និងផ្ទៃដីដាំដុះដំណាំឈើហូបផ្លែនិងអចិន្ត្រៃយ៍ចំនួន ០,១៩ លានហិកតា)។

## ២. ផលិតកម្មដំណាំកៅស៊ូ

### ២.១ ការវិវឌ្ឍផលិតកម្មកៅស៊ូ

កៅស៊ូជាដំណាំកសិ-ឧស្សាហកម្មរយៈពេលវែង ដែលបានបំពេញតួនាទីយ៉ាងសំខាន់ ជួយទ្រទ្រង់ដល់សង្គមសេដ្ឋកិច្ចជាតិ ចូលរួមការពារបរិស្ថាន ដោយបង្កើតជាគម្របបៃតង រក្សាលំនឹងធម្មជាតិ និងការពារហូរច្រោះដី ។

នៅឆ្នាំ២០១០ ផ្ទៃដីដាំដុះកៅស៊ូនៅកម្ពុជាបានកើនដល់ចំនួន ១៨១.៤៣០ ហិកតា គឺកើនឡើង ៣៩,៦% បើប្រៀបធៀបទៅនឹងឆ្នាំ២០០៩ (ផ្ទៃដីដាំកៅស៊ូឆ្នាំ២០០៩ មានចំនួន ១២៩.៩២០ ហិកតា) ក្នុងនោះ ផ្ទៃដីចំការកៅស៊ូកសិឧស្សាហកម្មមានស្រាប់ចំនួន ៤៧.០៩២ ហិកតា ផ្ទៃដីវិនិយោគថ្មីស្ថិតក្រោមសម្បទានដីសេដ្ឋកិច្ចមានចំនួន ៥២.៥២៨ ហិកតា និងផ្ទៃដីកៅស៊ូគ្រួសារមានចំនួន ៨១.៨១៣ ហិកតា។

**ក្រាហ្វិក៖ ការវិវឌ្ឍនៅក្នុងការដាំដុះកៅស៊ូ ២០០៦-២០១០**



សន្ទុះនៃការដាំដុះកៅស៊ូនៅកម្ពុជាមានការកើនឡើងជាលំដាប់ អាស្រ័យដោយសារតម្លៃកៅស៊ូបានឡើងខ្ពស់ គួបផ្សំស្ថានភាពនយោបាយសន្តិសុខល្អប្រសើរ សក្តានុពលនៃដីសមស្រប និងគោលនយោបាយសេរីភាវូបនីយកម្ម លើការលក់ដូរផលិតផលកៅស៊ូគ្រួសារក្នុងស្រុក ជាពិសេសមានការចូលរួមពីផ្នែកឯកជន ដែលបានធ្វើវិនិយោគលើសម្បទានដីសេដ្ឋកិច្ច ដោយបានធ្វើឲ្យផ្ទៃដីដាំដុះកៅស៊ូកើនឡើងគួរជាទីមោទនៈ។

ផ្ទៃដីដាំដុះកៅស៊ូបានកើនពី ៧០ពាន់ហិកតា នាឆ្នាំ២០០៦ រហូតដល់១៨១ពាន់ហិកតានាឆ្នាំ ២០១០ គឺបានកើនឡើងប្រមាណ១៥៨% ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ ។ ការដាំដុះដំណាំកៅស៊ូគ្រួសារមានសន្ទុះកើនឡើងខ្លាំងគួរឱ្យកត់សម្គាល់ គឺបានកើនពី២៥ពាន់ហិកតាឆ្នាំ២០០៦ ដល់៨១ពាន់ហិកតាឆ្នាំ២០១០ (កើនប្រហែល២២៤% ក្នុងរយៈពេល៥ឆ្នាំ)។ ផ្ទៃដីដាំដុះកៅស៊ូដោយក្រុមហ៊ុនវិនិយោគឯកជនលើដីសម្បទានសេដ្ឋកិច្ចបានកើនពីជាង២ពាន់ហិកតា ឆ្នាំ២០០៧ រហូតដល់ជិត ៥៣ពាន់ហិកតា ឆ្នាំ២០១០ ដែលសន្ទុះនៃការកើនមានកម្រិតខ្ពស់គួរឱ្យចាប់អារម្មណ៍ ក្នុងរយៈពេល៥ឆ្នាំនេះ។ ចំពោះចម្ការកៅស៊ូកសិឧស្សាហកម្មមានស្រាប់ (អតីតក្រុមហ៊ុនកៅស៊ូរដ្ឋទាំង៧ ដែលត្រូវបានធ្វើឯកជនភាវូបនីយកម្ម) ពុំមានការកើនឡើងផ្ទៃដីដាំដុះថ្មីគួរឲ្យកត់សម្គាល់ទេ គឺក្រុមហ៊ុនបានធ្វើការដាំដុះតែលើផ្ទៃដីកៅស៊ូចាស់ កាប់ និងដាំឡើងវិញតែប៉ុណ្ណោះ ពោលគឺកើនឡើងប្រហែល ៤% បើប្រៀបធៀបនឹងឆ្នាំ ២០១០ (៤៥ ពាន់ហិកតាឆ្នាំ២០០៦ ដល់ ៤៧ ពាន់ហិកតា ឆ្នាំ២០១០)។

## ២.២ ការខារអាជីវកម្មកៅស៊ូ

- ផ្ទៃដីចៀរជ័រកៅស៊ូ (ឆ្នាំ២០១០) សម្រេចបានចំនួន ៣៨.៤០៦ ហិកតា ក្នុងនោះផ្ទៃដីចៀរជ័រកៅស៊ូគ្រួសារចំនួន ១៧.៤៣៥ ហិកតា។
- ផលិតផលកៅស៊ូស្ងួត (ឆ្នាំ២០១០) សម្រេចបានចំនួន ៤២.២៥០តោន ក្នុងនោះផលិតផលកៅស៊ូគ្រួសារចំនួន ១៩.២០០តោន ។ ផលិតផលកៅស៊ូស្ងួតបានកើនឡើងប្រហែល ១៦% បើប្រៀបធៀបរយៈពេល៥ឆ្នាំ (កើនពី៣៦.៤០០តោន នាឆ្នាំ២០០៦ ដល់ ៤២.២៤៧តោន នាឆ្នាំ២០១០) ។
- ការនាំចេញកៅស៊ូស្ងួត (ឆ្នាំ២០១០) សម្រេចបាន ៤២.០០០តោន ក្នុងនោះ ផលិតផលកៅស៊ូគ្រួសារចំនួន ១៩.០០០តោន ។ ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ ការនាំចេញកៅស៊ូស្ងួតមានសន្ទុះរីកចំរើនគួរជាទីពេញចិត្ត ពោលគឺបានកើនពី ៣១ពាន់តោន នាឆ្នាំ២០០៦ ដល់ ៤២ពាន់តោននាឆ្នាំ២០១០ (កើនប្រមាណជាង ៣៥%)។

# ៣. ផលិតកម្មសត្វ និង បសុពេទ្យាបាល

ជារួមផលិតកម្មសត្វនៅកម្ពុជា ជាពិសេស គោ ក្របី និងបក្សីមានការវិវឌ្ឍប្រែប្រួលគួរឱ្យកត់សម្គាល់ទាំងចំនួនសត្វ ទាំងបែបផែនផលិតកម្ម ដែលអាចធានាការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុក និងនាំចេញទៅបរទេសបានមួយចំនួន។

ក្នុងរយៈពេល៥ឆ្នាំ ពីឆ្នាំ២០០៦ដល់ឆ្នាំ២០១០នេះ ការចិញ្ចឹមសត្វគោបានកើនពី ៣,៣៤ លានក្បាល (ឆ្នាំ២០០៦) ដល់ចំនួន ៣,៤៨ លានក្បាល (ឆ្នាំ២០១០) ពោលគឺបានកើនប្រមាណ ៤%។ ការចិញ្ចឹមក្របីមានការថយចុះប្រមាណ ៣% ក្នុងរយៈពេល៥ឆ្នាំនេះ គឺបានថយពី ៧២៤ ពាន់ក្បាល (ឆ្នាំ២០០៦) មកត្រឹម ៧០២ ពាន់ក្បាល (ឆ្នាំ២០១០) ។ ការថយចុះនេះ បណ្តាលមកពីប្រជាជនមិនសូវចូលចិត្តបរិភោគសាច់ក្របី ដោយពួកគាត់ចូលចិត្តសាច់គោច្រើនជាង មានន័យថាទីផ្សារសាច់ក្របីធ្លាក់ចុះ និងម្យ៉ាងទៀតប្រជាកសិករមានការលំបាក ក្នុងការស្វែងរកតំបន់ដែលមានទឹកនិងចំណីគ្រប់គ្រាន់សម្រាប់ការចិញ្ចឹមក្របី ជាពិសេសនៅក្នុងអំឡុងពេលនៃរដូវប្រាំង ក្នុងខណៈដែលសត្វក្របីមានតម្រូវការទឹកច្រើន។ ទោះបីជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍនៃការចិញ្ចឹមក្របីគឺត្រូវតែជំរុញថែមទៀតដើម្បីបំពេញនឹងការធ្លាក់ចុះ ។

ការចិញ្ចឹមជ្រូកមាននិន្នាការធ្លាក់ចុះជារៀងរាល់ឆ្នាំ ក្នុងកំឡុងពេល៥ឆ្នាំកន្លងទៅនេះ ។ ផលិតកម្មជ្រូកបានថយចុះពី ២,៧លានក្បាល នាឆ្នាំ២០០៦ ដល់ចំនួនជាង ២ លានក្បាលនាឆ្នាំ២០១០ (ថយចុះប្រមាណជាង ២៥% ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១០)។ ការថយចុះនេះគឺបណ្តាលមកពីប្រជាកសិករបានចំណាយថវិកាខ្ពស់លើការផលិត ពិសេសការទិញចំណីសម្រាប់ការចិញ្ចឹមជ្រូក ដែលធ្វើឱ្យថ្លៃដើមនៃការចិញ្ចឹមជ្រូករបស់ប្រជាកសិករមានតម្លៃខ្ពស់ បើប្រៀបធៀបនឹងប្រទេសជិតខាង និងម្យ៉ាងទៀត ដោយសារការទទួលរងពីការរាតត្បាតជំងឺឆ្លង ដូចជាជំងឺជ្រូកត្រចៀកខៀវ និងការលួចនាំចូលពីប្រទេសជិតខាងជាដើម ។

រីឯការចិញ្ចឹមសត្វស្លាបពីឆ្នាំ២០០៦ដល់២០១០ មានការកើនឡើងយ៉ាងខ្លាំងរហូតដល់ ៣៧% គឺពី ១៥ លានក្បាល ដល់ ២០,៦ លានក្បាល ជាមួយនោះឆ្នាំ២០១០ សត្វស្លាបមានការកើនឡើងចំនួន ៣% បើប្រៀបធៀបនឹងឆ្នាំ២០០៩ នេះបញ្ជាក់ឱ្យឃើញថា ប្រជាកសិករយល់ដឹងជាបណ្តើរៗនូវបច្ចេកទេសចិញ្ចឹមសត្វស្លាប និងការយល់ដឹងអំពីវិធានការទប់ស្កាត់ជំងឺឆ្លង តាមរយៈការប្រើប្រាស់ភ្នាក់ងារសុខភាពសត្វភូមិ ដែលមានចំនួនសរុប ១២.៤៧៤នាក់ ក្នុងទូទាំងប្រទេស ដែលចំនួននេះមានការថយចុះបន្តិច មូលហេតុដោយមានការផ្លាស់ប្តូរលំនៅដ្ឋាននិងមុខរបរផ្សេងៗ។

**ក្រាហ្វិក ៖ បង្ហាញអំពីការវិវឌ្ឍសត្វនៅកម្ពុជាពីឆ្នាំ ២០០៦-២០១០**



ទោះជាយ៉ាងណាក្តី ការផ្សព្វផ្សាយក្នុងជួរកសិករ ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ ដែលជាលទ្ធផលចំនួនគោនិងសត្វស្លាបមានការកើនឡើង និងធានាបាននូវការផ្គត់ផ្គង់សាច់ ស៊ុត នៅក្នុងប្រទេស។ ចំពោះការកែលម្អពូជសត្វ តាមរយៈការបង្កាត់តាមបែបសិប្បនិម្មិត ក៏កំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរៗផងដែរ ដោយសារប្រជាកសិករភាគច្រើន កាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វ ដែលជាកត្តាសំខាន់ក្នុងការផ្តល់ទិន្នផលខ្ពស់ ចំណេះដឹងលើការប្រើប្រាស់ចំណីសត្វដែលទាំងអស់នេះ បានជួយបង្កើនប្រាក់ចំណូលគ្រួសារកសិករបានមួយកម្រិតថែមទៀត។

ម្យ៉ាងវិញទៀត ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិ ក៏កំពុងតែអនុវត្តយ៉ាងផុសផុល ដែលមកទល់ពេលនេះយើងកសាងបានចំនួន ១០.១៥៦ ឡ ក្នុងនោះឆ្នាំ២០១០ ផលិតបាន ៣.៧៥៥ ឡ។

## ៤. អាជីវកម្ម និងកំណែទម្រង់ជលផល

ត្រីមានតួនាទីសំខាន់ផ្តល់ជាស្បៀងអាហារូបត្ថម្ភ និងផ្តល់នូវប្រាក់ចំណូលដល់ប្រជាជនកម្ពុជារាប់លាននាក់។ ត្រីចូលរួមចំណែកប្រមាណជាង៨០ភាគរយនៃប្រូតេអ៊ីន ដែលបានមកពីសាច់សត្វសម្រាប់ប្រជាជនកម្ពុជា ហើយប្រជាជនប្រមាណជាង ៤,៥ លាននាក់ បាននិងកំពុងចូលរួមដោយផ្ទាល់នៅក្នុងវិស័យជលផល។ ផ្អែកទៅលើស្ថិតិផលផល ផលត្រីសរុបកើនឡើង ជាពិសេសពីផ្នែកវារីវប្បកម្មនិងផលចាប់ពីវាលស្រែ។ ច្បាប់ស្តីពីជលផល ត្រូវបានប្រកាសឱ្យប្រើកាលពីខែឧសភា ឆ្នាំ២០០៦ ។ ចាប់តាំងពីមានកំណែទម្រង់វិស័យជលផលមក ការអភិវឌ្ឍវិស័យជលផលត្រូវបានបោះជំហានយ៉ាងខ្លាំង ដោយបានយកចិត្តទុកដាក់ទៅលើជនក្រីក្រ។

ក្នុងអំឡុងពេល៥ឆ្នាំកន្លងទៅ ពីឆ្នាំ២០០៦ដល់ឆ្នាំ២០១០នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបំពេញភារកិច្ចយ៉ាងសកម្ម ដោយបានសម្រេចលទ្ធផលគ្រប់ផ្នែកលើវិស័យជលផល ក្នុងនោះមានការជំរុញការអនុវត្តច្បាប់ស្តីពីជលផល ការកសាងលិខិតបទដ្ឋានក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការបង្កើតស្រះជម្រកត្រី ការអភិវឌ្ឍវារីវប្បកម្ម ការសិក្សាស្រាវជ្រាវ ការអភិរក្សការបង្ក្រាបបទល្មើសនេសាទ និងការផ្សព្វផ្សាយជាដើម។

ជាមួយនឹងការរីកចម្រើននេះដែរ ក្នុងរាល់ឱកាសប្រារព្ធទិវាមច្ឆជាតិ ១ កក្កដា សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី តែងតែបានផ្តល់អនុសាសន៍ដ៏ថ្លៃថ្លា ពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យជលផល ដែលទាក់ទងដល់ការបង្ក្រាបបទល្មើស ការប្រើប្រាស់ឧបករណ៍នេសាទស្បៃមុង ឧបករណ៍ឆក់ត្រី ការបង្កើតកន្លែងអភិរក្សធនធានជលផល ការរៀបចំនិងគ្រប់គ្រងពង្រឹងសហគមន៍នេសាទ ជំរុញការអភិវឌ្ឍវារីវប្បកម្ម ការថែរក្សាការពារព្រៃលិចទឹក និងព្រៃកោងកាងជាដើម ។ល។ ហើយសមិទ្ធផលសំខាន់ៗដែលសម្រេចបានរយៈពេល៥ឆ្នាំ (២០០៦ ដល់ ២០១០) រួមមាន៖

**-អាជីវកម្មនេសាទទឹកសាប:** អាជីវកម្មទឹកសាបអនុវត្តបាននៅឆ្នាំ២០១០ សរុបចំនួន ៤០៥.០០០ តោន កើនលើសឆ្នាំមុនប្រមាណ ៣,៨៥% និងមានការថយចុះប្រមាណ ៤% រយៈពេល ៥ ឆ្នាំ (ឆ្នាំ២០០៦ ដល់ឆ្នាំ២០១០) ប៉ុន្តែអាជីវកម្មនេសាទទឹកសាបនេះ មានការថយចុះបន្តិចពីឆ្នាំ

២០០៧ និងឆ្នាំ២០០៩ ពោលគឺបានថយចុះពី ៣៩៥.០០០ តោន មកត្រឹម ៣៩០.០០០ តោន ឆ្នាំ២០០៩ (ថយចុះប្រមាណ ១,២៧%)។

**-អាជីវកម្មនេសាទសមុទ្រ:** ការធ្វើអាជីវកម្មនេសាទសមុទ្រអនុវត្តបាន ៨៥.០០០តោន ក្នុងឆ្នាំ២០១០ និងមានកំណើនប្រហែល ៤០% រយៈពេល៥ឆ្នាំ រយៈពេល៥ឆ្នាំ (២០០៦-២០១០) ពោលគឺបានកើនពី ៦០,៥ ពាន់តោន នាឆ្នាំ២០០៦ ដល់ ៨៥ ពាន់តោន នាឆ្នាំ២០១០។

**-ការអភិវឌ្ឍវារីវប្បកម្ម:** ការចិញ្ចឹមត្រី បង្គា គ្រប់ប្រភេទឆ្នាំ ២០១០ អនុវត្តបានចំនួន ៦០.០០០ តោន កើនលើសឆ្នាំមុន ១៧ ភាគរយ និងមានការកើនឡើងប្រមាណ ៤៣ ភាគរយ រយៈពេល ៥ ឆ្នាំ (២០០៦-២០១០)។ នៅឆ្នាំ២០១០ នេះដែរការចិញ្ចឹមក្រពើអនុវត្តបាន ២៨៣ ពាន់ ក្បាល ការភ្ញាស់កូនត្រីពូជអនុវត្តបាន ១១០,៨៤ លានក្បាល។

ទន្ទឹមនឹងនោះ យើងបានបង្កើតកន្លែងភ្ញាស់ត្រីនៅទូទាំងប្រទេសបានចំនួន ២៧៣ កន្លែង ដែលក្នុងនោះមាន ២៦០ កន្លែង ជារបស់ប្រជាជនតាមរយៈការផ្តល់បច្ចេកទេសពីរដ្ឋបាលជលផល និងបានបង្កើតសហគមន៍ស្រះជម្រកត្រីបានចំនួន ៦៥៥ កន្លែង ។ បន្ថែមលើនេះទៀតនោះ កន្លែងដែលបានរៀបចំហើយ បានធ្វើឱ្យផលត្រីតាមវាលស្រែកើនពី ៤-៦ ដង ជាមធ្យម នេះអាចបញ្ជាក់បានថា ប្រជាកសិករនិងប្រជានេសាទ បានទទួលយកនូវបច្ចេកទេសវារីវប្បកម្ម ដែលក្រសួងបានអនុវត្តកន្លងមក។

**-ការអភិវឌ្ឍសហគមន៍នេសាទ:**

ការងារពង្រឹងសហគមន៍នេសាទ ក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់ ពោលគឺគិតមកទល់ឆ្នាំ២០១០នេះ សហគមន៍នេសាទចំនួន ៤៦៩ សហគមន៍ ត្រូវបានបង្កើតឡើង ក្នុងនោះ សហគមន៍នេសាទចំនួន ២៣៦ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការពីក្រសួង និងធនាគារក្តាមចំនួន ២៨ កន្លែង ក៏ត្រូវបានបង្កើតឡើងផងដែរ។

**-ការអភិរក្សជលផល:**

ដោយឡែក ការអភិរក្សជលផលត្រូវបានរៀបចំ ទាំងនៅទឹកសាបនិងសមុទ្រ រួមមាន ការអភិរក្សផ្កាថ្ម ស្មៅសមុទ្រ និងបោះបង្គោលការពារព្រៃលិចទឹកនិងព្រៃកោងកាង ។ លើសពីនេះទៀតនោះ ការរៀបចំលែងកូនត្រី កូនបង្កង និងត្រីមេពូជត្រូវបានប្រារព្ធធ្វើជារៀងរាល់ឆ្នាំ។

**-ការបង្ក្រាបបទល្មើសជលផល:**

ក្នុងអំឡុងពេល៥ឆ្នាំកន្លងទៅនេះ ការងារបង្ក្រាបបទល្មើសនេសាទ ត្រូវបានអនុវត្តយ៉ាងសកម្ម ដើម្បីទប់ស្កាត់អំពើល្មើស និងការពារធនធានជលផលប្រកបដោយចីរភាព ជាក់ស្តែងបទល្មើសនេសាទចំនួន ៨.០៧៩ ករណី ត្រូវបានបង្ក្រាបក្នុងឆ្នាំ២០១០ (ទឹកសាប ៥.៤៥៧ករណី និងសមុទ្រ ២.៦២២ ករណី)។

**-ចំណូលចំណាយជលផល:**

ចំណូលពីវិស័យជលផលអនុវត្តបានពីជាង ៧.៤៤៤ លានរៀល នាឆ្នាំ២០០៦ រហូតដល់ជាង ៨.២៤៧ លានរៀល ក្នុងឆ្នាំ២០១០ (កើនឡើងប្រមាណ ១០,៧%) ។




លទ្ធផលដែលទទួលបានក្នុងវិស័យជលផលកម្ពុជាកន្លងមក គឺអាស្រ័យដោយក្រសួងបានយកចិត្តទុកដាក់ខ្ពស់ ដល់ការអភិវឌ្ឍធនធានមនុស្ស ដោយបានខិតខំបណ្តុះបណ្តាល លើមុខជំនាញបច្ចេកទេសដល់មន្ត្រីជលផល រួមទាំងអ្នកនេសាទ សហគមន៍នេសាទ និងកសិករចិញ្ចឹមត្រីផង និងជំរុញការងារសហប្រតិបត្តិការជាមួយអង្គការជាតិនិងអន្តរជាតិ ដើម្បីអភិវឌ្ឍន៍វិស័យវារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព។

ការលែងប្រភេទពូជត្រីក្នុងស្រុកចូលតំបន់ទឹកធម្មជាតិ ដើម្បីបង្កើនផលស្តុកមច្ឆជាតិ បម្រើដល់សេចក្តីត្រូវការរបស់ប្រជាកសិករ និងជំរុញការទាញយកផលពីធនធានទឹក តាមរយៈការពង្រីកតំបន់អភិវឌ្ឍន៍វារីវប្បកម្ម ជាពិសេសការចិញ្ចឹមត្រីក្នុងស្រែត្រូវបានអនុវត្តយ៉ាងសកម្ម។ ម្យ៉ាងវិញទៀត ការជំរុញបង្កើនទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធនិងអង្គការនានា ដើម្បីគាំទ្រដល់ការរៀបចំការគ្រប់គ្រងនិងការអភិវឌ្ឍសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី បានជួយជំរុញថែមទៀតដល់ការលើកស្ទួយវិស័យជលផលនេះ និងបានជួយដល់ការអភិវឌ្ឍជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ជនបទ ឱ្យមានភាពវិវឌ្ឍឈានឡើងជាលំដាប់នាពេលកន្លងមក។ ការខិតខំអនុវត្តអនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី «ធ្វើឱ្យទីណាមានទឹក ទីនោះមានត្រីឡើងវិញ» បានធ្វើឱ្យវិស័យជលផលមានការរីកចម្រើនគួរជាទីមោទនៈ។

## ៥. រុក្ខកម្ម និង កំណែទម្រង់ព្រៃឈើ

រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ លើកម្មវិធីកំណែទម្រង់វិស័យព្រៃឈើដោយខិតខំបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ និងពិសេសយកចិត្តទុកដាក់ជាសំខាន់លើការត្រួតពិនិត្យតាមដានដ៏តឹងរឹង លើការធ្វើអាជីវកម្មព្រៃឈើ សំដៅរក្សាការពារនិងធានានិរន្តរភាពព្រៃឈើ។ ច្បាប់ស្តីពីព្រៃឈើ គឺជាត្រីវិស័យនិងក៏ជាឧបករណ៍ដ៏សំខាន់សម្រាប់ការគ្រប់គ្រងវិស័យព្រៃឈើជាតិ។

កម្មវិធីព្រៃឈើជាតិត្រូវបានរៀបចំឡើង និងបានទទួលការអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជាកាលពីខែតុលា ឆ្នាំ២០១០ កន្លងទៅនេះ។ កម្មវិធីព្រៃឈើជាតិ កំពុងត្រូវបានអនុវត្តយ៉ាងពេញទំហឹងដើម្បីឈានទៅសម្រេចបានតាមគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ដែលបានកំណត់ថាត្រូវថែរក្សាគម្របព្រៃឈើឱ្យបាន៦០ភាគរយនៃផ្ទៃដីសរុបនៅឆ្នាំ២០១៥ ។ កម្មវិធីព្រៃឈើជាតិនេះ បានផ្តោតជាពិសេសលើការពង្រឹងការអនុវត្តច្បាប់ព្រៃឈើនិងអភិបាលកិច្ច ការជំរុញល្បឿននៃការកំណត់ដែនព្រៃឈើ ការលើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រង និងការអភិរក្សព្រៃឈើនិងសត្វព្រៃ ការជំរុញការអភិវឌ្ឍសហគមន៍ព្រៃឈើ ការបង្កើនការដាំនិងស្តារព្រៃឈើឡើងវិញ ការកសាងសមត្ថភាពស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស ការសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយអំពីព្រៃឈើ និងការស្វែងរកប្រភពហិរញ្ញវត្ថុផ្សេងៗទៀត។

ទិសដៅនៃកិច្ចអភិវឌ្ឍនៅក្នុងកំណែទម្រង់វិស័យព្រៃឈើ គឺដើម្បីគ្រប់គ្រងនិងប្រើប្រាស់ធនធានព្រៃឈើតាមរបៀបមួយដែលមានចីរភាព សំដៅទាញយកប្រយោជន៍ឱ្យបានច្រើនបំផុត ពីការរួមចំណែករបស់វិស័យនេះ នៅក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច។ នៅក្នុងដំណើរការនៃការគ្រប់គ្រង ការរក្សាការពារ ការត្រួតពិនិត្យ និងការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការប្រើប្រាស់ធនធានដ៏មានតម្លៃនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តវិធានការជាច្រើន ហើយសម្រេចបានជោគជ័យគួរឱ្យកត់សម្គាល់ នូវសមិទ្ធផលធំៗមួយចំនួនក្នុងរយៈពេល៥ឆ្នាំ (២០០៦ ដល់ ២០១០) ដូចជា៖

- ការធ្វើអាជីវកម្មព្រៃគុបរបស់ក្រុមហ៊ុនព្រៃសម្បទានដែលបានផ្តល់ឱ្យរួចហើយ ត្រូវបានហាមឃាត់។ សកម្មភាពដាំដុះដើមឈើនិងព្រៃឈើឡើងវិញ មានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់ ហើយក្នុងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏បានចែងអំពីវិធានប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើដើម្បីបង្កលក្ខណៈសមស្រប និងជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋសហគមន៍និងផ្នែកឯកជនឱ្យចូលរួមក្នុងសកម្មភាពនេះ។ ជាក់ស្តែង សកម្មភាពដាំឈើជាចម្ការដោយរដ្ឋបាលព្រៃឈើ ក្រុមហ៊ុនវិនិយោគឯកជន និងគ្រួសារឯកជនខ្នាតតូចនាឆ្នាំ២០១០ សម្រេចបានចំនួន ២៨.៨៣៥ ហិកតា ។ ទន្ទឹមនឹងនេះ ការងារបណ្តុះកូនឈើនៅតាមបណ្តាថ្នាលបណ្តុះកូនឈើនៅគ្រប់កន្លែងក្នុងប្រទេស សម្រេចបានចំនួនជាង៩លានដើមជារៀងរាល់ឆ្នាំ សម្រាប់ចែកជូនដល់ប្រជាពលរដ្ឋដាំតាមភូមិដ្ឋាន និងដាំតាមទីសាធារណៈ។
- សហគមន៍ព្រៃឈើត្រូវបានជំរុញឱ្យបង្កើតឡើង តាមប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើដែលបានអនុម័តនៅដើមឆ្នាំ២០០៦។ ជាលទ្ធផល សហគមន៍ព្រៃឈើនៅទូទាំងប្រទេសបានកើនពី ២៦៤ សហគមន៍ នាឆ្នាំ២០០៦ ដល់ ៥១០ សហគមន៍ នាឆ្នាំ២០១០ ដែលបានគ្របដណ្តប់លើផ្ទៃដីព្រៃឈើប្រមាណ ៤៧៦.៨៨៤ ហិកតា។
- រដ្ឋបាលព្រៃឈើដែលបានទទួលភារកិច្ច លើការងាររៀបចំចាត់ចែងលក់កាបូនក្នុងប្រទេសកម្ពុជា បានធ្វើការតាមដាននិងសិក្សាស្រាវជ្រាវស៊ីជម្រៅនិងទាន់ពេលវេលា អំពីសភាព

ការណ៍អន្តរជាតិស្តីពីបញ្ហាព្រៃឈើលើពិភពលោក ដូចជាកាលានុវត្តភាពនៃទីផ្សារឥណទានកាបោនព្រៃឈើ ដែលសហគមន៍ពិភពលោកទាំងមូលកំពុងយកចិត្តទុកដាក់ជាមួយបញ្ហាប្រែប្រួលអាកាសធាតុ និងការកើនកំដៅនៃភពផែនដីនេះ។ ជាទស្សនៈរួមគឺយើងត្រូវការពារព្រៃឈើរបស់យើង ដោយឈប់ធ្វើអាជីវកម្មកាប់ឈើនាំចេញ មកជាការលក់ខ្យល់បរិសុទ្ធ (ឥណទានកាបោន) វិញ ដែលកើតឡើងពីព្រៃឈើរបស់យើង ហើយប្រើប្រាស់ចំណូលទាំងនេះ មកជួយថែរក្សាព្រៃឈើ និងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនសហគមន៍មូលដ្ឋាន។ កន្លងមក ការដាំដុះព្រៃឈើត្រូវបានជំរុញ និងបង្កើនសកម្មភាពខ្លាំងក្លាជាពិសេសការដាំដុះដើមឈើនៅតំបន់ដែលមិនសូវសម្បូរណ៍ព្រៃ តំបន់ភ្នំរេចរិល និងតំបន់ទីជម្រាលដែលមានការហូរច្រោះខ្លាំង ។ បន្ថែមលើនេះទៀតនោះ រដ្ឋបាលព្រៃឈើបានខិតខំនិងសហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការជាតិនានា ដោយបានរៀបចំគម្រោងបង្កើតឥណទានកាបូនលើសហគមន៍ព្រៃឈើមួយចំនួន ។

- ក្នុងរយៈពេល៥ឆ្នាំកន្លងទៅ សកម្មភាពនានាដែលទាក់ទងទៅនឹងយន្តការអភិវឌ្ឍស្អាត និងយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងរេចរិលព្រៃឈើ ត្រូវបានគាំទ្រនិងជំរុញយ៉ាងខ្លាំងក្លា ។
- រៀបចំផែនការគ្រប់គ្រងព្រៃឈើ ផ្តើមពីកម្រិតផ្នែករដ្ឋបាលព្រៃឈើ ដើម្បីជាមូលដ្ឋានសំរាប់ការរៀបចំផែនការគ្រប់គ្រងព្រៃឈើជាតិទូទាំងប្រទេស។ លើសពីនេះទៀតនោះ ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធ រដ្ឋបាលព្រៃឈើបានធ្វើការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើនិងសត្វព្រៃ ហើយចាត់ថ្នាក់ទៅតាមប្រភេទបទល្មើសបានជាច្រើនករណីជារៀងរាល់ឆ្នាំ។ ការចាប់ឃាត់ឈើហ៊ុបមូល និងឈើជ្រុង ឈើអារ និងសត្វព្រៃ បានអនុវត្តដូចភ្លៀងរលឹម សំដៅកាត់បន្ថយការបទល្មើស។ ជាមួយគ្នានេះដែរ ការចុះរុះរើដុតបំផ្លាញនិងការបញ្ឈប់សកម្មភាពរោងម៉ាស៊ីនអារឈើល្មើសច្បាប់ និងរឹបអូសមធ្យោបាយសម្ភារបំរើឱ្យសកម្មភាពល្មើសច្បាប់ជាច្រើនទៀត ត្រូវបានអនុវត្តដោយទទួលបានជោគជ័យក្នុងរយៈពេល៥ឆ្នាំនេះ។
- រដ្ឋបាលព្រៃឈើ បានពង្រីកការអនុវត្តកម្មវិធីសហគមន៍ព្រៃឈើជាតិ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធនៅក្នុងទូទាំងប្រទេស។ ធ្វើការអភិវឌ្ឍផែនការនិងគម្រោងសំណើ ជាពិសេសគម្រោងការស្រាវជ្រាវព្រៃឈើនិងសត្វព្រៃ ដោយធ្វើទំនាក់ទំនងសម្របសម្រួល ដើម្បីស្វែងរកនិងទទួលបាននូវការគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសសម្រាប់ដំណើរការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យព្រៃឈើឱ្យកាន់តែល្អប្រសើរឡើង ជាពិសេសតាមរយៈក្រុមការងារបច្ចេកទេសកំណែទម្រង់ព្រៃឈើ។

## ៦. សេវាកម្មគាំទ្រផលិតកម្ម

ជាមួយនឹងសមិទ្ធផលទាំងឡាយដែលសម្រេចបានជាវិជ្ជមានដូចបានបរិយាយខាងលើ ក៏នៅមានផ្នែកសេវាកម្មនិងការគាំទ្រផ្សេងៗទៀត ដែលទទួលបានលទ្ធផលល្អប្រសើរ តាមត្រីវិស័យដែលបង្ហាញយ៉ាងប្រត្យក្ស ដោយប្រមុខដ៏ឆ្នើមនៃរាជរដ្ឋាភិបាលកម្ពុជា។ ការវិនិយោគសាធារណៈ ការវិនិយោគផ្នែកឯកជន ក៏ដូចជាការយកចិត្តទុកដាក់ពីដៃគូអភិវឌ្ឍន៍នានា រួមទាំងអង្គការជាតិ-អន្តរជាតិ កំពុងតែតម្រង់ទិសយ៉ាងរស់រវើក ទៅរកការជួយទ្រទ្រង់ដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ការធានាសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋ ការកាត់បន្ថយភាពក្រីក្រ ជាពិសេសការអភិវឌ្ឍវិស័យកសិកម្មដោយបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុក្នុងបរិបទនៃសកលភាវូបនីយកម្ម។ ការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ ក៏ដូចជាការរៀបចំលិខិតបទដ្ឋានក្រោមច្បាប់ និងការរៀបចំច្បាប់ពាក់ព័ន្ធផ្សេងៗទៀតកំពុងតែដំណើរការយ៉ាងសកម្ម។

ចំពោះការងារសហប្រតិបត្តិការអន្តរជាតិ ការបណ្តុះបណ្តាលធនធានមនុស្សទាំងក្នុងនិងក្រៅប្រទេស កិច្ចសហប្រតិបត្តិការទ្វេ ពហុភាគី ការងារផ្នែកអាស៊ាន ការអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការនានា បានប្រព្រឹត្តទៅដោយទទួលបានលទ្ធផលជាផ្លែផ្កា ជាពិសេសការរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ានលើកទី ៣២ និងអាស៊ានបូក៣ អនុស្សារណៈនៃការយោគយល់គ្នាស្តីពីសហប្រតិបត្តិការអនាម័យនិងភូតគាមអនាម័យ លើផ្នែកត្រួតពិនិត្យអនាម័យសត្វ និងភូតគាមអនាម័យ ពិធីសារស្តីពីការនាំអង្ករកម្ពុជាទៅកាន់ប្រទេសចិន និងពិធីសារស្តីពីការនាំផលិតផលដំឡូងមីកម្ពុជាទៅកាន់ប្រទេសចិន ជាមួយអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័កនៃសាធារណរដ្ឋប្រជាមានិតចិននាពេលកន្លងមកនេះ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំសន្និបាតកសិករទូទាំងប្រទេសចំនួន ២ លើករួចមកហើយ ក្នុងគោលបំណងដើម្បីគាស់កកាយនូវមូលដ្ឋាននៃចំណេះដឹងរបស់ប្រជាកសិករនៅជនបទ លាតត្រដាងឱ្យឃើញការពិតពីគំនិតច្នៃប្រឌិត រកឱ្យឃើញនូវកសិករឆ្នើមទូទាំងប្រទេសដើម្បីជាគំរូ និងធ្វើការផ្សព្វផ្សាយជាបន្តដល់កសិករដ៏ទៃទៀតក្នុងទូទាំងប្រទេស ពោលគឺចង់បង្ហាញឱ្យឃើញពីភាពម្ចាស់ការក្នុងការប្រែក្លាយចំណេះដឹងរបស់ខ្លួន ដើម្បីជាប្រយោជន៍ទៅដល់កសិករដ៏ទៃទៀត ក៏ដូចជាការដើរទន្ទឹមទៅនឹងការប្រែប្រួលនៃបច្ចេកវិជ្ជា ក្នុងបរិបទនៃសាកលភាវូបនីយកម្មដោយតម្រង់ចក្ខុវិស័យ ទៅរកការប្រកួតប្រជែងទាំងបរិមាណនិងគុណភាព ឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មដ៏ស៊ីជម្រៅ។ ដោយឡែកចំពោះកសិករឆ្នើម ដែលជាប់ចំណាត់ថ្នាក់លេខ១ ទទួលបាននូវរង្វាន់និងថវិកា ដែលជាអំណោយដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវផងដែរ។

# គ. ការវាយតម្លៃ និង សន្និដ្ឋាន

## ១. ភាពខ្លាំង បញ្ហាប្រឈម និង ឧបសគ្គ

### ១.១ ភាពខ្លាំង និងកាលានុវត្តភាព

- សក្តានុពលផ្នែកផលិតកម្មកសិកម្ម ធនធានដីនិងទឹកនៅមានលទ្ធភាពអាចបង្កើនបានគ្រប់គ្រាន់ សំដៅធានាដល់ការរីកលូតលាស់ផ្នែកផលិតកម្មកសិកម្ម មានកម្លាំងពលកម្មច្រើននៅតាមទីជនបទ និងមានតម្លៃថោកសមរម្យ។
- ប្រជាកសិករបានខិតខំប្តូរទម្លាប់ពី «ការធ្វើកសិកម្មដើម្បីចិញ្ចឹមឆ្នាំង» ទៅជា «ការធ្វើកសិកម្មសម្រាប់លក់ដូរ» ដែលនេះពិតជារបត់ថ្មីមួយជួយជំរុញការអភិវឌ្ឍក្នុងវិស័យកសិកម្មកម្ពុជា។ ការកើនឡើងនៃការប្រើប្រាស់ធាតុចូលកសិកម្ម គ្រឿងយន្តកសិកម្មជាទឡ្ហីករណ៍បញ្ជាក់យ៉ាងជាក់លាក់។
- ធនធានមនុស្សរបស់រដ្ឋដែលបម្រើឱ្យការងារផលិតកម្មកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានលក្ខណៈល្អប្រសើរ និងមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលជាកត្តាអាចជួយបង្កើនសមត្ថភាពផ្តល់សេវាកម្មនានារបស់រដ្ឋ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។
- គោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា បានតម្រង់ទិសដៅដាក់ឱ្យអនុវត្តច្បាស់លាស់ក្នុងការអភិវឌ្ឍកសិកម្ម និងអ្នកពាក់ព័ន្ធទាំងអស់មានការប្តេជ្ញាចិត្ត និងទទួលស្គាល់នូវសារៈសំខាន់នៃវិស័យកសិកម្មនេះ ទាំងផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងប្រជាកសិករ។
- រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ ដល់ការអភិវឌ្ឍវិស័យកសិកម្មតាមរយៈការបង្កើនការវិនិយោគលើការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តបម្រើឱ្យផ្នែកសិកម្ម ពិសេសប្រព័ន្ធធារាសាស្ត្រ ផ្លូវជនបទ ព្រមទាំងការបង្កើនសមត្ថភាពការផ្តល់សេវាបច្ចេកទេស ការប្រើប្រាស់ធាតុចូលកសិកម្មសមស្រប ការគ្រប់គ្រងដីធ្លី ឥណទានជនបទ ការអភិវឌ្ឍសហគមន៍កសិករ និងទីផ្សារកសិកម្ម។
- មានការអភិវឌ្ឍផ្នែកកសិពាណិជ្ជកម្ម ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងទាញយកឱកាសនៃផ្គត់ផ្គង់ផលិតផលកសិកម្ម។ តម្រូវការប្រើប្រាស់ផលិតផលកសិកម្មមាននិន្នាការកើនឡើងនៅលើពិភពលោក ដែលនេះជាកាលានុវត្តភាពទីផ្សារមួយសម្រាប់កម្ពុជាក្នុងការបង្កើនផលិតកម្ម និងការប្រជែងទីផ្សារ។

### ១.២ បញ្ហាប្រឈម និង ឧបសគ្គ

បញ្ហាប្រឈមចំពោះមុខនៅក្នុងការអភិវឌ្ឍវិស័យនេះរួមមានៈ

- ការបង្កើនផលិតភាពនិងពិពិធកម្មកសិកម្ម ពិសេសនៅក្នុងផលិតកម្មដំណាំស្រូវ និងដំណាំផ្សេងៗទៀតនៅជួបបញ្ហាប្រឈមមួយចំនួននៅឡើយ ទោះបីជាសកម្មភាព

ដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានអនុវត្ត ដែលទាំងនេះទាមទារឱ្យមានការបង្កើនបន្ថែមទៀតនូវធនធានទាំងផ្នែកបច្ចេកទេសនិងថវិកា ព្រមទាំងការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធដើម្បីជំរុញនិងបង្កើនលទ្ធភាពទទួលបាន នូវសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ឥណទានបំរើផលិតកម្មកសិកម្ម និងធាតុចូលកសិកម្ម ។ ការដោះស្រាយទឹកស្រោចស្រពក្នុងកសិកម្ម គឺជាបញ្ហាដែលត្រូវបន្តដោះស្រាយ ដែលទាមទារឱ្យមានការបង្កើនការវិនិយោគដើម្បីបង្កើនការស្រោចស្រពនាពេលខាងមុខ។

- ការធានាឱ្យមាននូវអត្ថប្រយោជន៍កាន់តែប្រសើរជាងមុនសម្រាប់កសិករ តាមរយៈការរកទីផ្សារលក់ផលិតផល គឺជាបញ្ហាដែលត្រូវបន្តអនុវត្តបន្ថែមទៀត ព្រោះថាកសិករនៅមានការលំបាកក្នុងការស្វែងរកទីផ្សារលក់កសិផល និងលំបាកក្នុងការប្រកួតប្រជែងទីផ្សារក្នុងបរិបទនៃសេដ្ឋកិច្ចទីផ្សារសេរី។
- ការយល់ដឹងរបស់កសិករក្នុងការប្រើប្រាស់សម្ភារកសិកម្ម ឱ្យបានត្រឹមត្រូវតាមបច្ចេកទេស និងការគ្រប់គ្រងជីជាតិដី ក៏នៅតែជាបញ្ហាប្រឈមនៅឡើយ ដែលសកម្មភាពនានាពាក់ព័ន្ធនឹងបញ្ហានេះ នឹងត្រូវយកចិត្តទុកដាក់អនុវត្តបន្តឱ្យបានខ្លាំងក្លា។ ទន្ទឹមនោះ ឧបករណ៍ច្បាប់ និងសមត្ថភាពបច្ចេកទេសក្នុងការអនុវត្ត លើការគ្រប់គ្រងធនធានដី និងជីជាតិដីកសិកម្មនៅខ្វះខាត ដែលទាមទារឱ្យមានច្បាប់ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មនាពេលខាងមុខ ។
- ការកែលំអការគ្រប់គ្រងក្រោយពេលប្រមូលផលហាក់នៅមានកម្រិតនៅឡើយ ការជំរុញកសិឧស្សាហកម្ម រួមទាំងការកែច្នៃក្រោយពេលប្រមូលផល ការកែលំអគុណភាពនៃស្តង់ដារកសិផល គឺត្រូវបានវាយតម្លៃថានៅមានកម្រិត។
- ការបង្កើតសមាគមកសិករក្នុងគោលបំណងដើម្បីបង្កើនអំណាចតថ្លៃ ការទទួលបាននូវសេវាបច្ចេកទេសនិងឥណទាន និងការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវធនធាន គឺត្រូវបានអនុវត្ត ប៉ុន្តែក៏អាចទទួលស្គាល់ថានៅមិនទាន់គ្រប់គ្រាន់ ដែលត្រូវបន្តពង្រឹងឱ្យបានប្រសើរជាងនេះ។
- ការលើកទឹកចិត្តឱ្យមានការចូលរួមរបស់ផ្នែកឯកជន ក្នុងការអភិវឌ្ឍវិស័យកសិកម្ម គឺជាកត្តាចាំបាច់ សំដៅបង្កើនការវិនិយោគក្នុងវិស័យនេះ ។ កន្លងមក មានក្រុមហ៊ុនវិនិយោគជាច្រើនបានបណ្តាក់ទុនវិនិយោគ លើផលិតកម្មដំណាំកសិឧស្សាហកម្ម តាមរូបភាពសម្បទានដីសេដ្ឋកិច្ច ហើយមានករណីមួយចំនួនដែលជាបញ្ហារាំងស្ទះដល់ការអនុវត្ត និងទាមទារដោះស្រាយ ។ ប៉ុន្តែក៏មានករណីដែលវិនិយោគិនខ្លះមិនបានអនុវត្តកិច្ចសន្យា ដោយទុកដីឱ្យនៅទំនេរមិនបានដាំដុះ និងប្រឈមនឹងការដកហូតមកវិញ។ សកម្មភាពត្រួតពិនិត្យការអនុវត្តកិច្ចសន្យា នឹងត្រូវបង្កើនឱ្យបានខ្លាំងក្លានាពេលខាងមុខ។

- ដោយឡែកការប្រឈមដែលជាតម្រូវការក្នុងការជួយទ្រទ្រង់ដល់វិស័យនេះឱ្យសម្រេចជោគជ័យ គឺការបង្កើតក្របខ័ណ្ឌច្បាប់បន្ថែម រួមទាំងសមត្ថភាពអនុវត្តច្បាប់នៅគ្រប់កម្រិត ការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការបង្កើតនិងអភិវឌ្ឍន៍សមត្ថភាពអង្គភាពជំនាញកសិកម្មថ្នាក់មូលដ្ឋាន ដែលមានសមត្ថភាពបម្រើសេវាកម្មបច្ចេកទេសដល់កសិករផ្ទាល់ និងការជំរុញកម្មវិធីផ្សព្វផ្សាយនៅក្នុងមូលដ្ឋាន។
- ផលិតកម្មសត្វនៅកម្ពុជាមានបម្រែបម្រួលកំណើនយឺត ដោយមានការលំបាកកន្លងមក និងការប្រឈមដូចជា ជំងឺឆ្លងរាតត្បាត និងកង្វះមធ្យោបាយគ្រប់គ្រាន់ លើការការពារ និងកម្ចាត់ ការប្រកួតប្រជែងនៃទីផ្សារសាច់សត្វ ដោយសារថ្លៃដើមផលិតកម្មខ្ពស់ ពិសេសថ្លៃចំណីសត្វ ការរំលោភលើបទដ្ឋានច្បាប់ និងបច្ចេកទេសផ្សេងៗរបស់អ្នកជំនួញសត្វ និងអ្នកចិញ្ចឹមជាដើម។
- ព្រៃលិចទឹក ការទន្ទ្រានដីក្នុងនាទីព្រៃលិចទឹកនិងដែននេសាទ ត្រូវប្រឈមមុខនឹងការកាប់បំផ្លាញក្នុងរូបភាពជួញដូរ ដែលត្រូវតែមានវិធានការជាបន្ទាន់បំផុត។ ធនធានថវិកាក្នុងការចាត់វិធានការ ការពារកន្លែងអភិរក្សត្រីបឹងទន្លេសាប អន្លង់ត្រី អន្លង់ផ្សោតនៅតំបន់ទន្លេមេគង្គលើ ការអភិរក្សសមុទ្រ ការបោះបង្គោលព្រំប្រទល់ព្រៃលិចទឹកនិងការងារលុបបំបាត់បទល្មើសជលផលនៅមានកម្រិតនៅឡើយ។ សមត្ថភាពរបស់គណៈកម្មការសហគមន៍នេសាទក៏នៅមានកម្រិតដែរ ដោយសហគមន៍ភាគច្រើនពុំមានការជួយឧបត្ថម្ភគាំទ្រគ្រប់គ្រាន់។ បទល្មើសនេសាទដោយប្រើឧបករណ៍ឆក់ ស្បៃមុង ការកាប់បំផ្លាញព្រៃលិចទឹកក្នុងដែននេសាទនៅតែកើតមាន។ ការកំណត់ព្រំប្រទល់ដែននេសាទ និងការបោះបង្គោលព្រំតែងជួបប្រទះការលំបាក។
- នៅក្នុងវិស័យព្រៃឈើ មធ្យោបាយសម្រាប់ដំណើរការការងារនៅតំបន់ដាច់ស្រយាលនៅមានកម្រិត ដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពការងារ។ ជនប្រព្រឹត្តបទល្មើសតែងតែផ្លាស់ប្តូរវិធីសាស្ត្រក្នុងការប្រមូលផលឈើ ដឹកជញ្ជូន និងកាប់រានដីព្រៃឈើយកធ្វើជាកម្មសិទ្ធិក្រោមរូបភាពផ្សេងៗ។ កិច្ចសហការនិងការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត ជាពិសេសក្នុងការត្រួតពិនិត្យ បង្ក្រាបបទល្មើសព្រៃឈើ និងការកំណត់ព្រំប្រទល់ដែនដីព្រៃឈើ តែងជួបប្រទះការលំបាកយឺតយ៉ាវនិងមានវិវាទជាមួយជនល្មើស ព្រមទាំងមានការលួចវាយបំផ្លាញបង្គោលព្រំដែលបានបោះរួច។ ប្រជាជនមូលដ្ឋានដែលរស់នៅក្នុងនិងក្បែរតំបន់ព្រៃឈើ នៅតែពឹងអាស្រ័យខ្លាំងលើព្រៃឈើ ហើយការគ្រប់គ្រងជនចំណាកស្រុក នៅមានការធូររលុងដែលជាសម្ពាធធ្ងន់ធ្ងរចំពោះធនធានព្រៃឈើ ។

## ២. ការវាយតម្លៃ និង សន្និដ្ឋាន

ផ្អែកលើលទ្ធផលទទួលបានក្នុងរយៈពេល៥ឆ្នាំ (២០០៦-២០១០) កន្លងមកនេះ យើងអាចវាយតម្លៃជារួមបានថា បើទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិ រួមមានកង្វះខាតទឹកដោយសារកួនរដូវប្រាំងនៅពាក់កណ្ដាលរដូវវស្សា គ្រោះជំនន់ទឹកភ្លៀងចុងរដូវវស្សា ព្រមទាំងស្ថិតនៅក្រោមការប៉ះទង្គិចដោយកលយុគ្គវិបត្តិសេដ្ឋកិច្ចពិភពលោក តែក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំនិងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័នអាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ និងប្រជាកសិករទូទាំងប្រទេស ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ផងនោះ បានធ្វើឱ្យផលិតកម្មកសិកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងជាទីមោទនៈ។

ផលិតកម្មស្រូវរយៈពេល៥ឆ្នាំ (២០០៦-២០១០) នេះ បានទទួលលទ្ធផលគួរជាទីពេញចិត្ត ដែលជាលទ្ធផលគឺ កម្ពុជាទទួលបានបរិមាណផលស្រូវចំនួន៨,២៥លានតោន និងអាចសល់ស្បៀង (ជាអង្ករ) សរុបចំនួន២,៥លានតោន (ឬ៣,៩លានតោនស្រូវ) នៅឆ្នាំ២០១០ ដែលនេះជាជោគជ័យមួយគួរជាទីមោទនៈបំផុតសម្រាប់កម្ពុជា។ ផ្អែកលើសមិទ្ធផលខាងលើនេះ យើងអាចវាយតម្លៃជារួមបានថាផលិតកម្មកសិកម្មកម្ពុជាយើង ពិសេសផលិតកម្មស្រូវពីមួយឆ្នាំទៅមួយឆ្នាំ មានការវិវឌ្ឍឈានឡើងជាលំដាប់ ដោយសារកត្តា២យ៉ាងគឺ (១) ការពង្រីកដីដាំដុះ ដែលរួមទាំងការធ្វើបង្កើនរដូវតែពិសេសនោះគឺ (២) កត្តាកើនឡើងនៃទិន្នផល (២,៩៧តោន/ហ.ត) ដែលជាសមិទ្ធផលនៃការសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយ ពូជថ្មី បច្ចេកទេសដាំដុះ និងការថែទាំ។

ដំណាំរួមផ្សំនិងឧស្សាហកម្ម ដំណាំឈើហូបផ្លែនិងដំណាំអចិន្ត្រៃយ៍ កំពុងមានការរីកចម្រើនជាបន្តបន្ទាប់ជាលក្ខណៈគ្រួសារនិងជាលក្ខណៈវិនិយោគខ្នាតតូច មធ្យម និងធំ ជាក់ស្តែងផ្ទៃដីដាំដុះកៅស៊ូមានសន្ទុះកើនឡើង ពិសេសការអភិវឌ្ឍកៅស៊ូគ្រួសារមានការវិវឌ្ឍតាមសន្ទុះមួយគួរឱ្យចាប់អារម្មណ៍។

ផលិតកម្មសត្វ ក្របី ជ្រូក មានការថយចុះបន្តិច ប៉ុន្តែការចិញ្ចឹមសត្វគោនិងសត្វស្លាប បានកើនឡើងគួរឱ្យកត់សម្គាល់ ដោយសារការបង្កើនការងារផ្សព្វផ្សាយពូជ ការបង្ការជំងឺឆ្លងសត្វ និងការពង្រីកចំណេះដឹងផ្នែកបច្ចេកទេសនៃការចិញ្ចឹមសត្វដល់ប្រជាកសិករបានទូលាយ។

ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល កំពុងស្ថិតនៅតែជាប្រធានបទតឹងតែងស្ថិតស្វាញរវាងអភិរក្សនិងអភិវឌ្ឍ ហើយដែលត្រូវតែខិតខំរកឱ្យឃើញផ្លូវសមស្របមួយ ប្រកបដោយភាពសម្រុះសម្រួល និងចូលរួមដោយសុឆន្ទៈជាមួយនឹងការបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗ។

បន្ថែមជាងនេះទៅទៀត ផ្នែកសេវាកម្មនិងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល។ តែទោះ

យ៉ាងណាក្តី ផ្លូវនៅវែងឆ្ងាយទៀតដើម្បីសម្រេចបានគោលដៅ និងមហិច្ឆតាធំធេងដែលយើងចង់បាន សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាមួយ មានលក្ខណៈវិទ្យាសាស្ត្រទំនើប និងមានប្រសិទ្ធភាពខ្ពស់។

----------✍📖✍----------

# ផ្នែកទី ២

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០០៩-២០១៣)

----------✎✍---------

## I- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០០៩-២០១៣)

### ក. សាវតារ

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២នៃរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឆ្លាសវៃរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ការលើកកម្ពស់វិស័យកសិកម្ម សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងពន្លឿនការកាត់បន្ថយភាពក្រីក្រ ដោយផ្ដោតសំខាន់ទៅលើការលើកកម្ពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម កំណែទម្រង់ដីធ្លី កំណែទម្រង់ជលផល និងកំណែទម្រង់ព្រៃឈើ។

ចតុកោណយុទ្ធសាស្ត្រទាំងបួនសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចជាតិគឺៈ ១-ការលើកស្ទួយវិស័យកសិកម្ម ២-ការអភិវឌ្ឍផ្នែកឯកជននិងការងារ ៣-ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៤-ការកសាងសមត្ថភាពនិងអភិវឌ្ឍន៍ធនធានមនុស្ស។

ការលើកស្ទួយវិស័យកសិកម្មរួមមានៈ **(ទី១)-ការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម (ទី២)-កំណែទម្រង់ដីធ្លីនិងការបោសសំអាតមីន (ទី៣)-កំណែទម្រង់ជលផល និង (ទី៤)-កំណែទម្រង់ព្រៃឈើ។**

គោលនយោបាយកសិកម្មរបស់រាជរដ្ឋាភិបាល គឺសំដៅលើកកម្ពស់វិស័យកសិកម្ម ឱ្យក្លាយទៅជាផ្នែកនាំមុខមួយ ដែលអាចផ្ដល់ចលករបន្ថែមដល់កំណើនសេដ្ឋកិច្ច និងអាចចូលរួមវិភាគទានយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ។ នៅក្នុងទិសដៅនេះ រាជរដ្ឋាភិបាលកម្ពុជានឹងបង្កើនការប្រើប្រាស់ធនធានក្នុងស្រុក រួមជាមួយធនធានថវិកានិងជំនួយបច្ចេកទេស ពីដៃគូអភិវឌ្ឍន៍នានាសម្រាប់អនុវត្តពហុវប្បកម្ម និងប្រពលវប្បកម្មកសិកម្ម ដោយដោះស្រាយជាកញ្ចប់នូវបញ្ហាបច្ចេកទេសកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា ផ្លូវថ្នល់ ធារាសាស្ត្រ និងអគ្គិសនី ព្រមទាំងឥណទានទីផ្សារ និងការកែច្នៃកសិផល ជាពិសេសការកែច្នៃសម្រាប់ការនាំចេញ ដើម្បីធានាបាននូវនិរន្តរភាពនៃកំណើនសេដ្ឋកិច្ច បង្កើតការងារនិងបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានាសន្តិសុខស្បៀងសម្រាប់ប្រជាជនទូទៅ ហើយធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងបង្កើនការនាំចេញផលិតផលកសិកម្ម។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣ ត្រូវបានរៀបចំឡើងដោយឆ្លុះបញ្ចាំង និងឆ្លើយតបនូវទិសដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២នៃរាជរដ្ឋាភិបាលកម្ពុជា។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣ ក៏បានរៀបចំធ្វើឱ្យមានសង្គតិភាពរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ សំដៅចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ និងពន្លឿនការកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកកម្ពស់និងជំរុញការអភិវឌ្ឍវិស័យកសិកម្ម។

## ខ. ចក្ខុវិស័យរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (Vision)

ចក្ខុវិស័យរយៈពេលវែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺដើម្បីធានាៈ *«ភាពមានស្បៀងគ្រប់គ្រាន់ និងប្រកបដោយសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ដោយជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្ម រួមនឹងការគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព»* ។

## គ. បេសសកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (Mission)

បេសកកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺដើម្បីៈ *«ចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា តាមរយៈ ការផ្តល់សេវាកម្មមានគុណភាពខ្ពស់ ដែលនាំដល់ការផ្គត់ផ្គង់ស្បៀងប្រកបដោយសុវត្ថិភាព បង្កើនផលិតភាពកសិកម្មនិងតម្លៃបន្ថែម ដោយផ្អែកទៅលើមូលដ្ឋាននិរន្តរភាពនិងប្រសិទ្ធភាពតម្លៃចំពោះវិស័យ ដែលពឹងផ្អែកលើផលិតកម្មកសិកម្ម នេសាទ និងរុក្ខាប្រមាញ់»* ។

## ឃ. ទិសដៅគោលនយោបាយ ( Policy Goal )

### *១. ទិសដៅគោលនយោបាយរួម (Overall Policy Goal)*

*«លើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជកម្មកសិកម្ម ដើម្បីកាត់បន្ថយភាពក្រីក្រនិងជំរុញកំណើនសេដ្ឋកិច្ច ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព»* ។

ដើម្បីសម្រេចបាននូវទស្សនវិស័យ និងទិសដៅគោលនយោបាយរួមនេះ សកម្មភាពគាំទ្រជាច្រើននឹងត្រូវបានផ្តល់ រួមជាមួយនូវធាតុចូលសំខាន់ៗ សំដៅជំរុញដល់ការលូតលាស់សេដ្ឋកិច្ចដូចជាការផ្តល់នូវសេវាកម្មមានគុណភាពខ្ពស់ ហើយធានាបានការផ្គត់ផ្គង់ស្បៀងអាហារប្រកបដោយសុវត្ថិភាព ជាពិសេសបង្កើនផលិតផលកសិកម្មនិងតម្លៃបន្ថែម ដោយផ្អែកលើនិរន្តរភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចនៃការចំណាយលើវិស័យកសិកម្ម ។ ក្នុងលក្ខខណ្ឌធម្មតា និងមិនមានគ្រោះធម្មជាតិកើតឡើង កំណើននៃផ្នែកកសិកម្មនឹងត្រូវរក្សាក្នុងរង្វង់ ៥% ក្នុងមួយឆ្នាំៗ។

## ២. ទិសដៅគោលនយោបាយតាមផ្នែក (Specific Policy Goals)

ដើម្បីសម្រេចបានគោលដៅជាយុទ្ធសាស្ត្រចម្បងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបន្តកំណត់នូវទិសដៅគោលនយោបាយជាយុទ្ធសាស្ត្រ តាមវិស័យនិងអនុវិស័យ ដែលមានស្រាប់ដូចខាងក្រោម ៖

| | |
|---|---|
| *ទិសដៅគោលនយោបាយទី.១៖* | *«ធានាសន្តិសុខស្បៀង បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម»* |
| *ទិសដៅគោលនយោបាយទី.២៖* | *«ពង្រីកលទ្ធភាពឈានចូលទីផ្សារ សម្រាប់ផលិតផលកសិកម្ម»* |
| *ទិសដៅគោលនយោបាយទី.៣៖* | *«ក្របខ័ណ្ឌនៃការអភិវឌ្ឍស្ថាបន័ និងបញ្ញត្តិច្បាប់»* |
| *ទិសដៅគោលនយោបាយទី.៤៖* | *«កំណែទម្រង់ជលផល»* |
| *ទិសដៅគោលនយោបាយទី.៥៖* | *«កំណែទម្រង់ព្រៃឈើ»* |

### គោលបំណងគោលនយោបាយៈ (Policy Objectives)

*ទី-១៖ បង្កើនផលិតភាពនិងពិពិធកម្មកសិកម្ម ដោយធានាឱ្យបាននូវកំណើនផលិតកម្មគ្រប់មុខដំណាំ ១០% ផលិតកម្មសត្វ ៣% ក្នុងមួយឆ្នាំ លើមូលដ្ឋាននៃការបង្កើនការស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្មទូលាយជាងមុននិងការទប់ស្កាត់ជំងឺឆ្លងសត្វកាន់តែមានប្រសិទ្ធភាព។*

*ទី-២៖ ធានារក្សាឱ្យបាននូវផ្ទៃដីឡូត៍នេសាទប្រមាណ ៥៦,៤% សម្រាប់សហគមន៍នេសាទ បង្កើនការការពារធនធានជលផល ការទប់ស្កាត់បទល្មើសនេសាទ ពិសេស តំបន់ជុំវិញបឹងទន្លេសាប និងការជំរុញវារីវប្បកម្មក្នុងកំរិត ១៥% ក្នុងមួយឆ្នាំ រួមនឹងការពង្រឹងសមត្ថភាពសហគមន៍នេសាទឱ្យកាន់តែប្រសើរឡើង ។*

*ទី-៣៖ រក្សាបាននូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ ៦០% នៅឆ្នាំ២០១៥ ដោយត្រូវបង្កើនការការពារធនធានព្រៃឈើ ពិសេសការទប់ស្កាត់បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំឈើឡើងវិញឱ្យបានខ្លាំងក្លា និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើ លើមូលដ្ឋាននិរន្តរភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រង។*

### ៣. កម្មវិធី ទាំង៥ របស់ក្រសួង (MAFF Programmes):

ដើម្បីធ្វើឱ្យសម្រេចបានទិសដៅគោលនយោបាយ និងយុទ្ធសាស្ត្រទាំងប្រាំខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកម្មវិធីអាទិភាពសំខាន់ៗចំនួនប្រាំ ដែលជាផ្នែកមួយនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ សំដៅពង្រឹងការអនុវត្តថវិកាតាមកម្មវិធី និងកម្មវិធីវិនិយោគសាធារណៈ ដោយរួមបញ្ចូលនូវប្រភពធនធានថវិកាខាងក្រៅផងដែរ។ កម្មវិធីទាំង៥នោះរួមមាន ៖

| | |
|---|---|
| **កម្មវិធីទី-១៖** | **បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម** |
| *Programme-1:* | *Enhancement of Agricultural Productivity and Diversification;* |
| **កម្មវិធីទី-២៖** | **ជំរុញការចូលទីផ្សារនៃផលិតផលកសិកម្ម** |
| *Programme-2:* | *Increase Market Access for Agricultural Products;* |
| **កម្មវិធីទី-៣៖** | **ពង្រឹងស្ថាប័ន ក្របខ័ណ្ឌច្បាប់ និងអភិវឌ្ឍន៍ធនធានមនុស្ស** |
| *Programme-3:* | *Strengthening Institutional & Legislative Framework and HRD;* |
| **កម្មវិធីទី-៤៖** | **ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព** |
| *Programme-4:* | *Sustainable Fisheries Resource Management* |
| **កម្មវិធីទី-៥៖** | **ការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព** |
| *Programme-5:* | *Sustainable Forestry and Wildlife Resource Management* |

## ខ. អភិក្រមដើម្បីសម្រេចទិសដៅគោលនយោបាយ ( Approaches )

ក្នុងគោលដៅសម្រាប់ជំរុញការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម កំណែទម្រង់ដីធ្លី កំណែទម្រង់ជលផល និងព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំនិងយកចិត្តទុកដាក់ជាសំខាន់នូវចំណុចជាយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម៖

- ផ្តល់អាទិភាពខ្ពស់ទៅលើការបង្កើនផលិតភាពកសិកម្ម និងការធ្វើពិពិធភាវូបនីយកម្ម ក្នុងវិស័យកសិកម្ម ព្រមទាំងការជំរុញកសិឧស្សាហកម្មឱ្យបានខ្លាំងក្លា ដោយត្រូវយកចិត្តទុកដាក់លើការបង្កើនសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ តាមរយៈការបង្វែរទិសដៅពីការអភិវឌ្ឍតាមបែប "**វិបុលកម្ម**" ទៅកាន់ការអភិវឌ្ឍតាមបែប "**ប្រពលវប្បកម្ម**" ក្នុងគោលដៅបង្កើនផលិតកម្ម បង្កើតការងារ បង្កើនប្រាក់ចំណូលនៅជនបទ ធានានូវសន្តិសុខស្បៀង និងបង្កើនការនាំចេញកសិផល ជាពិសេសកសិផលសម្រេច ។
- ពង្រឹងនិងពង្រីក "***សេវាផ្សព្វផ្សាយកសិកម្ម***" ដោយជំរុញការផ្តល់សេវានេះ ឱ្យទៅដល់ថ្នាក់មូលដ្ឋាន ពិសេសការពង្រឹងសេវាថ្នាក់ស្រុក ឃុំ និងត្រូវតម្រង់ទិសជ្រើសរើសក្រុម

គោលដៅដែលត្រូវទទួលផល ជាពិសេសការយកចិត្តទុកដាក់ដល់ក្រុមកសិករ ដែលជាសមាជិកសហគមន៍អភិវឌ្ឍន៍កសិកម្ម ឬសហករណ៍កសិកម្ម និងផ្សារភ្ជាប់ជាមួយនឹងបណ្ដាញអ្នកស្ម័គ្រចិត្តថ្នាក់ឃុំ-ភូមិ (ផ្ដោតលើការពង្រឹងសមត្ថភាពភ្នាក់ងារសុខភាពសត្វភូមិឱ្យក្លាយជាអ្នកផ្សព្វផ្សាយកសិកម្មភូមិ) ព្រមទាំងធានាស្ថេរភាពនៃប្រព័ន្ធសេវាបច្ចេកទេសកសិកម្មដែលបាននិងកំពុងអនុវត្ត ។ យកចិត្តទុកដាក់លើអន្តរាគមន៍ សំដៅជួយដល់ការបង្កើនផលិតកម្មកសិកម្ម តាមរយៈការសិក្សាពិសោធន៍ស្រាវជ្រាវកសិកម្ម សំដៅជំរុញការអភិវឌ្ឍផលិតកម្មកសិកម្ម ។

- បន្តពង្រឹងនិងពង្រីកសមត្ថភាពពិសោធន៍ វិភាគក្នុងមន្ទីរពិសោធន៍កសិកម្មជាតិ តាមរយៈការពង្រឹងសមត្ថភាពជំនាញរបស់មន្ត្រីជាប្រចាំ និងស្វែងរកថវិកាដើម្បីបំពាក់នូវសម្ភារបរិក្ខារទំនើបទាន់សម័យគ្រប់គ្រាន់ សម្រាប់ដំណើរការពិសោធន៍វិភាគ និងជំរុញការអនុវត្តការងារធ្វើបទកម្មលើផលិតផលនិងសម្ភារវេចខ្ចប់ ចូលរួមចំណែកលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម សម្រាប់ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ និងធានាសុខភាពសាធារណៈ។
- ជំរុញការស្ដារ និងកសាងហេដ្ឋារចនាសម្ព័ន្ធនៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍កសិកម្ម និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កសិកម្ម ដើម្បីបម្រើឲ្យការងារពិសោធន៍ស្រាវជ្រាវអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាទំនើបសមស្របលើគ្រប់មុខជំនាញពាក់ព័ន្ធនឹងផលិតកម្មដំណាំ ពិសេសដំណាំស្រូវ ដើម្បីឈានឆ្ពោះទៅសម្រេចបានជាបណ្ដើរៗ នូវគោលដៅនៃគោលនយោបាយស្ដីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ដែលដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា។
- ជំរុញនិងបង្កើតបរិយាកាសអនុគ្រោះឱ្យកាន់តែប្រសើរឡើងថែមទៀត សម្រាប់ទាក់ទាញវិនិយោគទុនឯកជនទាំងក្នុងនិងក្រៅប្រទេស ឱ្យចូលរួមក្នុងផលិតកម្មកសិកម្ម ពិសេសផលិតកម្មដំណាំកសិឧស្សាហកម្ម និងស្វាគមន៍ចំពោះការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល ដើម្បីបង្កើននិងធានាឱ្យបាននូវការផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗដល់កសិករក្នុងការដាំដុះនិងចិញ្ចឹមសត្វ។
- ផ្សារភ្ជាប់កសិករទៅនឹងសង្វាក់ផ្គត់ផ្គង់កសិផលទីផ្សារក្នុងស្រុក ដោយយកចិត្តទុកដាក់លើការអនុវត្តប្រព័ន្ធ "***ផលិតកម្មកសិកម្មតាមកិច្ចសន្យា***" និងជំរុញការឈានចូលទីផ្សារពិភពលោក តាមរយៈការខិតខំប្រឹងប្រែងលើកកម្ពស់គុណភាពកសិផល ឱ្យស្របតាមស្តង់ដារអន្តរជាតិ យកចិត្តទុកដាក់ដល់ការអនុវត្តល្អក្នុងផលិតកម្មកសិកម្ម និងការផ្ដល់សេវាព័ត៌មានទីផ្សារកសិកម្ម។
- ជំរុញបន្ថែមការអភិវឌ្ឍលើវិស័យចិញ្ចឹមសត្វគ្រប់ប្រភេទ ដោយសង្កត់លើការកែលំអពូជចំណីសត្វ បញ្ជ្រាបបច្ចេកវិជ្ជាទំនើប ក្នុងការចិញ្ចឹមសត្វដល់ស្រទាប់កសិករ និងឡជីវ

ឧស្ម័នក្នុងគោលដៅបង្កើនផលិតភាពសត្វទាំងបរិមាណនិងគុណភាព។ ពង្រឹងពង្រីកការងារត្រួតពិនិត្យ និងទប់ស្កាត់ការរីករាលដាលជំងឺឆ្លងពីសត្វទៅមនុស្ស និងពីមនុស្សទៅសត្វ ឬពីតំបន់មួយទៅតំបន់មួយទៀត តាមរយៈការបង្កើនកម្មវិធីយុទ្ធនាការចាក់ថ្នាំការពារសត្វ ជីវសុវត្ថិភាព ពង្រឹងសមត្ថភាពបន្ថែមដល់ភ្នាក់ងារសុខភាពសត្វភូមិ និងការពិនិត្យចលនាសត្វឱ្យបានត្រឹមត្រូវ។ ជំរុញការងារសុខភាពសាធារណៈ ដោយផ្តោតជាសំខាន់លើការគ្រប់គ្រងសត្តឃាតដ្ឋាន ការពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសាច់នៅតាមសត្តឃាតដ្ឋាននិងទីផ្សារ ក្នុងទិសដៅកាត់បន្ថយលុបបំបាត់ជំងឺឆ្លង តាមរយៈសាច់ និងផលិតផលសាច់ ដើម្បីធានាសុវត្ថិភាពចំណីអាហារដល់ប្រជាពលរដ្ឋ។

- ជំរុញការដាំដុះដំណាំកៅស៊ូតាមគ្រប់រូបភាព ទាំងការពង្រីកចម្ការកៅស៊ូមានស្រាប់ ចម្ការកៅស៊ូវិនិយោគឯកជន និងពិសេសបង្កើនផ្ទៃដីដាំដុះកៅស៊ូគ្រួសារ។ រៀបចំច្បាប់កៅស៊ូពាក់ពន្ធ័នឹងការដាំដុះ ការប្រមូលផល ការកែច្នៃ ការដឹកជញ្ជូន និងការនាំចេញ ជាពិសេសការធ្វើសហប្រតិបត្តិការ និងចូលរួមជាមួយបណ្តាវិទ្យាស្ថាន និងអង្គការកៅស៊ូអន្តរជាតិនានា ដើម្បីផ្លាស់ប្តូរបទពិសោធន៍បច្ចេកវិទ្យា និងចំណេះដឹងទូទៅលើការងារស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ ដោយជំរុញការចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូដល់បណ្តារោងចក្រផលិតជ័រកៅស៊ូ និងខិតខំកៀងគររកប្រភពទុនពីស្ថាប័នភ្នាក់ងារហិរញ្ញវត្ថុនិងដៃគូអភិវឌ្ឍន៍នានា ដើម្បីជំរុញការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារនៅទូទាំងប្រទេស។
- រៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីជាឧបករណ៍អនុវត្តការងារ និងឆ្លើយតបទៅនឹងនិន្នាការរីកចម្រើនរបស់វិស័យកសិកម្ម រួមមាន៖ ច្បាប់ស្តីពីការការពារដំណាំនិងភូតគាមអនាម័យ ច្បាប់ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ។ល។ រៀបចំគោលនយោបាយជាតិសម្រាប់អភិវឌ្ឍសហគមន៍កសិកម្ម គោលនយោបាយនិងយុទ្ធសាស្ត្រវិស័យផលិតកម្មនិងបសុព្យាបាល អនុក្រឹត្យស្តីពីការគ្រប់គ្រងរោងជាងផលិត កែច្នៃ តម្លើង និងរោងជាងជួសជុលគ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្ម អនុក្រឹត្យនិងប្រកាសពាក់ព័ន្ធនឹងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជ ប្រកាសរួមស្តីពីសោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យ និងការកម្ចាត់សមាសភាពចង្រៃ ប្រកាសស្តីពីការតែងតាំងនគរបាលយុត្តិធម៌សម្រាប់សមត្ថកិច្ចមន្ត្រីភូតគាមអនាម័យ វិសោធនកម្មលើប្រកាសស្តីពីការបង្កើតឯកសណ្ឋាន សញ្ញាសម្គាល់ និងត្រារបស់មន្ត្រីភូតគាមអនាម័យ ជាដើម។ល។
- ជំរុញការអភិវឌ្ឍធនធានមនុស្ស ដោយរៀបចំបណ្តុះបណ្តាលលើមុខជំនាញបច្ចេកទេសជលផល ដោយរួមទាំងអ្នកនេសាទ សហគមន៍នេសាទនិងកសិករចិញ្ចឹមត្រីផង និងបន្ត

ការងារសហប្រតិបត្តិការជាមួយអង្គការជាតិនិងអន្តរជាតិ ដើម្បីកិច្ចអភិវឌ្ឍវិស័យវារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផល។

- បង្កើនលែងប្រភេទពូជត្រីក្នុងស្រុកចូលតំបន់ទឹកធម្មជាតិឱ្យបានគ្រប់ស្រុក ដើម្បីបង្កើនផលស្តុកមច្ឆជាតិ បម្រើសេចក្តីត្រូវការរបស់ប្រជាកសិករ និងជំរុញការទាញយកផលពីធនធានទឹក តាមរយៈការពង្រីកតំបន់អភិវឌ្ឍន៍វារីវប្បកម្ម ជាពិសេសការចិញ្ចឹមត្រីក្នុងស្រែ។
- ជំរុញបង្កើនទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធនិងអង្គការនានា ដើម្បីគាំទ្រដល់ការរៀបចំគ្រប់គ្រងនិងអភិវឌ្ឍន៍សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី និងធ្វើការអភិរក្សផ្សោតទន្លេមេគង្គនៅខេត្តក្រចេះនិងស្ទឹងត្រែង ដោយសិក្សាស្រាវជ្រាវផ្សព្វផ្សាយ អភិវឌ្ឍន៍ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់។
- ខិតខំបន្តអនុវត្តអនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី **«ធ្វើឱ្យទីណាមានទឹក ទីនោះមានត្រីឡើងវិញ»** និងបង្កើនប្រព័ន្ធត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផលជលផល ជាពិសេស បង្កើនសកម្មភាពត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផលតាមបណ្តាខេត្តឱ្យកាន់តែកាន់ខ្លាំងក្លា។
- ពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ច ដោយធ្វើការផ្សព្វផ្សាយច្បាប់ បទបញ្ជា បទប្បញ្ញត្តិលិខិតបទដ្ឋានពាក់ព័ន្ធនិងវិស័យព្រៃឈើ ពិសេសច្បាប់ស្តីពីព្រៃឈើ ព្រមទាំងចាត់វិធានការស៊ើបអង្កេតស្រាវជ្រាវ ចុះល្បាតទប់ស្កាត់និងបង្ក្រាបបទល្មើសឱ្យបានទាន់ពេលវេលាទន្ទឹមនឹងការពង្រឹងវិន័យការងារចំពោះមន្ត្រីមានសមត្ថកិច្ច ដើម្បីបង្កើនប្រសិទ្ធភាពសេវាកម្មសាធារណៈ និងអភិបាលកិច្ចល្អនៃវិស័យព្រៃឈើ។
- រៀបចំធនធានមនុស្សនិងលិខិតបទដ្ឋានក្រោមច្បាប់ ដើម្បីអនុវត្តរចនាសម្ព័ន្ធរដ្ឋបាលព្រៃឈើតាមអនុក្រឹត្យកំណត់ និងបន្តសហការជាមួយស្ថាប័នពាក់ពន្ធ័ និងអាជ្ញាធរដែនដីចុះបោះបង្គោល ដើម្បីកំណត់ព្រំប្រទល់ដែនព្រៃឈើច្បាស់លាស់ និងអនុវត្តបន្តកម្មវិធីសហគមន៍ព្រៃឈើជាតិ ។
- ជំរុញការដាំព្រៃឈើសម្រាប់បម្រើដល់ពហុប្រយោជន៍នៃសេដ្ឋកិច្ចសង្គម និងសេវាបរិស្ថាន និងបណ្តុះកូនឈើចែកចាយជូនប្រជាពលរដ្ឋដាំឱ្យបាន១០លានដើមជារៀងរាល់ឆ្នាំ និងរៀបចំបុណ្យរុក្ខទិវាដាំដើមឈើ។ សហការជាមួយដៃគូអភិវឌ្ឍន៍រៀបចំបង្កើតប្រពន្ធ័គណនេយ្យឥណទានកាបូនព្រៃឈើ (Forest Carbon Accounting System) ព្រមទាំងពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើលើបញ្ហាថ្មីៗនៃឥណទានកាបូនព្រៃឈើ។

## ច. កម្មវិធីលម្អិតតាមវិស័យ និងអនុវិស័យ

ដើម្បីសំរេចគោលដៅចំបងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់យ៉ាងច្បាស់នូវកម្មវិធីចំនួន៥ និងបង្ហាញជាក់លាក់ទៅតាមអនុវិស័យនីមួយៗ នៅក្នុងការអភិវឌ្ឍវិស័យកសិកម្មមានដូចខាងក្រោម ៖

### ទិសដៅគោលនយោបាយទី១- "ធានាសន្តិសុខស្បៀង បង្កើនផលិតភាព និង ពិពិធកម្មកសិកម្ម"

### កម្មវិធីទី-១៖ បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម

១.១. បញ្ជ្រាបការប្រើប្រាស់ពូជដំណាំមានគុណភាពនិងផលិតភាពខ្ពស់

១.២. ជំរុញផលិតកម្មសត្វ ការត្រួតពិនិត្យអនាម័យសត្វ និងប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងសត្វ

១.៣. ជំរុញការស្រាវជ្រាវលើវិស័យផលិតកម្មនិងបសុព្យាបាល

១.៤. ការគ្រប់គ្រងកែលំអដីជាតិដីនិងការសិក្សាចំណាត់ថ្នាក់ដី សម្រាប់កំណត់តំបន់ដាំដុះ និងផែនការប្រើប្រាស់ដីធ្លី

១.៥. ពង្រឹងការយល់ដឹងអំពីការការពារដំណាំ និងការបង្កើនទិន្នផលដំណាំ ដោយប្រព័ន្ធគ្រប់គ្រងដំណាំចំរុះ

១.៦. ពង្រឹងការអភិវឌ្ឍនិងការប្រើប្រាស់គ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្ម

១.៧. ជំរុញការធ្វើប្រពលវប្បកម្មនិងពិពិធកម្មកសិកម្ម

១.៨. ធ្វើឱ្យប្រសើរឡើងបច្ចេកទេសក្រោយពេលប្រមូលផល

១.៩. ពង្រឹងសេវាកម្មអន្តរាគមន៍ក្នុងផលិតកម្មកសិកម្ម

១.១០. ពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តបម្រើឱ្យការស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្ទេរបច្ចេកវិទ្យា

១.១១. ពង្រឹងនិងជំរុញការស្រាវជ្រាវកសិកម្ម ដោយផ្តោតលើផលិតកម្មពូជដំណាំកសិកម្ម

១.១២. កែលំអនូវរចនាសម្ព័ន្ធតួនាទីភារកិច្ច និងពង្រឹងប្រសិទ្ធភាពប្រព័ន្ធផ្សព្វផ្សាយកសិកម្ម

១.១៣. បង្កើនសមត្ថភាពមន្ត្រីភ្នាក់ងារផ្សព្វផ្សាយកសិកម្មនិងអ្នកពាក់ព័ន្ធនានា តាមរយៈការអប់រំ ការបណ្តុះបណ្តាលពីវិធីសាស្ត្រផ្សព្វផ្សាយ

១.១៤. បង្កើនការផ្សព្វផ្សាយពីបច្ចេកទេសថ្មីៗទាក់ទងនឹងវិស័យផលិតកម្ម និងបសុព្យាបាលដើម្បីបង្កើនសមត្ថភាពយល់ដឹងនៅតាមមូលដ្ឋាន

១.១៥. ពង្រឹងសមត្ថភាពមន្ត្រីនិងប្រសិទ្ធភាពនៃការអនុវត្ត លើសេវាផលិតកម្មនិងបសុព្យាបាលសត្វ

១.១៦. សិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយពីបច្ចេកវិទ្យាក្រោយពេលប្រមូលផល ការកែច្នៃ និងទីផ្សារផលិតផលកសិកម្ម

១.១៧. សិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយអំពីសហគ្រាសកសិកម្ម និងកសិឧស្សាហកម្មនៅកម្ពុជា

១.១៨. ពង្រឹងនិងបង្កើនសមត្ថភាពដល់មន្ត្រីស្រាវជ្រាវ និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធនានា តាមរយៈ ផ្តល់វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា

១.១៩. អភិវឌ្ឍន៍និងពង្រឹងការគ្រប់គ្រងប្រពន្ធ័កសិកម្ម និងបទដ្ឋានអនុវត្តបច្ចេកវិទ្យាសម្រាប់ការចូលរួមកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាន

១.២០. ពង្រឹងនិងពង្រីកប្រសិទ្ធភាពការផ្សព្វផ្សាយព័ត៌មាន និងបច្ចេកវិទ្យាកសិកម្ម តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសាធារណៈ

១.២១. ជំរុញការផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់មន្ត្រីបច្ចេកទេស អ្នកផ្សព្វផ្សាយ កសិករ និងអ្នកពាក់ព័ន្ធនានា តាមរយៈការបោះពុម្ពផ្សាយ

១.២២. បង្កើនផលិតកម្មស្បៀងនិងប្រាក់ចំណូលគ្រួសារកសិករ តាមរយៈការអនុវត្តបច្ចេកទេសផ្សព្វផ្សាយកសិកម្មនៅជនបទ

១.២៣. ពង្រឹងការស្រាវជ្រាវនិងអភិវឌ្ឍន៍ពូជដំណាំ បច្ចេកទេសផលិតកម្មដំណាំ និងការការពារដំណាំ

១.២៤. ពង្រឹងការស្រាវជ្រាវបច្ចេកទេសគ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្ម

១.២៥. ជំរុញការផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់មន្ត្រីបច្ចេកទេស ភ្នាក់ងារផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធនានា តាមរយៈព័ត៌មានវិទ្យា

១.២៦. ជំរុញការត្រួតពិនិត្យនិងការគ្រប់គ្រងបមាណីសម្ភារកសិកម្ម

១.២៧. ជំរុញការដាំដុះកៅស៊ូគ្រួសារ (ជួយបង្កើនជីវភាពរស់នៅរបស់កសិករតូចតាច សំដៅកាត់បន្ថយភាពក្រីក្ររបស់ពួកគាត់ និងបង្កើនការងារនៅជនបទ ជៀសវាងការធ្វើចំណាកស្រុក)

១.២៨. ការសិក្សាអំពីលទ្ធភាពប្រើប្រាស់ដោយស្របច្បាប់នូវសក្តានុពលដីទំនេរ ដែលកប នឹងដំណាំកៅស៊ូ (សម្រួលដល់ការប្រើប្រាស់សក្តានុពលដីនៅក្នុងតំបន់ព្រៃរេចរិល ដីសម្បទានសេដ្ឋកិច្ចឬសង្គមកិច្ច ដល់កសិករឬសមាគមន៍)

១.២៩. ធានាគុណភាពនៃការដាំដុះកៅស៊ូ (លើកកម្ពស់គុណភាពចម្ការកៅស៊ូគ្រប់ផ្នែកឱ្យទទួលបាននូវទិន្នផលខ្ពស់ សំដៅបង្កើនប្រាក់ចំណូលដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិ និងការពារបរិស្ថានធម្មជាតិ)

## ទិសដៅគោលនយោបាយទី២-"ពង្រីកលទ្ធភាពនៃការចូលទីផ្សារសម្រាប់ផលិតផលកសិកម្ម"

### កម្មវិធីទី-២៖ ជំរុញការចូលទីផ្សារនៃផលិតផលកសិកម្ម

២.១. កែលំអគុណភាព និងចំណាត់ថ្នាក់ផលិតផលកសិកម្ម

២.២. ពង្រឹងសមត្ថភាព និងសេវាកម្មត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម

២.៣. បង្កើនការយល់ដឹងអំពីតម្រូវការ និងលក្ខណ្ឌទីផ្សារក្នុងស្រុក និងក្នុងរបបពាណិជ្ជកម្មពិភពលោកដល់អ្នកពាក់ព័ន្ធ

២.៤. ជំរុញនិងការឈានចូលដល់ប្រព័ន្ធទីផ្សារកសិកម្ម និងអភិវឌ្ឍន៍ទីផ្សារ

២.៥. លើកកម្ពស់សុវត្ថិភាពនៃផលិតផលកសិកម្ម និងតម្រូវការស្តង់ដារទីផ្សារ

២.៦. ជំរុញការនាំចេញសត្វ និងផលិតផលមានដើមកំណើតពីសត្វទៅទីផ្សារក្នុងតំបន់

២.៧. បង្កើនការយល់ដឹងអំពីបច្ចេកវិទ្យាក្រោយពេលប្រមូលផល ការកែច្នៃ ការកែលំអប្រព័ន្ធទីផ្សារ និងការកែលំអគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម

២.៨. ជំរុញខ្សែចង្វាក់តម្លៃកៅស៊ូឱ្យបានល្អ (ធ្វើឱ្យផលិតផលជ័រកៅស៊ូកម្ពុជាមានតម្លៃខ្ពស់នៅលើទីផ្សារអន្តរជាតិ ធ្វើឱ្យប្រតិបត្តិករកៅស៊ូទទួលបានចំណូលជាអតិបរិមា)

## ទិសដៅគោលនយោបាយទី៣-"ក្របខ័ណ្ឌនៃការអភិវឌ្ឍស្ថាប័ន និងបញ្ញត្តិច្បាប់"

### កម្មវិធីទី-៣៖ ពង្រឹងស្ថាប័ន ក្របខ័ណ្ឌច្បាប់ និងអភិវឌ្ឍន៍ធនធានមនុស្ស

៣.១. កសាងក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត និងកំណែទម្រង់រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ

៣.២. បង្កើតនិងពង្រីកហេដ្ឋារចនាសម្ព័នរូបវ័ន្ត និងលិខិតបទដ្ឋានច្បាប់ពាក់ពន្ធ័នានា ក្នុងការអភិវឌ្ឍសហគមន៍កសិកម្ម

៣.៣. លើកកម្ពស់ការអភិវឌ្ឍនិងពង្រឹងក្របខ័ណ្ឌច្បាប់ ពាក់ព័ន្ធនឹងផលិតកម្មសត្វ និងធាតុចូលកសិកម្ម

៣.៤. ជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានក្រោមច្បាប់ឱ្យមានប្រសិទ្ធភាព

៣.៥. ពង្រឹងសមត្ថភាពជំនាញ និងទេពកោសល្យដល់មន្ត្រីកសិកម្មពាក់ព័ន្ធគ្រប់ជាន់ថ្នាក់

៣.៦. លើកកម្ពស់ការយល់ដឹងអំពីយេនឌ័រក្នុងវិស័យកសិកម្ម

៣.៧. ការកសាងច្បាប់គ្រប់គ្រងគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មនិងអនុក្រឹត្យពាក់ព័ន្ធនានា ពិសេសជំរុញការអនុវត្តអនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា

៣.៨. ពង្រឹងសមត្ថភាពជំនាញរបស់មន្ទីរកសិកម្មរាជធានី ខេត្ត ស្តីពីការងារអភិវឌ្ឍន៍កសិឧស្សាហកម្ម

៣.៩. លើកកម្ពស់អភិវឌ្ឍន៍ និងពង្រឹងក្របខ័ណ្ឌច្បាប់ ពាក់ព័ន្ធនឹងការគ្រប់គ្រងថ្នាំ និងជីកសិកម្ម

៣.១០. ជំរុញចម្ការកៅស៊ូកសិឧស្សាហកម្ម ដើម្បីធ្វើជាស្នូលនៃការអភិវឌ្ឍចម្ការកៅស៊ូគ្រួសារ (ជួយឱ្យកសិករម្ចាស់កៅស៊ូគ្រួសារបានទទួលនូវផលប្រយោជន៍ពីក្រុមហ៊ុនចម្ការកៅ

ស្ទូកសិឧស្សាហកម្មនៅលើដីសម្បទានសេដ្ឋកិច្ចដោយរក្សានូវផលប្រយោជន៍ទៅវិញទៅមករវាងគូភាគីទាំងពីរ)

៣.១១. ពង្រឹងនិងកែលម្អតួនាទីដឹកនាំរបស់អគ្គនាយកដ្ឋានកៅស៊ូ ឲ្យទៅជាអង្គភាពសម្របសម្រួលមួយ (ជាអង្គភាពដឹកនាំដ៏មានថាមភាពដើម្បីឆ្លើយតបចំពោះរាល់តម្រូវការ និងការពេញចិត្តគ្រប់តួអង្គនៃផ្នែកកៅស៊ូ)

## ទិសដៅគោលនយោបាយទី៤-"កំណែទម្រង់ជលផល"

### កម្មវិធីទី-៤៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព

៤.១ ការគ្រប់គ្រងនិងអភិវឌ្ឍន៍សហាគមន៍នេសាទ

៤.២ កែទម្រង់ដែននេសាទ (ការបោះបង្គោលព្រំដែននេសាទ រក្សាផ្ទៃឡូត៍ដែលបានកាត់ចេញជូនសហាគមន៍ប្រើប្រាស់ និងការការពារព្រៃលិចទឹក)

៤.៣ ជំរុញការអភិវឌ្ឍវារីវប្បកម្ម

៤.៤ ផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងការបង្ក្រាបបទល្មើសជលផល

៤.៥ ការងារស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប

៤.៦ បង្កើនការយល់ដឹងការកែច្នៃផលផលិតផលជលផល និងបច្ចេកវិទ្យាក្រោយពេលប្រមូលផល

៤.៧ អភិរក្សនិងសិក្សាស្រាវជ្រាវដើម្បីបង្កើនផលស្តុកជលផល

៤.៨ ការរៀបចំផែនការខណ្ឌរដ្ឋបាលជលផល និងការគ្រប់គ្រងស្ថិតិជលផល

៤.៩ ការរៀបចំផែនការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យជលផល

## ទិសដៅគោលនយោបាយទី៥-"កំណែទម្រង់ព្រៃឈើ"

### កម្មវិធីទី-៥៖ ការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃ ប្រកបដោយនិរន្តរភាព

**៥.១. ការកំណត់ព្រំប្រទល់ព្រៃឈើ ការចាត់ថ្នាក់ និងការចុះបញ្ជិកា**

៥.១.១ ការកំណត់ព្រំប្រទល់ដែនព្រៃនិងការចុះបញ្ជិកា

៥.១.២ ការចាត់ថ្នាក់ព្រៃឈើតាមមុខងារ

**៥.២. អភិរក្ស និងអភិវឌ្ឍធនធានព្រៃឈើ និងជីវៈចម្រុះ**

៥.២.១. ផែនការសកម្មភាពគ្រប់គ្រងព្រៃឈើជាតិ

៥.២.២. ការអភិវឌ្ឍ និងអនុវត្តបច្ចេកទេសគ្រប់គ្រងព្រៃផ្តល់ផល

៥.២.៣. ពង្រឹងការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

៥.២.៤. ការអភិរក្ស និងអភិវឌ្ឍធនធានសេនេទិច និងប្រភពពូជ

៥.២.៥. ការដាំដុះដើមឈើ និងការអភិវឌ្ឍចំការព្រៃដាំ

៥.២.៦. ការអភិវឌ្ឍផលិតផលព្រៃឈើ និងពង្រីកទីផ្សារ

៥.២.៧.ការអភិវឌ្ឍបច្ចេកទេសកែច្នៃឈើ និងការកែច្នៃផល អនុផលព្រៃឈើ

៥.២.៨. ការអភិវឌ្ឍប្រព័ន្ធវិញ្ញាបនបត្រព្រៃឈើ

**៥.៣. ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច**

៥.៣.១.ការកែទម្រង់ច្បាប់និងរដ្ឋបាល

៥.៣.២.ពង្រឹងការអនុវត្តច្បាប់ និងការតាមដាននិងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ

**៥.៤. សហគមន៍ព្រៃឈើជាតិ**

៥.៤.១. ការកំណត់តំបន់សក្តានុពល និងការបង្កើតសហគមន៍ព្រៃឈើ

៥.៤.២. ការអភិវឌ្ឍសហគមន៍ព្រៃឈើនិងការបង្កើនជីវភាព

៥.៤.៣.ការផ្តល់សេវាគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ

**៥.៥. កសាងសមត្ថភាព និងការស្រាវជ្រាវ**

៥.៥.១. អភិវឌ្ឍស្ថាប័ននិងធនធានមនុស្ស

៥.៥.២. ការអប់រំនិងផ្សព្វផ្សាយសាធារណៈ

៥.៥.៣.ការអភិវឌ្ឍសមត្ថភាពសិក្សាស្រាវជ្រាវ

**៥.៦. ហិរញ្ញប្បទានដោយចីរភាពសម្រាប់វិស័យព្រៃឈើ**

៥.៦.១. ហិរញ្ញប្បទានផ្តល់ដោយរាជរដ្ឋាភិបាល

៥.៦.២. ចំណូលពីវិស័យព្រៃឈើជាតិ

៥.៦.៣.ចំណូលពីវិស័យឯកជន និងសហគមន៍ព្រៃឈើ

៥.៦.៤. ប្រភពហិរញ្ញប្បទានថ្មីនៃសេវាកម្មបរិស្ថានព្រៃឈើ និងឥណទានកាបូន

## ឆ. សកម្មភាពអាទិភាពរបស់ក្រសួង (២០០៩-២០១៣)

ដើម្បីសម្រេចទិសដៅគោលនយោបាយទាំង៥ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម កម្មវិធី អនុកម្មវិធី (ឬចង្កោមសកម្មភាព) និងសកម្មភាពលម្អិតត្រូវបានកំណត់ដូចខាងក្រោម៖

### ទិសដៅគោលនយោបាយទី១- “ធានាសន្តិសុខស្បៀង បង្កើនផលិតភាព និង ពិពិធកម្មកសិកម្ម”

### កម្មវិធីទី-១៖ បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម

#### ១.១. បញ្ជ្រាបការប្រើប្រាស់ពូជដំណាំមានគុណភាព និងផលិតភាពខ្ពស់

**សកម្មភាព៖**

១. ផលិតកម្មពូជស្រូវសុទ្ធល្អសម្រាប់ការបង្កើនផលិតផលស្រូវ

២. ផលិតកម្មពូជដំណាំសាកវប្បកម្មនិងដំណាំរួមផ្សំ

៣. ផលិតកម្មពូជដំណាំឧស្សាហកម្ម

៤. ការជំរុញការធ្វើប្រពលវប្បកម្ម និងពិពិធកម្មដំណាំជាលក្ខណៈគ្រួសារ នៅតាមតំបន់ដែលមានប្រភពទឹក

៥. ការផ្សព្វផ្សាយពូជដំណាំឧស្សាហកម្ម ដំណាំសាកវប្បកម្ម និងដំណាំរួមផ្សំ តាមរយៈចម្ការបង្ហាញក្នុងតំបន់ដែលមានលក្ខណៈកេ្សត្របរិស្ថានខុសគ្នា

៦. ការអប់រំផ្សព្វផ្សាយអំពីប្រព័ន្ធកសិកម្មចម្រុះ តាមរយៈពិពិធកម្មកសិកម្មដំណាំ

៧. ការបណ្តុះបណ្តាលអំពីការដាំដុះដំណាំសាកវប្បកម្ម និងដំណាំរួមផ្សំ

៨. បណ្តុះបណ្តាលគ្រូបង្គោលតាមខេត្ត អំពីបង្គុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ

៩. បណ្តុះបណ្តាលកសិករតាមខេត្តស្តីពីបង្គុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ

១០. ធ្វើស្រែបង្ហាញអំពីបង្គុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវតាមតំបន់ស្រោចស្រព

១១. បោះពុម្ពឯកសារបច្ចេកទេសស្តីពីផលិតកម្មគ្រាប់ពូជសុទ្ធល្អ និងពង្រីកការផ្សព្វផ្សាយ

១២. បណ្តុះបណ្តាលសហគមន៍កសិករស្តីពីផលិតកម្មគ្រាប់ពូជសុទ្ធល្អ

១៣. ចុះពិនិត្យនិងផ្តល់ជំនួយបច្ចេកទេសក្នុងការផលិតពូជសុទ្ធល្អនៅតាមសហគមន៍ និងក្រុមហ៊ុនដើម្បីចែកចាយធ្វើផលិតកម្ម

១៤. ចុះសិក្សានិងវាយតម្លៃបន្ថែមអំពីពូជស្រូវដែលឆ្លើយតបនឹងទីផ្សារ

១៥. រៀបចំសិក្ខាសាលាផ្សព្វផ្សាយបច្ចេកទេសប្រចាំឆ្នាំដើម្បីចែករំលែកបទពិសោធន៍ល្អៗ

១៦. រៀបចំទស្សនកិច្ចសិក្សាក្នុងប្រទេសដល់កសិករដើម្បីផ្លាស់ប្តូរបទពិសោន៍ល្អៗ

១៧. រៀបចំកែសម្រួល និងបោះពុម្ពឯកសារស្តីពីបង្គុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវរបស់ CARDI ឱ្យស្របតាមសមត្ថភាពរបស់គ្រូបង្គោល

១៨. ផលិតគ្រាប់ពូជសុទ្ធអនុញ្ញាតនៅតាមស្ថានីយ៍លើកដំបូងលើផ្ទៃដី៥០ហិកតា

១៩. ផលិតគ្រាប់ពូជសុទ្ធល្អនៅតាមស្ថានីយ៍ និងសហគមន៍កសិករលើផ្ទៃដី៩៥០ហិកតា

២០. រៀបចំគោលការណ៍ យន្តការ និងឯកសារវាយតម្លៃ និងបញ្ជាក់គុណភាពគ្រាប់ពូជស្រូវ

២១. ផ្តល់ឥណទានស្រូវពូជមានគុណភាពខ្ពស់ប្រចាំឆ្នាំ សម្រាប់ត្រៀមបម្រុងការស្តារការខូចខាតដោយគ្រោះធម្មជាតិ ទឹកជំនន់ និងគ្រោះរាំងស្ងួតតាមបណ្តារាជធានី ខេត្ត

២២. ផ្តល់ស្រូវពូជត្រៀមអន្តរាគមន៍សង្គ្រោះបន្ទាន់ប្រចាំឆ្នាំ សម្រាប់ការស្តារការខូចខាតដោយគ្រោះធម្មជាតិ ទឹកជំនន់ និងគ្រោះរាំងស្ងួតតាមបណ្តារាជធានី ខេត្ត

២៣. សាងសង់ឃ្លាំងសម្រាប់ស្តុកស្រូវពូជតាមស្តង់ដារបច្ចេកទេសត្រឹមត្រូវ នៅតាមបណ្តាមន្ទីរកសិកម្ម រាជធានី ខេត្ត ទាំង១៧ ដើម្បីរក្សាគុណភាពដំណុះស្រូវពូជ និងធានាបរិមាណស្រូវពូជ

២៤. រៀបចំធ្វើជំរឿនកសិកម្មជាតិ ដោយរួមសហការជាមួយក្រសួងផែនការ អង្គការ FAO និងដៃគូអភិវឌ្ឍន៍ដទៃទៀត

២៥. រៀបចំកសាងផែនទីដាំដុះដំណាំទូទាំងប្រទេស ដោយត្រូវធ្វើសម្ភាសន៍ ប្រមូល កែច្នៃ និងវិភាគទិន្នន័យដែលប្រមូលបាន ចងក្រងជារបាយការណ៍និងផ្សព្វផ្សាយ។

### ១.២. ជំរុញផលិតកម្មសត្វ ការត្រួតពិនិត្យអនាម័យសត្វ និងប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងសត្វ

**សកម្មភាពៈ**

១. គ្រប់គ្រងការចិញ្ចឹមសត្វ និងការចិញ្ចឹមសត្វបង្ហាញគ្រប់ប្រភេទ ស្របតាមលក្ខណៈបច្ចេកទេស ដោយធ្វើការកែលំអពូជសត្វ ជីវសុវត្ថិភាព និងចំណីសត្វ

២. វិធានការចាក់ថ្នាំការពារជំងឺឆ្លងសត្វ និងព្យាបាលជំងឺសត្វ (គោ ក្របី និងជ្រូក)

៣. ពង្រឹងវិធានការ និងប្រសិទ្ធភាពនៃការអនុវត្តលើការត្រួតពិនិត្យចលនាសត្វ និងទប់ស្កាត់ជំងឺឆ្លងសត្វសំខាន់ៗ និងការចម្លងរាតត្បាតពីសត្វទៅមនុស្ស

៤. ពង្រឹងការគ្រប់គ្រងសេវាបសុព្យាបាលនៅតាមមូលដ្ឋាន ដោយជំរុញការលើកទឹកចិត្តដល់ភ្នាក់ងារសុខភាពសត្វភូមិ ទាំងបច្ចេកទេសនិងសម្ភារក្នុងការចូលរួមបំរើការងារសេវាបសុពេទ្យ

៥. បង្កើនវិធានការនិងប្រសិទ្ធភាពនៃការអនុវត្ត លើការត្រួតពិនិត្យអនាម័យសត្វសាច់ និងផលិតផលសត្វ និងទប់ស្កាត់ជំងឺឆ្លងសត្វនៅតាមទីសត្តឃាតដ្ឋាន

៦. ពង្រឹងការអភិវឌ្ឍស្ថានីយ៍ពិសោធន៍ពូជគោ និងពូជជ្រូកនៅស្ថានីយទាំងពីរ

៧. តាមដានឃ្លាំមើលជំងឺនៅតាមកសិដ្ឋានចិញ្ចឹមសត្វនិងនៅលើទីផ្សារ នៅតាមបណ្តារាជធានី ខេត្ត

៨. ធ្វើជំរឿនសត្វ និងការធ្វើស្ថិតិសត្វនៅរាជធានី ខេត្តទូទាំងប្រទេស

## ១.៣. ជំរុញការស្រាវជ្រាវលើវិស័យផលិតកម្ម និងបសុព្យាបាល

**សកម្មភាពៈ**

១. សិក្សាស្រាវជ្រាវ និងកំណត់តំបន់ជំងឺឆ្លងសត្វនៅទូទាំងប្រទេស

២. សិក្សាស្រាវជ្រាវ និងវិភាគពីជំងឺឆ្លងសត្វសំខាន់ៗ ការរាតត្បាតជំងឺឆ្លងសត្វ វិធានការទប់ស្កាត់ និងលុបបំបាត់ជំងឺឆ្លងសត្វ

៣. ការសិក្សាស្រាវជ្រាវនិងវិភាគពីគុណភាពអនាម័យ សុវត្ថិភាពសាច់ និងផលិតផលសាច់នៅតាមសត្តឃាតដ្ឋាន និងទីផ្សារ

៤. ការស្រាវជ្រាវលើធនធានពូជសត្វ និងសេនេទិកសត្វនៅកម្ពុជា

៥. សិក្សាពីចំណីសត្វសម្រាប់ជំរុញផលិតកម្មសត្វនៅកម្ពុជាឱ្យមានសន្ទុះកាន់តែប្រសើរ

៦. សិក្សាស្រាវជ្រាវពីស្ថិតិសត្វ ទិន្នផលសត្វ ការផ្គត់ផ្គង់ និងតម្រូវការសត្វក្នុងស្រុក

## ១.៤. ការគ្រប់គ្រងកែលំអជីជាតិដី និងការសិក្សាចំណាត់ថ្នាក់ដីសំរាប់កំណត់តំបន់ដាំដុះ និងផែនការប្រើប្រាស់ដី

**សកម្មភាពៈ**

១. ការអប់រំផ្សព្វផ្សាយអំពីការសន្សំការផលិត និងការប្រើប្រាស់ជីកំប៉ុស្ត៍

២. ការអប់រំផ្សព្វផ្សាយអំពីប្រសិទ្ធភាពជីធម្មជាតិលាយជីគីមី

៣. និរន្តភាពនៃការគ្រប់គ្រងជីជាតិ និងដំណាំក្នុងក្របខ័ណ្ឌប្រព័ន្ធកសិកម្មខ្នាតតូច

៤. ការសិក្សាលើការប្រើប្រាស់ដីកសិកម្ម

៥. ការកំណត់តំបន់ដាំដុះតាមគោលការណ៍ភូមិមួយផលិតផលមួយ

៦. ចាត់ថ្នាក់និងវាយតម្លៃភាពសមស្របនៃដីសម្រាប់ដំណាំកសិកម្មតាមរយៈ:

-សិក្សាស្រាវជ្រាវមូលដ្ឋាន ក្នុងការប្រមូលផ្តុំទិន្នន័យដែលមានកន្លងមក ពាក់ពន្ធ័នឹងការវាយតម្លៃប្រភេទដីសម្រាប់ដំណាំកសិកម្ម ព្រមទាំងផ្ទៀងផ្ទាត់តាមរយៈចុះអង្កេតផ្ទាល់ដល់ទីវាលជាក់ស្តែងដើម្បីរៀបចំគូរព្រំប្រទល់ដី

-ចុះសិក្សាអង្កេតនិងវាយតម្លៃពីលក្ខណៈរបស់ដី និងសក្តានុពលរបស់ដី ដើម្បីកំណត់ចំណាត់ដី និងបង្កើតផែនទីដីបឋម ឈានទៅកសាងផែនការប្រើប្រាស់ដីកសិកម្មប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនៅតំបន់គោលដៅ១៣ខេត្ត

៧. ពង្រឹងសមត្ថភាពនិងបញ្ជ្រាបការប្រើប្រាស់ដី និងសម្ភារកសិកម្មសម្រាប់ដំណាំស្រូវ

៨. ចាត់ថ្នាក់និងវាយតម្លៃភាពសមស្របនៃដី

៩. កំណត់តំបន់ប្រើប្រាស់ដីកសិកម្មនៅខេត្តកំពង់ធំ សៀមរាប កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពង់ស្ពឺ តាកែវ កណ្តាល ព្រៃវែង ស្វាយរៀង កំពង់ចាម បន្ទាយមានជ័យ និងឧត្តរមានជ័យ

១០. រៀបចំធ្វើចំណាត់ថ្នាក់តំបន់ប្រើប្រាស់ដីកសិកម្មរបស់ក្រុមហ៊ុនវិនិយោគឯកជន ចំនួន ៩៥ ក្រុមហ៊ុន ក្នុងខេត្តចំនួន១៧

១១. វាយតម្លៃនិន្នាការជីជាតិដីរយៈពេលវែងសម្រាប់ផលិតកម្មដំណាំស្រូវដែលប្រើជីខនិជ ឬជីសរីរាង្គក្នុងលក្ខខណ្ឌដីខ្សាច់នៃតំបន់ទំនាប

១២. ការគ្រប់គ្រងថែទាំនិងការអភិវឌ្ឍមន្ទីរពិសោធន៍ដី រុក្ខជាតិ និងទឹក

១៣. ការសិក្សាពីតម្រូវការ និងគុណភាពទឹកសម្រាប់ផលិតកម្មដំណាំស្ម្យៀង។

១៤. បង្កើនផលិតភាពដីតំបន់ទំនាបសម្រាប់ផលិតកម្មដំណាំស្រូវ ប្រកបដោយនិរន្តរភាព សេដ្ឋកិច្ច និងបរិស្ថាន

១៥. បង្កើនផលិតភាពដីតំបន់ខ្ពង់រាបសម្រាប់ផលិតកម្មដំណាំចម្ការ និងបន្លែប្រកបដោយ និរន្តរភាពសេដ្ឋកិច្ចនិងបរិស្ថាន

## ១.៥. ពង្រឹងការយល់ដឹងអំពីការការពារដំណាំ និងការបង្កើនទិន្នផលដំណាំដោយប្រព័ន្ធគ្រប់គ្រងដំណាំចម្រុះ

**សកម្មភាពៈ**

១. ការអប់រំផ្សព្វផ្សាយអំពីវិធានការកម្ចាត់សត្វល្អិតចង្រៃលើដំណាំបន្លែ

២. ការអប់រំផ្សព្វផ្សាយអំពីការអនុវត្តល្អក្នុងការងារកសិកម្ម ដើម្បីគុណភាពផលិតផល និងសុវត្ថិភាពចំណីអាហារ

៣. ការអប់រំផ្សព្វផ្សាយអំពីសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំកសិកម្ម

៤. ការអប់រំផ្សព្វផ្សាយអំពីការប្រើប្រាស់ថ្នាំកម្ចាត់សត្វល្អិតផ្សំពីរុក្ខជាតិលើដំណាំ

៥. ការអប់រំផ្សព្វផ្សាយអំពីវិធានការកម្ចាត់ខ្យងមាសបំផ្លាញដំណាំស្រូវ

៦. ការអប់រំផ្សព្វផ្សាយអំពីវិធានការកម្ចាត់មមាចត្នោតលើដំណាំស្រូវ

៧. រៀបចំចងក្រង និងបោះពុម្ពផ្សព្វផ្សាយអត្ថបទបច្ចេកទេស ស្តីពីសមាសភាពចង្រៃ (សត្វល្អិតចង្រៃ ជំងឺ និងស្មៅចង្រៃ) លើដំណាំស្រូវ និងថ្នាំកសិកម្ម និងការប្រើប្រាស់

៨. សិក្សាពីប្រភេទសត្វល្អិតចង្រៃលើដំណាំស្រូវនៅក្នុងប្រទេសកម្ពុជា រៀបចំបញ្ជីឈ្មោះសត្វល្អិតចង្រៃ ដើម្បីឆ្លើយតបការតម្រូវរបស់ភាគីពាក់ព័ន្ធ រៀបចំចងក្រងនិងផ្សព្វផ្សាយអត្ថបទបច្ចេកទេសស្តីពីសមាសភាពចង្រៃ ភូតគាមអនាម័យលើដំណាំស្រូវ

៩. ពង្រឹងសមត្ថភាពដោយបំពាក់សម្ភារបច្ចេកទេស ដើម្បីជំរុញការអនុវត្តការងារធូបទកម្ម (Fumigation) លើផលិតផលស្តុក និងសម្ភារវេចខ្ចប់ពីឈើ ស្របតាមស្តង់ដារអន្តរជាតិ

១០. កំណត់តំបន់គ្មានសមាសភាពចង្រៃលើដំណាំស្រូវ ដើម្បីសម្របសម្រួលការធ្វើពាណិជ្ជកម្មអង្ករទៅកាន់ទីផ្សារអន្តរជាតិ

១១. រៀបចំតំបន់គ្មានសមាសភាពចង្រៃសំរាប់ផលិតកម្មដំណាំស្រូវ ដើម្បីនាំចេញទៅតាមតម្រូវការរបស់ប្រទេសនាំចូល ដោយផ្អែកលើស្តង់ដារអន្តរជាតិស្តីពីវិធានភូតគាមអនាម័យ

១២. សិក្សាអំពីសត្វល្អិត និងពិសោធន៍តាមដានរកពូជ ដែលធន់ទៅនឹងការបំផ្លាញរបស់សត្វល្អិត (មមាចត្នោត) នៅក្នុងលក្ខខណ្ឌស្រែទំនាបពឹងផ្អែកទឹកភ្លៀង។

១៣. សម្ងហាកម្មសត្វល្អិត និងជំងឺលើដំណាំបន្លែ និង ធញ្ញជាតិ

១៤. សិក្សាស្រាវជ្រាវពីវិធីសាស្ត្រដាំដុះ និងវប្បកម្មដំណាំផ្សិត

១៥. សិក្សាស្រាវជ្រាវអំពីថ្នាំកសិកម្មធម្មជាតិ សម្រាប់ដំណាំស្រូវ និងបន្លែមួយចំនួន

១៦. ពិសោធន៍តាមដានលើថ្នាំកសិកម្មអសរីរាង្គ ដែលមានបទដ្ឋានត្រឹមត្រូវ និងមានប្រសិទ្ធភាពក្នុងផលិតកម្មដំណាំស្រូវ និងបន្លែមួយចំនួន

## ១.៦. ពង្រឹងការអភិវឌ្ឍ និងការប្រើប្រាស់គ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម

**សកម្មភាពៈ**

១. រៀបចំបញ្ជីឈ្មោះគ្រឿងយន្តកសិកម្មដើម្បីសម្របសម្រួលការនាំចូល

២. ការផលិតនិងសាកពិសោធន៍ឧបករណ៍និងគ្រឿងយន្ត សម្រាប់រៀបចំដីដាំដុះ ប្រមូលផល កែច្នៃផលិតផល

៣. ការបណ្តុះបណ្តាលបច្ចេកទេសគ្រឿងយន្តកសិកម្ម

៤. ការធ្វើបង្ហាញអំពីប្រសិទ្ធភាពឧបករណ៍ និងគ្រឿងយន្តកសិកម្ម ដែលបានផលិត

៥. ការអនុវត្តបង្ហាញធ្វើស្រែប្រពលវប្បកម្ម ដោយបញ្ចូលបច្ចេកវិទ្យាគ្រឿងយន្តកសិកម្មខ្នាតតូច

## ១.៧. ជំរុញការធ្វើប្រពលវប្បកម្ម និងពិពិធកម្មកសិកម្ម

**សកម្មភាពៈ**

១. ការបណ្តុះបណ្តាលពីការធ្វើប្រពលវប្បកម្មដំណាំស្រូវ និងការធ្វើបង្ហាញ

២. ការបណ្តុះបណ្តាលពីប្រពលវប្បកម្មដំណាំផ្សេងៗ (ដំណាំរួមផ្សំ បន្លែ ឈើហូបផ្លែ រុក្ខជាតិលំអ ដំណាំឧស្សាហកម្ម)

៣. ការធ្វើបង្ហាញប្រពន្ធ័កសិកម្មដំណាំស្រូវ

៤. ការពង្រីកការអនុវត្តប្រព័ន្ធកសិកម្មចម្រុះខ្នាតតូចដើម្បីកែលំអស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងគ្រួសារក្រីក្រ

៥. ការជំរុញការធ្វើប្រពលវប្បកម្ម និងពិពិធកម្មកសិកម្មតាមប្រព័ន្ធធារាសាស្ត្រ

៦. ការបណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវដល់កសិករ

៧. ធ្វើការអង្កេតសេដ្ឋកិច្ចគ្រួសារមុននិងក្រោយធ្វើវិនិយោគ ប្រព័ន្ធធារាសាស្ត្រដើម្បីប្រៀបធៀបការរីកចម្រើនរបស់កសិករក្នុងតំបន់កសាងប្រពន្ធ័ធារាសាស្ត្រ

### ១.៨. ធ្វើឱ្យប្រសើរឡើងបច្ចេកទេសក្រោយពេលប្រមូលផល

**សកម្មភាពៈ**

១. ការបណ្តុះបណ្តាលបច្ចេកទេសក្រោយពេលប្រមូលសម្រាប់គ្រប់ប្រភេទដំណាំ

២. ការរៀបចំបុណ្យដារលាន ដើម្បីលើកកម្ពស់និងថែរក្សាទំនៀមទម្លាប់ប្រពៃណីបុរាណ និងបញ្ជ្រាបបច្ចេកទេសក្រោយពេលប្រមូលផលដល់កសិករ

### ១.៩. ពង្រឹងសេវាកម្មអន្តរាគមន៍

**សកម្មភាពៈ**

១. ការអន្តរាគមន៍ពូជដំណាំ

២. ការអន្តរាគមន៍ជីគីមីនិងថ្នាំកសិកម្ម

៣. ការអន្តរាគមន៍ស្រោចស្រព

៤. ការអន្តរាគមន៍ភ្ជួររាស់

៥. ការអន្តរាគមន៍ប្រមូលផលស្រូវ

៦. ការអន្តរាគមន៍អនុត្តរភាពប្រព័ន្ធធារាសាស្ត្រខ្នាតតូច

៧. បង្កើតគ្លីនិកដំណាំចល័តដែលអាចឱ្យកសិករបង្កើនសមត្ថភាពប្រើប្រាស់ពូជ

៨. បង្កើតគ្លីនីកចល័តសត្វធំ

៩. បង្កើតគ្លីនិកចល័តសម្រាប់សត្វតូច

### ១.១០. ពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បម្រើឱ្យការស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្ទេរបច្ចេកវិទ្យា

**សកម្មភាពៈ**

១. កសាងនិងស្តារឡើងវិញបណ្តាកសិដ្ឋានស្ថានីយ៍ស្រាវជ្រាវ និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម

២. ស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សព្វផ្សាយកសិកម្មៈ មណ្ឌលបណ្តុះបណ្តាលនិងអភិវឌ្ឍន៍កសិកម្ម ការិយាល័យកសិកម្មស្រុក និងមណ្ឌលផ្សព្វផ្សាយកសិកម្មឃុំ

៣. ជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ស្ថានីយ៍កសិដ្ឋាន និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម

៤. បំពាក់ឧបករណ៍និងបរិក្ខាចាំបាច់សម្រាប់គាំទ្រការស្រាវជ្រាវ និងផ្ទេរបច្ចេកវិជ្ជាផលិតកម្មដំណាំស្រូវនៅតាមស្ថានីយ៍ កសិដ្ឋាន និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម

៥. ជួសជុលនិងសាងសង់មជ្ឈមណ្ឌលសម្រាប់បណ្តុះបណ្តាលមន្រ្តីជំនាញ អ្នកផ្សព្វផ្សាយ និងកសិករនៅស្ថានីយ៍ កសិដ្ឋាន និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម
៦. ផលិតគ្រាប់ពូជសុទ្ធអនុញ្ញាតនៅស្ថានីយ៍កសិដ្ឋាន និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម
៧. ធ្វើពិសោធន៍ស្រាវជ្រាវច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវនៅស្ថានីយ៍ កសិដ្ឋាន និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម
៨. បណ្តុះបណ្តាលកសិករអំពីច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ
៩. ការធ្វើស្រែបង្ហាញអំពីបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវតាមសហគមន៍
១០. ការបណ្តុះបណ្តាលកសិករអំពីផលិតកម្មពូជសុទ្ធល្អនៅតាមសហគមន៍អភិវឌ្ឍន៍កសិកម្ម
១១. រៀបចំទស្សនកិច្ចសិក្សាក្រៅប្រទេសសម្រាប់មន្រ្តីបច្ចេកទេស និងកសិករដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងទទួលបានចំណេះដឹងចំណេះធ្វើថ្មីៗ
១២. ផលិតឧបករណ៍កសិកម្ម និងគ្រឿងយន្តកសិកម្មសាកពិសោធន៍ សម្រាប់ការរៀបចំដីដាំដុះ
១៣. ការធ្វើបង្ហាញ និងប្រសិទ្ធភាពឧបករណ៍ និងគ្រឿងយន្តកសិកម្មដែលបានផលិតដើម្បីផ្តល់ក្នុងការប្រើប្រាស់ឧបករណ៍ និងគ្រឿងយន្តកសិកម្ម សំដៅបង្កើនផលិតភាពប្រពលវប្បកម្មដំណាំស្រូវ
១៤. បើកវគ្គបណ្តុះបណ្តាលបច្ចេកវិទ្យាក្រោយពេលប្រមូលផលស្រូវ
១៥. បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសស្តីពីការថែទាំជួសជុលគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម
១៦. ត្រៀមថ្នាំកសិកម្មនិងឧបករណ៍សម្រាប់អន្តរាគមន៍បន្ទាន់ កម្ចាត់សមាសភាពចង្រៃនៅពេលមានការផ្ទុះឡើងការបំផ្លាញលើដំណាំស្រូវ
១៧. សិក្សានិងរៀបចំផែនការលម្អិត ដើម្បីពង្រឹងនិងពង្រីកកសិដ្ឋាន ស្ថានីយ៍ និងមណ្ឌលអភិវឌ្ឍន៍សម្រាប់ផលិតកម្មពូជស្រូវ
១៨. ជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាជំហានដំបូង នៅកសិដ្ឋានផលិតពូជស្រូវទួលសំរោង ដើម្បីគាំទ្រដល់ការផលិតពូជ
១៩. រៀបចំកែលំអឯកសារ និងផែនការពិសោធន៍ស្រាវជ្រាវបន្សាំតាមប្រភេទប្រពន្ធ័ក្សេត្របរិស្ថានផ្សេងៗ
២០. កំណត់តំបន់ផលិតកម្មស្រូវដែលមានប្រភពទឹក និងប្រពន្ធ័ធារាសាស្រ្ត
២១. ត្រៀមថ្នាំកសិកម្មនិងឧបករណ៍សម្រាប់អន្តរាគមន៍បន្ទាន់ ក្នុងការកំចាត់សមាសភាពចង្រៃនៅពេលមានការផ្ទុះឡើងការបំផ្លាញ ដើម្បីធានាថាគ្មានការបាត់បង់ទិន្នផល បើទោះបីមានការបំផ្លាញក៏ដោយ

## ១.១១. ពង្រឹងនិងជំរុញការស្រាវជ្រាវកសិកម្ម ដោយផ្តោតលើផលិតកម្មពូជដំណាំកសិកម្ម

**សកម្មភាព៖**

១. បសិដ្ឋកម្មពូជ ទិន្នផល និងគុណភាពដំណាំធញ្ញជាតិ ។ សិក្សាស្រាវជ្រាវរកពូជស្រូវដែលធន់ទ្រាំនឹងទឹកជំនន់និងទឹកប្រៃ

២. បសិដ្ឋកម្មពូជ ទិន្នផល និងគុណភាព ដំណាំផ្តល់ ផ្លែផ្តល់មើម និងដាំណាំវាយនភ័ណ្ឌ និងជាលិការវប្បកម្មដំណាំ

៣. បសិដ្ឋកម្មទិន្នផល និងគុណភាព ដំណាំបន្លែ និងរុក្ខជាតិលម្អ

៤. សម្ងួហកម្ម និងអភិរក្សពន្ធុនៃរុក្ខជាតិសម្រាប់ស្បៀងនិងកសិកម្ម

៥. អភិវឌ្ឍន៍ឧបករណ៍ញែកគ្រាប់អង្ករនិងគ្រាប់ស្រូវ

៦. អភិវឌ្ឍន៍ឧបករណ៍សម្ងួតគ្រាប់ស្រូវដោយចង្ក្រានដុតអង្កាម

៧. សិក្សាពីប្រសិទ្ធភាពនៃឡសម្ងួត និងការបាត់បង់បរិមាណនិងគុណភាពគ្រាប់ស្រូវ នៅក្នុងសហគមន៍កសិករ ដែលធ្វើផលិតកម្មស្រូវបង្កើនរដូវ

៨. វិធីសាស្ត្ររៀបចំដីប្រកបដោយនិរន្តរភាព សម្រាប់ផលិតកម្មដំណាំស្រូវប្រដេញទឹក

៩. សិក្សាវាយតម្លៃពីឧបករណ៍ និងម៉ាស៊ីនកសិកម្មកំពុងប្រើប្រាស់ និងធ្វើការអភិវឌ្ឍឧបករណ៍ និងម៉ាស៊ីនសមស្របសម្រាប់សេដ្ឋកិច្ច និងលក្ខខណ្ឌក្នុងប្រទេសកម្ពុជា

១០. អភិវឌ្ឍន៍បរិក្ខារទុកដាក់ ឬសម្រាប់វេចខ្ចប់ផ្លែឈើនិងបន្លែ

១១. ជំរុញប្រព័ន្ធកសិកម្មគំរូ សំដៅបង្កើតបាននូវប្រព័ន្ធកសិកម្មគំរូមួយ ដែលសមស្របក្នុងការជួយកសិករផលិតបានអាហារគ្រប់គ្រាន់ សម្រាប់តម្រូវការហូបចុកប្រចាំគ្រួសារ និងសល់អាចលក់ទៅទីផ្សារ ដើម្បីជាប្រភពប្រាក់ចំណូលគ្រួសារបន្ថែមបន្ទាប់ពីដំណាំស្រូវ តាមរយៈការលក់ផលិតផលក្នុងកសិដ្ឋាន។

១២. អភិវឌ្ឍន៍បង្ហុំបច្ចេកវិទ្យាសម្រាប់ប្រព័ន្ធដាំដុះដំណាំកសិកម្ម

១៣. កំណត់ប្រភេទពូជស្រូវសំខាន់ៗមួយចំនួន ដែលសមស្របសម្រាប់ប្រព័ន្ធក្សេត្របរិស្ថានដំណាំស្រូវ មានសក្តានុពលទិន្នផលខ្ពស់ និងមានគុណភាពស្របតាមតម្រូវការទីផ្សារជាតិនិងអន្តរជាតិ

១៤. សិក្ខាសាលាពិគ្រោះយោបល់លើប្រភេទពូជស្រូវមួយចំនួន ជាមួយវិស័យឯកជន និងអ្នកពាក់ព័ន្ធ

១៥. ចងក្រងនិងបោះពុម្ពសៀវភៅស្តីអំពីលក្ខណៈពូជស្រូវ ដែលបានកំណត់រួមទាំងវិធីសាស្ត្រសម្រិតសម្រាំងពូជស្រូវតាមបែបកសិករ ការកំណត់ក្រុមដី និងកម្រិតប្រើប្រាស់ដី និងលក្ខខណ្ឌក្សេត្របរិស្ថានដំណាំស្រូវ និងចែកចាយជូនអង្គភាពជំនាញរបស់ក្រសួង មន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្មស្រុក ក្រុមប្រឹក្សាឃុំ ក្រុមហ៊ុនឯកជន និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ

១៦. ចងក្រង និងបោះពុម្ពផ្សព្វផ្សាយសៀវភៅបង្គុំបច្ចេកទេស បង្កើនផលិតភាពដំណាំស្រូវ (Technology Package for Increased Rice Productivity = TPIRP) សម្រាប់ប្រភេទឬក្រុមនៃពូជស្រូវ ដែលបានកំណត់ឱ្យប្រើប្រាស់ និងចែកជូនអង្គភាពជំនាញរបស់ក្រសួង មន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្មស្រុក ក្រុមប្រឹក្សាឃុំ ក្រុមហ៊ុនឯកជន និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ

១៧. បើកវគ្គបណ្តុះបណ្តាលគ្រូជំនាញ (Master trainers) ចំនួន០២វគ្គ (១) លក្ខណៈសំខាន់ៗរបស់ពូជស្រូវទាំង១០ (២) វិធីសាស្ត្រសម្រិតសម្រាំងពូជស្រូវតាមបែបកសិករ (៣) ការកំណត់ក្រុមដីនិងកម្រិតប្រើប្រាស់ជី (៤) លក្ខខណ្ឌកេ្សត្របរិស្ថានដំណាំស្រូវ និង (៥) បង្គុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ ដើម្បីឲ្យមន្ត្រីទាំងនោះក្លាយជាគ្រូជំនាញសម្រាប់បណ្តុះបណ្តាលគ្រូបង្គោលបន្តទៀត

១៨. ផលិតគ្រាប់ពូជសុទ្ធគ្រឹះរបស់ពូជស្រូវដែលបានកំណត់ចំនួន៥ហិកតា តាមរយៈគម្រោងពីដៃគូអភិវឌ្ឍន៍ និង ២ ហិកតា តាមរយៈ ថវិការដ្ឋាភិបាលសម្រាប់ចែកចាយជូនកសិករ និងផ្គត់ផ្គង់ជូនអតិថិជនប្រើប្រាស់

១៩. ផលិតគ្រាប់ពូជសុទ្ធទទួលស្គាល់ របស់ពូជស្រូវដែលបានកំណត់លើផ្ទៃដីចំនួន០៥ហិកតា សម្រាប់ចែកចាយនិងផ្គត់ផ្គង់ជូនអតិថិជនប្រើប្រាស់

២០. បំពាក់ឧបករណ៍កសិកម្មតាមរយៈគម្រោងពីដៃគូអភិវឌ្ឍន៍នានា នូវត្រាក់ទ័រចំនួន០១គ្រឿង និង minicombined harvester ចំនួន០១គ្រឿង និងគម្រោងស្រោចស្រពនិងបង្កើនផលិតភាពកសិកម្មខេត្តភាគខាងកើតនូវត្រាក់ទ័រចំនួន០៣គ្រឿង និងគ្រឿងបរិក្ខារភ្ជួររាស់ចំនួន០៣សម្រាប់ រួមទាំងម៉ាស៊ីនបោកស្រូវចំនួន០១គ្រឿង និងម៉ាស៊ីនបូមទឹកដើរដោយចរន្តអគ្គីសនី ពោងនិងបណ្តាញខ្សែភ្លើង ត្រូវបានបំពាក់នៅស្រះទឹកចំនួន០៤នៅក្នុងវិទ្យាស្ថានកាឌី

២១. បំពាក់ឧបករណ៍មន្ទីរពិសោធន៍គ្រាប់ពូជ និងបណ្តុះបណ្តាលមន្ត្រីឱ្យចេះប្រើប្រាស់ឧបករណ៍ទាំងនោះ

២២. ចង់ប្លាស្ទីក Volcanic cube (cocune ) សម្រាប់ចំណុះ៣តោនចំនួន ១០ សម្រាប់ចំណុះ៥តោន ចំនួន៣ និងសម្រាប់ចំណុះ១០តោន ចំនួន២ សម្រាប់ទុកគ្រាប់ពូជស្រូវ

២៣. កំណត់រកប្រព័ន្ធដំណាំដោយយកដំណាំស្រូវជាមូលដ្ឋាន តាមរយៈគម្រោងបង្កើនផលិតភាពកសិកម្មខេត្តភាគខាងកើតនៅក្នុងប្រព័ន្ធស្រោចស្រពចំនួន១៥ក្នុងរយៈពេល៣ឆ្នាំ

២៤. បញ្ជ្រាបការបញ្ចូលស្រូវពូជទាំង១០ តាមរយៈការដឹកនាំកសិករផលិត និងសម្រិតសម្រាំងគ្រាប់ពូជស្រូវ តាមរយៈគម្រោងបង្កើនផលិតភាពកសិកម្មខេត្តភាគខាងកើតនៅក្នុងប្រព័ន្ធស្រោចស្រពចំនួន១៥ ក្នុងរយៈពេល៣ឆ្នាំ

២៥. បង្ហាញនូវបង្គុំបច្ចេកវិទ្យាបង្កើននូវផលិតភាពដំណាំស្រូវតាមរយៈគម្រោងបង្កើនផលិតភាពកសិកម្មខេត្តភាគខាងកើត នៅក្នុងប្រព័ន្ធស្រោចស្រពចំនួន១៥ ក្នុងរយៈពេល៣ឆ្នាំ
២៦. សង់ប្រឡាយបេតុងរំដោះទឹក ស្តារប្រឡាយក្នុងបរិវេណវិទ្យាស្ថាន និងជីកប្រឡាយនាំទឹកពីប្រឡាយទឹកខាងលិចមកប្រឡាយក្នុងវិទ្យាស្ថានកាឌី
២៧. ការងារគ្រប់គ្រងស្ថានីយ៍កណ្តាល
២៨. ការងារគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
២៩. ការងារគ្រប់គ្រងស្ថានីយ៍ស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកោះកេរ្តិ៍

### ១.១២. កែលំអរចនាសម្ព័ន្ធ តួនាទីភារកិច្ច និងពង្រឹងប្រសិទ្ធភាពប្រពន្ធ័ផ្សព្វផ្សាយកសិកម្ម

**សកម្មភាព៖**

១. បណ្តុះបណ្តាលមន្ត្រីផ្សព្វផ្សាយកសិកម្មខេត្តនិងស្រុក អំពីជំនាញនិងវិធីសាស្រ្តផ្សព្វផ្សាយកសិកម្ម
២. បណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំពីជំនាញ និងវិធីសាស្រ្តផ្សព្វផ្សាយ
៣. រៀបចំទស្សនកិច្ចសិក្សាសម្រាប់មន្ត្រី ភ្នាក់ងារផ្សព្វផ្សាយ និងកសិករ
៤. រៀបចំសន្និបាតកសិករទូទាំងប្រទេស
៥. សិក្សាវាយតម្លៃស្ថានភាពបច្ចុប្បន្នលើប្រព័ន្ធផ្សព្វផ្សាយកសិកម្ម
៦. សិក្ខាសាលាពិគ្រោះយោបល់ស្តីពីស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធផ្សព្វផ្សាយកសិកម្ម
៧. ការសិក្សាវាយតម្លៃប្រព័ន្ធក្សេត្របរិស្ថានឃុំ
៨. ការគ្រប់គ្រងទិន្នន័យគ្រឹះប្រព័ន្ធព័ត៌មានប្រព័ន្ធកសិកម្ម
៩. ការសិក្សាវាយតម្លៃប្រព័ន្ធកសិកកម្ម និងសេដ្ឋកិច្ចកសិកម្មគ្រួសារ
១០. ធ្វើបង្ហាញប្រព័ន្ធផលិតកម្មកសិកម្មគំរូ
១១. ពង្រឹករចនាសម្ព័ន្ធផ្សព្វផ្សាយកសិកម្មដល់ថ្នាក់ឃុំ និង កសាងមណ្ឌលផ្សព្វផ្សាយកសិកម្មឃុំ

### ១.១៣. បង្កើនសមត្ថភាពមន្ត្រីភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងអ្នកពាក់ព័ន្ធនានា តាមរយៈការអប់រំ ការបណ្តុះបណ្តាលពីវិធីសាស្រ្តផ្សព្វផ្សាយ

**សកម្មភាព៖**

១. ការបណ្តុះបណ្តាលស្តីពីវិធីសាស្រ្តផ្សព្វផ្សាយកសិកម្ម
២. ដំណើរការសិក្ខាសាលាប្រចាំឆ្នាំដើម្បីកែលំអប្រពន្ធ័អភិវឌ្ឍន៍ធនធានមនុស្ស

៣. ការរៀបចំបង្កើតកម្មវិធីសិក្សា សម្រាប់វគ្គបណ្តុះបណ្តាលក្រុមស្ត្រីស្តីពីបង្កើនមុខរបរខ្នាតតូច និងការអនុវត្តជាក់ស្តែង

៤. ដំណើរការសិក្ខាសាលាដើម្បីរៀបចំ និងចូលរួមចំណែកបង្កើតគោលនយោបាយពាក់ព័ន្ធ

៥. បណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយភូមិ

៦. ពង្រឹងសហគមន៍កសិកម្មលើការងារគ្រប់គ្រង ការគ្រប់គ្រងបញ្ជីគណនេយ្យ និងការធ្វើជំនួញ

៧. កសាងឡសម្ងួត និងឃ្លាំងស្តុកកសិផលដល់សហគមន៍ចំនួន២០

## ១.១៤. បង្កើនការផ្សព្វផ្សាយពីបច្ចេកទេសថ្មីៗ ទាក់ទងនឹងវិស័យផលិតកម្ម និងបសុព្យាបាល ដើម្បីបង្កើនសមត្ថភាពយល់ដឹងនៅតាមមូលដ្ឋាន

### សកម្មភាពៈ

១. ការឃោសនាផ្សព្វផ្សាយពីការអនុវត្តល្អប្រសើរនៃវិធានការការពារ និងទប់ស្កាត់ជំងឺឆ្លងសត្វ

២. ឃោសនាផ្សព្វផ្សាយពីវិធានបសុពេទ្យ ដើម្បីលើកកម្ពស់គុណភាពអនាម័យ និងសុវត្ថិភាពសាច់ និងផលិតផលសាច់នៅតាមសត្តឃាតដ្ឋាន និងទីផ្សារ

៣. ការឃោសនាផ្សព្វផ្សាយពីប្រសិទ្ធភាពនៃការអនុវត្តល្អប្រសើរលើការចិញ្ចឹមសត្វ

៤. ការផ្សព្វផ្សាយស្តីពីការយល់ដឹងនិងការអនុវត្តច្បាប់សុខភាពសត្វ និងផលិតកម្មសត្វ និងឯកសារក្រោមច្បាប់ឱ្យមានភាពល្អប្រសើរ និងទូលំទូលាយ

## ១.១៥. ពង្រឹងសមត្ថភាពមន្ត្រី និងប្រសិទ្ធភាពនៃការអនុវត្ត លើសេវាផលិតកម្ម និងបសុព្យាបាលសត្វ

### សកម្មភាពៈ

១. ការបណ្តុះបណ្តាលថ្មី និងការបំពាក់បំប៉នបច្ចេកទេសបន្ថែម លើកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសថ្មីដល់ភ្នាក់ងារសុខភាពសត្វភូមិ

២. ការបណ្តុះបណ្តាលការងារមន្ទីរពិសោធន៍ដល់មន្ត្រីនៅថ្នាក់កណ្តាល និងរាជធានី ខេត្ត ស្រុក

៣. ការបណ្តុះបណ្តាលការតាមដានឃ្លាំមើលជំងឺសត្វ ដល់មន្ត្រីផលិតកម្មនិងបសុព្យា-បាលស្រុក ខេត្ត

៤. ការបណ្ដុះបណ្ដាលជំងឺឆ្លងសត្វសំខាន់ៗ (ប៉េស្តជ្រូក គ្រុចៀកខៀវ អុតក្ដាម សារទឹកបូសខ្យល់ ឈាមខ្មៅ ញូវកាស អាសន្នរោគបក្សី ផ្ដាសាយបក្សី និងផ្ដាសាយជ្រូក) និងរបៀបធ្វើរោគវិនិច្ឆ័យជំងឺដល់មន្ត្រីផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត

៥. ការបណ្ដុះបណ្ដាលពីរបៀបយកវត្ថុវិភាគ (ប៉េស្តជ្រូក គ្រុចៀកខៀវ អុតក្ដាម សារទឹកបូសខ្យល់ ឈាមខ្មៅ ញូវកាស អាសន្នរោគបក្សី ផ្ដាសាយបក្សី) និងការធ្វើរោគវិនិច្ឆ័យជំងឺដល់មន្ត្រីផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ស្រុក

៦. ការបណ្ដុះបណ្ដាលពីការអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺសត្វ ដល់មន្ត្រីផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ស្រុក

## ១.១៦. សិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយ ពីបច្ចេកវិទ្យាក្រោយពេលប្រមូលផល ការកែច្នៃ និងទីផ្សារផលិតផលកសិកម្ម

**សកម្មភាព៖**

១. សិក្សាពីស្ថានភាពក្រោយពេលប្រមូលផល នៃផលិតផលកសិកម្មនៅកម្ពុជា និងការកែលំអដើម្បីភាពរីកចម្រើន

២. សិក្សាពីស្ថានភាពកែច្នៃកសិផលកម្ពុជា និងការកែលំអដើម្បីភាពរីកចម្រើន

៣. សិក្សាពីស្ថានភាពទីផ្សារផលិតផលកសិកម្មនៅកម្ពុជា និងការកែលំអដើម្បីភាពរីកចម្រើន

## ១.១៧. សិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយ អំពីសហគ្រាសកសិកម្ម និងកសិឧស្សាហកម្ម នៅកម្ពុជា

**សកម្មភាព៖**

១. ការគ្រប់គ្រងសហគ្រាសកសិកម្ម និងកសិឧស្សាហកម្មនៅកម្ពុជា

## ១.១៨. ពង្រឹងនិងបង្កើនសមត្ថភាព ដល់មន្ត្រីស្រាវជ្រាវ និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធនានាតាមរយៈ ផ្ដល់វគ្គបណ្ដុះបណ្ដាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា

**សកម្មភាព៖**

១. បើកវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា និងរៀបចំសន្និបាតបច្ចេកទេសក្នុងប្រទេសចំនួន១០ និងបើកវគ្គបណ្ដុះបណ្ដាលបច្ចេកទេសកសិកម្មចំនួន៧វគ្គ ដល់មន្ត្រីបច្ចេកទេស ភ្នាក់ងារផ្សព្វផ្សាយកសិករ និងអ្នកពាក់ព័ន្ធ

២. បើកសិក្ខាសាលាសម្រាប់មន្ត្រីស្រាវជ្រាវ មន្ត្រីបច្ចេកទេស និងជំនួយការស្រាវជ្រាវក្នុងគោលបំណងបង្ហាញនូវចំណេះដឹងនិងបច្ចេកទេសថ្មីៗ ព្រមទាំងផ្លាស់ប្ដូរបទពិសោធន៍និងយោបល់ ដើម្បីជួយជំរុញការអភិវឌ្ឍវិស័យកសិកម្មកម្ពុជា ឱ្យកាន់តែប្រសើរឡើងជាលំដាប់

៣. រៀបចំសន្និបាតបច្ចេកទេសកសិកម្ម ប្រមូលផ្តុំរាល់មន្ត្រីស្រាវជ្រាវ មន្ត្រីបច្ចេកទេស អ្នកផ្សព្វផ្សាយ និងអ្នកពាក់ពន្ធ័ទាំងអស់ ដើម្បីបង្ហាញនូវលទ្ធផលនៃការស្រាវជ្រាវក្នុងរយៈពេល១ឆ្នាំកន្លងមក និងលើកទិសដៅសម្រាប់ការអនុវត្តនៅឆ្នាំខាងមុខ

៤. ដឹកនាំនិស្សិតសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ និងបរិញ្ញាប័ត្រជាន់ខ្ពស់ជំនាញកសិកម្ម

៥. បើកវគ្គបណ្តុះបណ្តាលសិក្ខាសាលា និងរៀបចំទស្សនកិច្ចសិក្សាក្រៅប្រទេស ដើម្បីទទួលបាននូវចំណេះដឹង និងបច្ចេកទេស ព្រមទាំងបទពិសោធន៍ល្អៗពីប្រទេសនានាក្នុងតំបន់និងក្រៅតំបន់

៦. រៀបចំនិងសម្របសម្រួលសិក្ខាសាលាក្រៅប្រទេស សម្រាប់ថ្នាក់ដឹកនាំ មន្ត្រីស្រាវជ្រាវនិងមន្ត្រីបច្ចេកទេស បានចូលរួមចែករំលែកនូវបទពិសោធន៍ ក៏ដូចជាចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗ ព្រមទាំងបទពិសោធន៍ល្អៗពីប្រទេសនានា ក្នុងនិងក្រៅតំបន់តាមរយៈសិក្ខាសាលាក្រៅប្រទេស

៧. ទស្សនកិច្ចសិក្សាក្រៅប្រទេសសម្រាប់ថ្នាក់ដឹកនាំ មន្ត្រីស្រាវជ្រាវ បានទៅទស្សនកិច្ចសិក្សាស្វែងយល់ ដើម្បីទទួលបានពិសោធន៍នូវបច្ចេកទេសទំនើបៗ ពីបណ្តាប្រទេសជឿនលឿន

### ១.១៩. អភិវឌ្ឍន៍និងពង្រឹងការគ្រប់គ្រងប្រព័ន្ធកសិកម្ម និងបទដ្ឋានអនុវត្តបច្ចេកវិទ្យាសម្រាប់ការចូលរួមកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាន

**សកម្មភាពៈ**

១. ការបណ្តុះបណ្តាលលើការវិភាគប្រព័ន្ធក្សេត្របរិស្ថាន ដល់មន្ត្រីផ្សព្វផ្សាយកសិកម្មនៅថ្នាក់រាជធានីខេត្ត ស្រុក និងភ្នាក់ងារផ្សព្វផ្សាយភូមិ

២. ការបណ្តុះបណ្តាលដល់មន្ត្រីផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត ក្រុង ស្រុក និងភ្នាក់ងារផ្សព្វផ្សាយភូមិ នូវបច្ចេកវិទ្យាកសិកម្មដែលជាតម្រូវការរបស់កសិករក្នុងតំបន់

៣. ការបណ្តុះបណ្តាលដល់មន្ត្រីផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិ និង ខេត្ត ពីការងារគ្រប់គ្រងទិន្នន័យប្រព័ន្ធក្សេត្របរិស្ថាន

៤. សិក្ខាសាលាបង្ហាញពីសារៈសំខាន់នៃការប្រើប្រាស់ទិន្នន័យប្រព័ន្ធក្សេត្របរិស្ថាន សម្រាប់ការរៀបចំផែនការរបស់មន្ទីរកសិកម្មរាជធានី ខេត្ត

៥ សិក្សាវាយតម្លៃពីខ្សែសង្វាក់ផលិតកម្មកសិកម្ម និងទីផ្សារកសិផលនៅមូលដ្ឋាន

៦ បណ្តុះបណ្តាលពីបច្ចេកទេសការទុកដាក់ក្រោយពេលប្រមូលផលលើដំណាំស្រូវ

៧. សិក្សាវាយតម្លៃពីទីផ្សារនិងការកែច្នៃផលិតផលនិងទំនាក់ទំនងលើអ្នកកែច្នៃកសិផល និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ

៨. បណ្តុះបណ្តាលពីបច្ចេកទេសការសម្រិតសម្រាំងពូជស្រូវ

៩. បណ្តុះបណ្តាលពីការវិភាគសេដ្ឋកិច្ចកសិកម្ម

### ១.២០. ពង្រឹងនិងពង្រីកប្រសិទ្ធភាពការផ្សព្វផ្សាយព័ត៌មាន និងបច្ចេកវិទ្យាកសិកម្ម តាមរយៈ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសាធារណៈ

**សកម្មភាពៈ**

១. ការបណ្តុះបណ្តាល និង អនុវត្តជាក់ស្តែងសម្រាប់មន្ត្រីថ្នាក់ជាតិ

២. ការផលិតឯកសារផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងការបោះពុម្ពផ្សាយ

៣. ពង្រីកប្រសិទ្ធភាពការផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម

### ១.២១. ជំរុញការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដល់មន្ត្រីបច្ចេកទេស អ្នកផ្សព្វផ្សាយ កសិករ និងអ្នកពាក់ព័ន្ធនានា តាមរយៈការបោះពុម្ពផ្សាយ

**សកម្មភាពៈ**

១. បោះពុម្ពរបាយការណ៍ប្រចាំឆ្នាំចំនួន ១.០០០ ច្បាប់ (សម្រាប់ចែកជូនអ្នកពាក់ព័ន្ធទាំងអស់)

២. បោះពុម្ពអត្ថបទព័ត៌មានចំនួន ២.០០០ ច្បាប់ (សម្រាប់ចែកជូនអ្នកពាក់ព័ន្ធទាំងអស់)

៣. បោះពុម្ពព្រឹត្តិប័ត្រកសិករចំនួន ២.០០០ ច្បាប់ (សម្រាប់ចែកជូនអ្នកពាក់ព័ន្ធទាំងអស់)

៤. បោះពុម្ពខិតប័ណ្ណព័ត៌មានបច្ចេកទេសកសិកម្មចំនួន ៥.០០០ ច្បាប់ (សម្រាប់ចែកជូនអ្នកពាក់ព័ន្ធទាំងអស់)

៥. បោះពុម្ពទស្សនាវដ្តីកសិកម្មចំនួន ១.០០០ ច្បាប់

៦. ផលិតខ្សែវីដេអូ (Video Spot) និងស៊ីឌីបច្ចេកទេសកសិកម្ម

៧. បោះពុម្ពផែនទីដីសម្រាប់ដំណាំស្រូវ និងដំណាំកសិកម្មដទៃទៀតចំនួន ១.០០០ ច្បាប់

### ១.២២. បង្កើនផលិតកម្មស្បៀង និងប្រាក់ចំណូលគ្រួសារកសិករ តាមរយៈ ការអនុវត្តបច្ចេកទេសផ្សព្វផ្សាយកសិកម្មនៅជនបទ

**សកម្មភាពៈ**

១. ការរៀបចំច្បាប់ និងគោលនយោបាយយុទ្ធសាស្ត្រជាតិស្តីពីសហករណ៍កសិកម្ម

២. ការបណ្តុះបណ្តាលស្តីពីប្រពលវប្បកម្ម និងពហុវប្បកម្មដំណាំ ជាពិសេសដំណាំស្រូវ ចំនួន ២០វគ្គ

៣. ការបណ្តុះបណ្តាលស្តីពីបច្ចេកទេសដំណាំបន្លែ

៤. បណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមសត្វចំនួន ២០ វគ្គ

៥. បណ្តុះបណ្តាលស្តីពីបច្ចេកទេសវារីវប្បកម្មចំនួន ២០ វគ្គ

៦. បណ្តុះបណ្តាលស្តីពីក្រុមសន្សំឥណទាន និងបង្កើតក្រុមកសិករចំនួន ២០ វគ្គ

៧. បណ្តុះបណ្តាលស្តីពីការធ្វើផែនការ និងការគ្រប់គ្រងអាជីវកម្មខ្នាតតូចចំនួន ២០ វគ្គ

៨. បណ្តុះបណ្តាលស្តីពីការរៀបចំផែនការក្នុងការងារដាំដុះ
៩. សាលារៀនចម្រុះស្រែកសិករពីផលិតកម្មស្បៀង និងចំណូលគ្រួសារ
១០. វគ្គបណ្តុះបណ្តាលកសិករអំពីប្រព័ន្ធកសិកម្មចម្រុះប្រពលវប្បកម្ម និងពហុវប្បកម្ម ដោយយកដំណាំស្រូវជាមូលដ្ឋាន
១១. វគ្គបណ្តុះបណ្តាលកសិករពីផលិតកម្មបន្លែ និងសួនដំណាំគ្រួសារ
១២. វគ្គបណ្តុះបណ្តាលកសិករពីការចិញ្ចឹមជាលក្ខណៈគ្រួសារ
១៣ វគ្គបណ្តុះបណ្តាលកសិករពីការចិញ្ចឹមត្រី (វារីវប្បកម្ម) ជាលក្ខណៈគ្រួសារ
១៤. វគ្គបណ្តុះបណ្តាលកសិករពីការសន្សំប្រាក់ និងបង្កើតក្រុមសន្សំ

## ១.២៣. ពង្រឹងការស្រាវជ្រាវ និងអភិវឌ្ឍន៍ពូជដំណាំ បច្ចេកទេសផលិតកម្មដំណាំ និងការការពារដំណាំ

**សកម្មភាព៖**

១. ការសិក្សាបឋមអំពីតំបន់ដាំដុះដំណាំឧស្សាហកម្ម
២. ការពិសោធន៍ស្រាវជ្រាវជ្រើសរើសពូជ និងបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងសាកវប្បកម្ម និងដំណាំរួមផ្សំសមស្របនឹងកេ្សត្របរិស្ថាននៃប្រទេសកម្ពុជា
៣. ការគ្រប់គ្រង និងអភិរក្សប្រភពធនធានសេនេទិចដំណាំ (ដំណាំឧស្សាហកម្ម និងដំណាំសាកវប្បកម្ម និងដំណាំរួមផ្សំ)
៤. ការអង្កេតនិងវិធានការកម្ចាត់រុយចោះផ្លែលើដំណាំស្វាយនៅកម្ពុជា
៥. ការអង្កេតនិងវិធានការកម្ចាត់ខ្មុងដូងនៅកម្ពុជា
៦. ការអង្កេតសមាសភាពចង្រៃលើដំណាំសំខាន់ៗ (ស្រូវ ដំឡូងមី ស្វាយច័ន្ទី សណ្តែកសៀង ពោត និង បន្លែ ផ្លែឈើ និងដូងប្រេង)
៧. រៀបចំចងក្រងឯកសារ និងផ្សព្វផ្សាយស្តីពីនីតិវិធីនៃការនាំចេញទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ
៨. សិក្សាពីប្រភេទសត្វល្អិតចង្រៃលើអង្ករនៅក្នុងប្រទេសកម្ពុជារៀបចំបញ្ជីឈ្មោះសត្វល្អិតចង្រៃ ដើម្បីឆ្លើយតបការតម្រូវរបស់ភាគីពាក់ព័ន្ធ រៀបចំចងក្រង និងផ្សព្វផ្សាយអត្ថបទបច្ចេកទេសស្តីពីសត្វល្អិតចង្រៃលើអង្ករ

## ១.២៤. ពង្រឹងការស្រាវជ្រាវបច្ចេកទេសគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម

**សកម្មភាព៖**

១. ពិសោធន៍និងកែសម្រួលម៉ាស៊ីនជួយបំផុសដីនិងសំអាតស្មៅ និងឧបករណ៍ពីរប្រភេទ ឧបករណ៍ដាំពោត សណ្តែក និងអង្គប់វាយដីភ្ជាប់កៀវ ភ្ជាប់ដោយគោយន្ត

២.	ពិសោធន៍និងកែសម្រួលឧបករណ៍បីប្រភេទ ឧបករណ៍លើករងនិងភ្លឺស្រែ ដាំពោត សណ្តែក ភ្ជាប់ដោយគោយន្តនិងត្រាក់ទ័រ

**១.២៥. ជំរុញការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដល់មន្ត្រីបច្ចេកទេស ភ្នាក់ងារផ្សព្វផ្សាយ និង អ្នកពាក់ព័ន្ធនានា តាមរយៈ ព័ត៌មានវិទ្យា**

**សកម្មភាព៖**

១.	អភិវឌ្ឍន៍និងកែលម្អគេហទំព័ររបស់វិទ្យាស្ថានកាឌីជារៀងរាល់ឆ្នាំ

២.	ផលិតជាស៊ីឌីបច្ចេកទេសកសិកម្មចំនួន ១.០០០ ច្បាប់

**១.២៦. ជំរុញការត្រួតពិនិត្យនិងការគ្រប់គ្រងបមាណីសម្ភារកសិកម្ម**

**សកម្មភាព៖**

១.	ចុះពង្រឹងការត្រួតពិនិត្យការធ្វើអាជីវកម្មតាមដេប៉ូលក់សម្ភារកសិកម្មនិងណែនាំដល់បណ្តាអាជីវករ ដែលធ្វើអាជីវកម្មសម្ភារកសិកម្មក្នុងខេត្តគោលដៅ

២.	រៀបចំសិក្ខាសាលាផ្សព្វផ្សាយឱ្យយល់ដឹងអំពីលិខិតបទដ្ឋានពាក់ព័ន្ធបមាណីសម្ភារកសិកម្ម ដល់មន្ត្រីពាក់ព័ន្ធ និងអាជីវករកសិករក្នុងខេត្តគោលដៅ

៣.	ចាក់ផ្សាយឈុតអប់រំស្តីពីសុវត្ថិភាពនៃការទិញនិងប្រើប្រាស់ថ្នាំកសិកម្មតាមទូរទស្សន៍

៤-	ការលើកកម្ពស់ផ្នែកមន្ទីរពិសោធន៍ សម្រាប់ដំណើរការវិភាគបមាណីសម្ភារកសិកម្ម

**១.២៧. ជំរុញ ការដាំដុះ កៅស៊ូ គ្រួសារ(ជួយបង្កើនជីវភាព រស់នៅរបស់កសិករតូចតាចជួយកាត់បន្ថយភាពក្រីក្រ និងបង្កើនការងារនៅ ជនបទជៀសវាងការធ្វើចំណាកស្រុក)**

**សកម្មភាព៖**

១.	បណ្តុះបណ្តាលមន្ត្រីបង្គោលសម្រាប់បង្កើនផលិតភាពដំណាំកៅស៊ូ

២.	បណ្តុះបណ្តាល និងផ្សព្វផ្សាយ បច្ចេកទេសដំណាំកៅស៊ូដល់អ្នកដាំកៅស៊ូ

៣.	ស្រង់ស្ថិតិផ្ទៃដីដំណាំកៅស៊ូគ្រួសារ

៤.	ចូលរួមក្នុងវេទិកាកៅស៊ូទាំងក្នុងនិងក្រៅប្រទេស ដើម្បីទាក់ទាញរកដៃគូសហប្រតិបត្តិការនិងគាំទ្រផ្តល់ថវិកា

**១.២៨. ការសិក្សាអំពីលទ្ធភាព ប្រើប្រាស់ដោយស្របច្បាប់នូវសក្តានុពលដីទំនេរ ដែលគប នឹងដំណាំកៅស៊ូ(សម្រួលដល់ការប្រើប្រាស់សក្តានុពលដីនៅក្នុងតំបន់ព្រៃរេចរិល ដីសម្បទានសេដ្ឋកិច្ច ឬសង្គមកិច្ចដល់កសិករឬសមាគមន៍)**

**សកម្មភាព៖**

១.	ស្រង់ស្ថិតិចម្ការកៅស៊ូគ្រួសារ ស្ថិតក្នុងដីសម្បទានសេដ្ឋកិច្ច សង្គមកិច្ច និងតំបន់ព្រៃឈើរេចរិល

២.	ចុះសម្របសម្រួលក្នុងការរៀបចំធ្វើប័ណ្ណកម្មសិទ្ធិដីចម្ការកៅស៊ូ
៣.	ចុះពិនិត្យដីកបនឹងដំណាំកៅស៊ូ និងរៀបចំធ្វើផែនទីដាំដុះកៅស៊ូ

**១.២៩.	ធានាគុណភាពនៃការដាំដុះកៅស៊ូ (លើកកម្ពស់គុណភាពចម្ការកៅស៊ូគ្រប់ផ្នែកឱ្យទទួលបាននូវទិន្នផលខ្ពស់សំដៅបង្កើនប្រាក់ចំណូលដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិ និងការពារបរិស្ថានធម្មជាតិ)**

**សកម្មភាព៖**

១.	ចុះផ្សព្វផ្សាយបច្ចេកទេសកៅស៊ូថ្នាក់ជាតិដល់អ្នកដាំកៅស៊ូទូទាំងប្រទេសទទួលបាននូវចំណេះដឹងពីការដាំដំណាំកៅស៊ូ និងក្លូនកៅស៊ូមានទិន្នផលខ្ពស់
២.	ត្រួតពិនិត្យផ្តល់វិញ្ញាបនបត្រ និងបណ្តុះបណ្តាលអ្នកធ្វើច្បារពូជ
៣.	ចុះត្រួតពិនិត្យ និងបណ្តុះបណ្តាលអ្នកធ្វើថ្នាលកូន
៤.	ចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ទទួលបានរបកគំហើញដើម្បីធ្វើច្បារ បង្កាត់ពូជដែលមានទិន្នផលខ្ពស់ និងបន្សាំបាននឹងការប្រែប្រួលបរិយាកាស

**ទិសដៅគោលនយោបាយទី២-"ពង្រីកលទ្ធភាពនៃការចូលទីផ្សារសម្រាប់ផលិតផលកសិកម្ម"**

**កម្មវិធីទី-២៖ ជំរុញការចូលទីផ្សារនៃផលិតផលកសិកម្ម**

**២.១.	កែលំអគុណភាព និងចំណាត់ថ្នាក់ផលិតផលកសិកម្ម**

**សកម្មភាព៖**

១.	ការផ្សព្វផ្សាយអំពីបច្ចេកវិទ្យាមុនក្រោយប្រមូលផល (ដោយផ្តោតលើដំណាំជាមុខសញ្ញានាំចេញ)
២.	ការអភិវឌ្ឍនិងផ្សព្វផ្សាយបច្ចេកទេសចំណាត់ថ្នាក់កសិផល (ជាពិសេសដំណាំមុខសញ្ញានាំចេញ)
៣.	ការអភិវឌ្ឍស្តង់ដារជាតិសម្រាប់ផលិតផលកសិកម្ម (ជាពិសេស ដំណាំមុខសញ្ញានាំចេញ)
៤.	ការជំរុញការធ្វើកសិកម្មសរីរាង្គ (ជាពិសេសដំណាំស្រូវ) និងចលនាភូមិមួយផលិតផលមួយ

**២.២.	ពង្រឹងសមត្ថភាព និងសេវាកម្មត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម**

**សកម្មភាព៖**

១.	ពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពមន្ត្រីបច្ចេកទេសមន្ទីរពិសោធន៍ជាតិកសិកម្ម

២.	ពង្រឹងសមត្ថភាពវិភាគនៅក្នុងមន្ទីរពិសោធន៍ជាតិកសិកម្ម ដោយបំពាក់នូវសារធាតុគីមី សម្ភារបរិក្ខារ និងឧបករណ៍វិភាគទំនើបទាន់សម័យ
៣.	រៀបចំលិខិតបទដ្ឋានបច្ចេកទេសស្តីគំរូស្តង់ដារមន្ទីរពិសោធន៍
៤.	ការកសាងនិងពង្រឹងស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យតាមច្រកព្រំដែនដើម្បីសម្រួលដល់ការចេញវិញ្ញាបនប័ត្រអនាម័យនិងភូតគាមអនាម័យ
៥.	ការគាំទ្រការអភិវឌ្ឍវិស័យនាំចេញកសិផលតាមរយៈយន្តការលុបបំបាត់របាំងបច្ចេកទេសលើការនាំចេញ-នាំចូលកសិផល និងពង្រឹងលើផ្នែកយន្តការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យ
៦.	ការជំរុញការអង្កេតស្រាវជ្រាវ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធប្រព្រឹត្តកម្មផលិតផលកសិកម្មដើម្បីសម្របសម្រួលតាមតម្រូវការទីផ្សារ
៧.	ពង្រឹងការបណ្តុះបណ្តាលលើវិស័យភូតគាមអនាម័យ និងអនាម័យសត្វ
៨.	បណ្តុះបណ្តាលថ្នាក់ឧត្តមនិងក្រោយឧត្តម
៩.	ពង្រឹងហេដ្ឋារចនាសម្ពន្ធ័សម្រាប់ការស្រាវជ្រាវនិងផ្សព្វផ្សាយ
១០.	ពង្រីកហេដ្ឋារចនាសម្ពន្ធ័បណ្តុះបណ្តាល
១១.	សិក្សាស្រាវជ្រាវទំនាក់ទំនងសំណល់គីមី និងជីវៈនៃផលិតផលសត្វ និងប្រភេទផលិតកម្ម

## ២.៣.	បង្កើនការយល់ដឹងអំពីតម្រូវការ និងល័ក្ខខ័ណ្ឌទីផ្សារក្នុងស្រុក និងក្នុងរបបពាណិជ្ជកម្មពិភពលោកដល់អ្នកពាក់ព័ន្ធ

**សកម្មភាពៈ**

១.	ការណ្តុះបណ្តាលដំណើរការសិក្ខាសាលា និងការផ្សព្វផ្សាយអំពីតម្រូវការ និងល័ក្ខខ័ណ្ឌទីផ្សារ
២.	ការអង្កេតស្រាវជ្រាវនិងផ្សព្វផ្សាយព័ត៌មានទីផ្សារ នៃផលិតផលដំណាំសាកវប្បកម្មនិងដំណាំរួមផ្សំ
៣.	ផ្តល់វគ្គបណ្តុះបណ្តាលអំពីទស្សនទានទីផ្សារស្រូវបើកចំហរ និងលិខិតបទដ្ឋាន ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា
៤.	បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពគ្រប់គ្រងទីផ្សារស្រូវបើកចំហរ និងកសាងពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសហគមន៍កសិកម្ម ឬសម្ព័ន្ធសហគមន៍គំរូចំនួន ៥
៥.	បង្កើតនិងដំណើរការទីផ្សារស្រូវបើកចំហរដល់សហគមន៍កសិកម្មគំរូ ៥ កន្លែង
៦.	ធ្វើសិក្ខាសាលាដល់មន្ត្រីទីផ្សារនៅគ្រប់រាជធានីខេត្តស្តីពីវិធីសាស្ត្រនៃការប្រមូលទិន្នន័យព័ត៌មានតម្លៃ
៧.	ចុះទៅត្រួតពិនិត្យនិងតាមដានការប្រមូលទិន្នន័យព័ត៌មានតម្លៃ

៨. ប្រមូលព័ត៌មានតម្លៃទីផ្សារស្រូវអង្ករក្នុងស្រុក និងចរាចរស្រូវអង្ករក្នុងប្រទេស
៩. ប្រមូលព័ត៌មានតម្លៃទីផ្សារស្រូវអង្ករក្នុងតំបន់និងអន្តរជាតិ
១០. ផ្សព្វផ្សាយព័ត៌មានតម្លៃស្រូវអង្ករក្នុងស្រុកក្នុងតំបន់ និងទីផ្សារអន្តរជាតិ តាមវិទ្យុ ទូរទស្សន៍ សារជាអក្សរ ព្រឹត្តិប័ត្រ និងគេហទំព័រ
១១. ភ្ជាប់គេហទំព័រព័ត៌មានទីផ្សារកសិកម្មជាមួយនឹងគេហទំព័រទីផ្សារអង្ករអន្តរជាតិ

## ២.៤. ជំរុញ និងការឈានចូលដល់ប្រព័ន្ធទីផ្សារកសិកម្ម និងអភិវឌ្ឍន៍ទីផ្សារ

**សកម្មភាព៖**

១. ជំរុញការចូលទីផ្សារនៃបច្ចេកវិទ្យាកសិកម្ម តាមរយៈការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា ផលិតស្រូវក្រអូបផ្ការំដួល និងសែនពិដោរ
២. ជំរុញការចូលទីផ្សារនៃបច្ចេកវិទ្យាកសិកម្ម តាមរយៈការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា ផលិតស្រូវរាំងជ័យ
៣. ជំរុញការចូលទីផ្សារនៃបច្ចេកវិទ្យាកសិកម្ម តាមរយៈការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា លើផលិតកម្មដំណាំកសិកម្មដទៃទៀត ដែលបញ្ចេញដោយវិទ្យាស្ថានកាឌី

## ២.៥. លើកកម្ពស់សុវត្ថិភាពនៃផលិតផលកសិកម្ម និងតម្រូវការស្តង់ដារទីផ្សារ

**សកម្មភាព៖**

១. សិក្សានិងវាយតម្លៃអំពីការរីកសាយភាយ និងការទទួលយករបស់កសិករ ចំពោះបច្ចេកវិទ្យាថ្មីៗសមស្របដែលបានធ្វើអនុសាសន៍ឱ្យប្រើប្រាស់កន្លងមក សម្រាប់បង្កើនផលិតកម្មដំណាំស្រូវ
២. ការសិក្សាវាយតម្លៃអំពីតម្រូវការ និងការផ្គត់ផ្គង់ទីផ្សារសម្រាប់ផលិតកម្មដំណាំស្រូវ។
៣. ការសិក្សានិងវិភាគពីថវិកាសម្រាប់ផលិតកម្មដំណាំស្រូវរបស់កសិករ

## ២.៦. ជំរុញការនាំចេញសត្វ និងផលិតផលមានដើមកំណើតពីសត្វទៅទីផ្សារក្នុងតំបន់

**សកម្មភាព៖**

១. បង្កើតក្រុមអ្នកចិញ្ចឹមសត្វ ឬសមាគមន៍ចិញ្ចឹមសត្វ សម្រាប់និរន្តរភាពផ្គត់ផ្គង់ទៅទីផ្សារ
២. ពង្រឹងការងារសហគ្រាសចិញ្ចឹមសត្វខ្នាតតូចនិងមធ្យម ក្នុងការជំរុញការកែលំអបច្ចេកវិជ្ជាទំនើបក្នុងសង្វាក់ផលិតកម្ម ដើម្បីបង្កើនគុណភាពនិងសុវត្ថិភាពសត្វ និងផលិតផលសត្វ ឱ្យឆ្លើយតបតាមតម្រូវការទីផ្សារ និងផ្តល់តម្លៃបន្ថែម
៣. ពង្រឹងប្រព័ន្ធព័ត៌មានទីផ្សារពីមូលដ្ឋានរហូតដល់ថ្នាក់ជាតិនិងថ្នាក់តំបន់
៤. បង្កើតកិច្ចសហប្រតិបត្តិការទ្វេឬពហុភាគី លើការនាំចេញ ការទំនាក់ទំនងទីផ្សារ និងបណ្តាញតភ្ជាប់ទីផ្សារពីមូលដ្ឋានទៅថ្នាក់ជាតិនិងតំបន់

៥. បង្កើនការសិក្សាស្រាវជ្រាវបន្ត ពីការផ្គត់ផ្គង់ និង តំរូវការទីផ្សារសត្វ

### ២.៧. បង្កើនការយល់ដឹងអំពីបច្ចេកវិទ្យាក្រោយពេលប្រមូលផល ការកែច្នៃ ការកែលំអប្រព័ន្ធទីផ្សារ និង ការកែលំអគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម

**សកម្មភាព៖**

១. ផ្តល់វគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសស្តុកគ្រាប់ធញ្ញជាតិជាលក្ខណៈគ្រួសារ
២. ផ្តល់វគ្គបណ្តុះបណ្តាលអំពីការកែច្នៃ និងផ្សំចំណីសត្វ
៣. ផ្តល់វគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសទុកដាក់ផ្លែឈើស្រស់ ដូចជា ស្វាយ ប៉េងប៉ោះ និងការកែច្នៃ
៤. ការលើកកំពស់ស្តង់ដាគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម
៥. ផ្តល់ការយល់ដឹងពីការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា
៦. ការជំរុញទីផ្សារកសិផលកម្ពុជា និងបង្កើតប្រព័ន្ធព័ត៌មានកសិពាណិជ្ជកម្ម

### ២.៨. ជំរុញខ្សែចង្វាក់ តម្លៃកៅស៊ូឱ្យបានល្អ(ធ្វើឱ្យផលិតផលជ័រកៅស៊ូកម្ពុជាមានតម្លៃខ្ពស់នៅលើទីផ្សារអន្តរជាតិធ្វើឱ្យប្រតិបត្តិករកៅស៊ូទទួលបានចំណូលជាអតិបរិមា)

**សកម្មភាព៖**

១. សិក្សាលំអិតអំពីទីផ្សារគោលដៅសំខាន់ៗរបស់ផលិតផលកៅស៊ូកម្ពុជា
២. បង្កើតមជ្ឈមណ្ឌលទីផ្សារផលិតផលកៅស៊ូ
៣. ជំរុញការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលកៅស៊ូ
៤. ផ្តល់ព័ត៌មានពីការផ្គត់ផ្គង់ តម្រូវការ និងតម្លៃកៅស៊ូប្រចាំថ្ងៃ
៥. ចុះពង្រឹងសមាគមអ្នកដាំកៅស៊ូគ្រួសារ
៦. ចុះពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់រោងចក្រកែច្នៃផលិតផលកៅស៊ូ
៧. ចុះពិនិត្យនិងផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ម្ចាស់រោងចក្រទទួលបានចំណេះដឹងការកែច្នៃផលិតផលកៅស៊ូ
៨. ចុះពិនិត្យនិងផ្សព្វផ្សាយដល់ម្ចាស់រោងចក្រនិងអ្នកនាំចេញឱ្យយល់ដឹងពីផលប្រយោជន៍នៃវិញ្ញាបនបត្របញ្ជាក់គុណភាពជ័រកៅស៊ូ

## ទិសដៅគោលនយោបាយទី៣-"ក្របខ័ណ្ឌនៃការអភិវឌ្ឍស្ថាប័ន និងបញ្ញត្តិច្បាប់"

### កម្មវិធីទី-៣៖ ពង្រឹងស្ថាប័ន ក្របខ័ណ្ឌច្បាប់ និង អភិវឌ្ឍន៍ធនធានមនុស្ស

### ៣.១. កសាងក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ និងកំណែទម្រង់រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ

**សកម្មភាព៖**

១. ការរៀបចំច្បាប់ភូតគាមអនាម័យ និងអនុក្រឹត្យនៅក្រោមច្បាប់ និងប្រកាសផ្សេងៗ

២. ការរៀបចំលក្ខន្តិក:គំរូសម្រាប់សហភាពសហគមន៍កសិកម្ម

៣. ការអភិវឌ្ឍន៍ហេដ្ឋារចនាសម័ន្ធ សហគមន៍កសិកម្ម និងមជ្ឈមណ្ឌលបណ្តុះបណ្តាល

៤. ការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តិស្តីពីការគ្រប់គ្រង និងប្រើប្រាស់ធនធានដីកសិកម្ម

៥. ការកែសម្រួលរចនាសម្ព័ន្ធថ្នាក់ខេត្តឱ្យស្របតាមអាណត្តិរបស់អគ្គនាយកដ្ឋានកសិកម្ម

៦. រៀបចំសារាចរណែនាំឱ្យប្រើប្រាស់ពូជស្រូវដែលបានកំណត់រួចនិងផ្សព្វផ្សាយ

៧. រៀបចំកសាងច្បាប់ស្តីពី «ការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម»

៨. រៀបចំកសាងច្បាប់ស្តីពី «សហគមន៍កសិកម្ម»

៩. រៀបចំគោលនយោបាយជាតិសម្រាប់អភិវឌ្ឍន៍សហគមន៍កសិកម្ម

១០. សម្របសម្រួលនិងផ្តល់ការគាំទ្របច្ចេកទេសដល់សហគមន៍ផលិតស្រូវ ក្នុងភាពជាដៃគូជាមួយរោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញស្រូវអង្ករ

១១. ការរៀបចំរចនាសម្ព័ន្ធតួនាទីភារកិច្ចមណ្ឌលកសិកម្មឃុំសង្កាត់
ចុះសិក្សានិងប្រមូលព័ត៌មានសម្រាប់រៀបចំរចនាសម្ព័ន្ធរបស់មណ្ឌលកសិកម្ម
ចំណុះការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ និងតួនាទីភារកិច្ចរបស់មណ្ឌលកសិកម្មឃុំ សង្កាត់

១២. រៀបចំសេចក្តីព្រាងតួនាទីភារកិច្ចរបស់មណ្ឌលកសិកម្មឃុំ សង្កាត់

១៣. រៀបចំសិក្ខាសាលាពិគ្រោះយោបល់នៅតំបន់គោលដៅចំនួន០៤

១៤. រៀបចំសិក្ខាសាលាថ្នាក់ក្រសួងដើម្បីពិនិត្យនិងសម្រេច លើសេចក្តីព្រាងរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់មណ្ឌលកសិកម្មឃុំ សង្កាត់

១៥. ការពង្រាយមន្ត្រីរាជការឲ្យដល់មូលដ្ឋានមណ្ឌលកសិកម្មឃុំ សង្កាត់

- រៀបចំសិក្ខាសាលាថ្នាក់កណ្តាលនិងរាជធានីខេត្ត ដើម្បីពិគ្រោះយោបល់រកវិធីសាស្រ្ត និងតម្រូវការមន្ត្រីរាជការ
- រៀបចំសារាចរណែនាំដល់មន្ទីរកសិកម្មរាជធានី ខេត្ត ដើម្បីជំរុញមន្ត្រីរាជការដែលមានស្រាប់ក្នុងមន្ទីរកសិកម្ម ឱ្យបំពេញការងារដល់មណ្ឌលកសិកម្មឃុំ សង្កាត់
- រៀបចំផែនការជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី

១៦. ការពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីមូលដ្ឋាន រៀបចំផែនការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី

- រៀបចំវគ្គបណ្តុះបណ្តាលលើការងាររដ្ឋបាលគ្រប់គ្រង ការរៀបចំផែនការ ការងារគណនេយ្យចំនួន ២៤ វគ្គ
- ពង្រាយមន្ត្រីរាជការដល់មណ្ឌលកសិកម្មឃុំ សង្កាត់
- សាងសង់មណ្ឌលកសិកម្មនៅតាមឃុំ សង្កាត់

### ៣.២. បង្កើត និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងលិខិតបទដ្ឋានច្បាប់ពាក់ពន្ធ័នានា ក្នុងការអភិវឌ្ឍសហគមន៍កសិកម្ម

**សកម្មភាព៖**

១. ការវាយតម្លៃប៉ាន់ប្រមាណពីតម្រូវការបណ្តុះបណ្តាល និងការរីកចម្រើនរបស់សហគមន៍កសិកម្ម

២. ការបង្កើនចំណេះដឹងនិងសមត្ថភាពអ្នកដឹកនាំសហគមន៍និងសមាជិក លើការងារគ្រប់គ្រងរដ្ឋបាល គណនេយ្យ ផ្គត់ផ្គង់ និងផ្នែកទីផ្សារ

៣. បង្កើនចំណេះដឹងពាក់ព័ន្ធអំពីគោលការណ៍ច្បាប់សហគមន៍ សហករណ៍កសិកម្ម ដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ដែលសម្របសម្រួលដល់ការងារសហគមន៍កសិកម្ម

៤. កសាងទីស្នាក់ការសហគមន៍កសិកម្ម

៥. ចងក្រងក្រុមកសិករឱ្យទៅជាសហគមន៍កសិកម្ម

៦. ធ្វើសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ និងជំរុញការអនុវត្តអនុក្រឹត្យ «ផលិតកម្មកសិកម្មតាមកិច្ចសន្យា» របស់រាជរដ្ឋាភិបាលដល់សហគមន៍កសិកម្ម

៧. រៀបចំបណ្តាញធុរកិច្ចសហគមន៍កសិកម្មនៅថ្នាក់ជាតិ និងតាមខេត្តគោលដៅ

៨. សិក្ខាសាលាពីការធ្វើជំនួញស្រូវអង្ករដល់សហគមន៍កសិកម្ម

៩. ពង្រឹងសមត្ថភាពសហគមន៍កសិកម្មលើ៖
    - ការងារដឹកនាំនិងរដ្ឋបាល
    - ការគ្រប់គ្រងបញ្ជីគណនេយ្យសហគមន៍
    - ផែនការមុខជំនួញ

១០. ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសហគមន៍ដើម្បីគាំទ្រដល់សហគមន៍កសិកម្ម

១១. ការបង្កើតកសិធុរកិច្ចគំរូក្នុងសហគមន៍កសិកម្ម

១២. សន្និបាតសហគមន៍កសិកម្មទូទាំងប្រទេស

### ៣.៣. លើកកម្ពស់ការអភិវឌ្ឍ និងពង្រឹងក្របខ័ណ្ឌច្បាប់ ពាក់ព័ន្ធនឹងផលិតកម្មសត្វ និងធាតុចូលកសិកម្ម

**សកម្មភាព៖**

១. រៀបចំសរសេរសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ
២. កិច្ចពិភាក្សានិងឆ្លងលើសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ
៣. ពង្រឹងការផ្សព្វផ្សាយនិងការអនុវត្តលើច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ និង ឯកសារពាក់ព័ន្ធក្រោមច្បាប់ដែលបានចូលជាធរមាន
៤. រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងជីកសិកម្ម និងថ្នាំកសិកម្ម
៥. រៀបចំសេចក្តីព្រាងប្រកាសស្តីពីនីតិវិធី និងការតម្រូវបមាណីយ សម្រាប់កិច្ចបញ្ជិកា ថ្នាំកសិកម្ម និងសម្ភារកសិកម្ម
៦. រៀបចំសេចក្តីព្រាងច្បាប់ស្តីពីគុណភាពនិងសុវត្ថិភាពកសិផល
៧. បណ្តុះបណ្តាលគ្រូបង្គោល និងពង្រឹងសមត្ថភាពមន្ត្រីជំនាញ លើការគ្រប់គ្រងគុណភាព សុវត្ថិភាពស្រូវ អង្ករ ដោយផ្អែកលើវិធាន GMP និង HACCP ។

## ៣.៤. ជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានក្រោមច្បាប់ឱ្យមានប្រសិទ្ធភាព

**សកម្មភាព៖**

១. បន្តរៀបចំលិខិតបទដ្ឋានច្បាប់នានាសម្រាប់អនុវត្តច្បាប់ពូជដំណាំ
២. រៀបចំសេចក្តីព្រាងនិងដាក់ឆ្លងការពិភាក្សាតាមដំណាក់កាល នូវច្បាប់ស្តីពីការ ការពាររុក្ខជាតិ និងភូតគាមអនាម័យ
៣. រៀបចំប្រកាសចំនួន៤ដែលស្ថិតក្រោមអនុក្រឹត្យលេខ១៥ អនក្រ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ រួមមាន៖
-ប្រកាសស្តីពីសោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យ និងកម្ចាត់សមាសភាព ចង្រៃ
-ប្រកាសស្តីពីបញ្ជីរាយមុខទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ
-ប្រកាសស្តីពីការតែងតាំងនគរបាលយុត្តិធម៌
-វិសោធនកម្មប្រកាសស្តីពីការបង្កើតឯកសណ្ឋាន សញ្ញាសម្គាល់ និងត្រារបស់មន្ត្រី ភូតគាមអនាម័យ
៤. ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍រោគវិនិច្ឆ័យរុក្ខជាតិ និងមន្ទីរពិសោធន៍វិភាគសំណល់ ថ្នាំកសិកម្មក្នុងផលិតផលកសិកម្ម ដោយបំពាក់ឧបករណ៍និងសម្ភារបច្ចេកទេស បន្ថែមទាំងនៅថ្នាក់កណ្តាល និងស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ
៥. រៀបចំអនុក្រឹត្យនិងប្រកាសស្ថិតនៅក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិ អ្នកបង្កាត់ពូជដំណាំ
៦. រៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់និងអត្ថបទក្រោមច្បាប់ ការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

## ៣.៥. ពង្រឹងសមត្ថភាពជំនាញ និង ទេពកោសល្យដល់មន្ត្រីកសិកម្មពាក់ព័ន្ធគ្រប់ជាន់ថ្នាក់

**សកម្មភាព៖**

១. បណ្តុះបណ្តាលស្តីពីការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាដំណាំស្រូវ ដែលមានការចូលរួម

២. ការបណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវដល់មន្ត្រីកសិកម្មថ្នាក់ខេត្ត ស្រុក

៣. ការបណ្តុះបណ្តាលបច្ចេកទេសផលិតកម្មដំណាំដល់មន្ត្រីកសិកម្មពាក់ព័ន្ធ

៤. ការបណ្តុះបណ្តាលពីវិធីសាស្ត្រពិសោធន៍បង្ហាញលើស្រែកសិករ ដល់មន្ត្រីកសិកម្មខេត្ត ស្រុក

៥. ការកសាងនិងពង្រឹងសមត្ថភាពជំនាញ ដល់មន្ត្រីកសិកម្មពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ពីចំណេះដឹងមូលដ្ឋាន ក្នុងការវាយតម្លៃគ្រប់គ្រង និងប្រើប្រាស់ធនធានដីកសិកម្ម

៦. ការវាយតម្លៃអំពីតម្រូវការ និងកសាងផែនការអភិវឌ្ឍធនធានមនុស្ស របស់អគ្គនាយកដ្ឋានកសិកម្ម

៧. ការតាមដានប្រមូលទិន្នន័យដាំដុះ និងស្ទង់ទិន្នផលដំណាំទូទាំងប្រទេស

៨. ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យស្ថិតិ និងព័ត៌មានទីផ្សារ

៩. ការបណ្តុះបណ្តាលជំនាញ និងទេពកោសល្យ ការគ្រប់គ្រងការធ្វើផែនការ និងគ្រប់គ្រងព័ត៌មានស្ថិតិដល់មន្ត្រីកសិកម្មពាក់ព័ន្ធ

១០. ការកសាងផែនការយុទ្ធសាស្ត្ររយៈពេលវែង មធ្យម និងខ្លី សម្រាប់អគ្គនាយកដ្ឋានកសិកម្ម

១១. ការដំណើរការសន្និបាតបូកសរុបវាយតម្លៃសមិទ្ធផល និងកំណត់ទិសដៅ

១២. រៀបចំកែលម្អនីតិវិធីជួយសម្របសម្រួល ការធ្វើអាជីវកម្ម ការចុះបញ្ជិកា និងការនាំចូលសម្ភារកសិកម្ម

## ៣.៦. បន្តលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រក្នុងវិស័យកសិកម្ម

**សកម្មភាព៖**

១. ការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលបញ្ហាយេនឌ័រនៅក្នុងវិស័យកសិកម្ម

## ៣.៧. ការកសាងច្បាប់គ្រប់គ្រងគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម និងអនុក្រឹត្យពាក់ព័ន្ធនានា

**សកម្មភាព៖**

១. ការកសាងច្បាប់គ្រប់គ្រងគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មកម្ពុជា

២.	ជំរុញការអនុវត្តអនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា

### ៣.៨.	ពង្រឹងសមត្ថភាពជំនាញរបស់ មន្ទីរកសិកម្មរាជធានី ខេត្ត ស្តីពី ការងារអភិវឌ្ឍន៍កសិឧស្សាហកម្ម

**សកម្មភាព៖**

១.	បង្កើនការយល់ដឹងអំពីការងារដើម្បីអភិវឌ្ឍន៍កសិឧស្សាហកម្ម

### ៣.៩.	លើកកម្ពស់អភិវឌ្ឍន៍ និងពង្រឹងក្របខ័ណ្ឌច្បាប់

**សកម្មភាព៖**

១.	កម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម

២.	រៀបចំសេចក្តីព្រាងប្រកាសចំនួន០២ គឺ ៖ សេចក្តីព្រាងប្រកាស ស្តីពីនីតិវិធី និងការតម្រូវបមាណីយ សម្រាប់ការចុះបញ្ជីថ្នាំកសិកម្មនិង សេចក្តីព្រាងប្រកាសស្តីពីនីតិវិធី និង ការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម

៣.	រៀបចំសិក្ខាសាលាពង្រឹងសមត្ថភាពមន្ត្រីនាយកដ្ឋាននីតិកម្មកសិកម្ម ថ្នាក់ដឹកនាំមន្ទីរកសិកម្ម និងមន្ត្រីការិយាល័យនីតិកម្មកសិកម្ម រាជធានីខេត្តក្នុងក្របខ័ណ្ឌការងារគ្រប់គ្រងសម្ភារកសិកម្ម

### ៣.១០.	ជំរុញចម្ការកៅស៊ូកសិឧស្សាហកម្ម ដើម្បីធ្វើជាស្នូលនៃការអភិវឌ្ឍចម្ការកៅស៊ូគ្រួសារ (ជួយឱ្យកសិករម្ចាស់កៅស៊ូគ្រួសារបានទទួលនូវផលប្រយោជន៍ពីក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្មនៅលើដីសម្បទានសេដ្ឋកិច្ច ដោយរក្សានូវផលប្រយោជន៍ទៅវិញទៅមករវាងគូភាគីទាំងពីរ)

**សកម្មភាព៖**

១.	ចុះពិនិត្យនិងពន្យល់ម្ចាស់ចម្ការកៅស៊ូកសិឧស្សាហកម្មឱ្យជួយគាំទ្រដល់ម្ចាស់ចម្ការកៅស៊ូគ្រួសារ

២.	ចូលរួមដោះស្រាយបញ្ហាប្រឈមក្នុងការផ្តល់ដីសម្បទានសង្គមកិច្ចសម្រាប់ដំណាំកៅស៊ូដល់កសិករ

៣.	ចូលរួមធ្វើជាអ្នកសម្របសម្រួលរវាងម្ចាស់ចម្ការកៅស៊ូកសិឧស្សាហកម្ម និងម្ចាស់ចម្ការកៅស៊ូគ្រួសារ

### ៣.១១.	ពង្រឹងនិងកែលម្អ តួនាទីដឹកនាំរបស់អគ្គនាយកដ្ឋានកៅស៊ូឲ្យទៅជាអង្គភាពសម្របសម្រួលមួយ (ជាអង្គភាពដឹកនាំ៍ មានថាមភាពដើម្បីឆ្លើយតបចំពោះរាល់ តម្រូវការ និងការពេញចិត្តគ្រប់តួអង្គនៃផ្នែកកៅស៊ូ)

**សកម្មភាព៖**

១.	រៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ

២. ជំរុញឲ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវក្របខ័ណ្ឌច្បាប់
៣. ការគាំទ្រគម្រោងអភិវឌ្ឍន៍កៅស៊ូគ្រួសារ ដើម្បីទាក់ទាញរកដៃគូសហប្រតិបត្តិការក្នុងការគាំទ្រថវិកានិងបច្ចេកទេស
៤. ចាត់តាំងមន្ត្រីជំនាញនៅតាមមាត់ច្រកនាំចេញដើម្បីតាមដាននិងត្រួតពិនិត្យសកម្មភាពនៃការនាំចេញនាំចូលផលិតផលកៅស៊ូ រុក្ខសម្ភារ ឧបករណ៍ គ្រឿងចក្រសម្រាប់បម្រើវិស័យកៅស៊ូ
៥. បង្កើតការិយាល័យដំណាំកៅស៊ូនៅតាមបណ្តាខេត្តដើម្បីសិក្សាអំពីសក្តានុពលដីដែលកបនឹងដំណាំកៅស៊ូ តាមដានត្រួតពិនិត្យ រៀបចំចុះបញ្ជិកា ប្រមូលទិន្នន័យ ចងក្រងស្ថិតិកៅស៊ូ និងផ្ទេរបច្ចេកវិទ្យា ព្រមទាំងផ្តល់ព័ត៌មានកៅស៊ូ ឱ្យដល់អ្នកពាក់ព័ន្ធនឹងវិស័យកៅស៊ូ
៦. ពង្រឹងការបណ្តុះបណ្តាលលើវិស័យភូតគាមអនាម័យ និងអនាម័យសត្វ
៧. បណ្តុះបណ្តាលថ្នាក់ឧត្តម និងក្រោយឧត្តម
៨. ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការស្រាវជ្រាវនិងផ្សព្វផ្សាយ
៩. ពង្រីកហេដ្ឋារចនាសម្ព័ន្ធបណ្តុះបណ្តាល

## ទិសដៅគោលនយោបាយទី៤-"កំណែទម្រង់ជលផល"

### កម្មវិធីទី-៤៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព

#### ៤.១ ការគ្រប់គ្រងនិងអភិវឌ្ឍន៍សហគមន៍នេសាទ

**សកម្មភាព៖**

១. ការចុះបញ្ជីនិងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរបស់សហគមន៍នេសាទ
២. ពង្រឹងសមត្ថភាពសហគមន៍នេសាទដើម្បីគ្រប់គ្រងធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព

#### ៤.២ កែទម្រង់ដែននេសាទ

**សកម្មភាព៖**

១. ការបោះបង្គោលព្រំប្រទល់ឡូត៍នេសាទនិងសហគមន៍នេសាទ
២. ការកាត់បន្ថយឡូត៍នេសាទ
៣. ការរៀបចំផែនទីកំណត់ព្រំប្រទល់និងការការពារព្រៃលិចទឹក

#### ៤.៣ ជំរុញការអភិវឌ្ឍន៍វារីវប្បកម្ម

**សកម្មភាព៖**

១. បង្កើនទិន្នផលវារីវប្បកម្ម (១៥%ក្នុងមួយឆ្នាំៗ)

២. ការជ្រើសរើសតំបន់ និងបណ្តុះបណ្តាលបច្ចេកទេសដល់កសិករ
៣. ការផលិតកូនត្រីពូជ១០០លានក្បាលក្នុងមួយឆ្នាំៗ
៤. ការរៀបចំបង្កើតសហគមន៍ស្រះជម្រកត្រី

## ៤.៤ ផ្សព្វផ្សាយច្បាប់ ស្តីពី ជលផល និងការបង្ក្រាបបទល្មើសជលផល

**សកម្មភាព៖**

១. ផ្សព្វផ្សាយច្បាប់ស្តីពីជលផល
២. ការបង្ក្រាបបទល្មើសជលផល

## ៤.៥ ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

**សកម្មភាព៖**

១. ការសិក្សាប្រព័ន្ធតាមដាននិងវាយតម្លៃទៅលើអេកូឡូស៊ីជីវសាស្រ្ត ដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានធម្មជាតិ
២. ការសិក្សាផលប៉ះពាល់ពីការសាងសង់ទំបន់វារីអគ្គីសនីនៅតំបន់ទន្លេមេគង្គលើ
៣. ការសិក្សាលើប្រព័ន្ធទិន្នន័យតាមដានផលនេសាទសមុទ្រ និងវាយតម្លៃលើប្រព័ន្ធអេកូឡូស៊ីនិងជីវសាស្រ្តសមុទ្រ
៤. ការសិក្សាផលប៉ះពាល់លើប្រព័ន្ធអេកូឡូស៊ីនិងជីវសាស្រ្តសមុទ្រ

## ៤.៦ បង្កើនការយល់ដឹងការកែច្នៃផលផលិតផលជលផល និងបច្ចេកវិទ្យាក្រោយពេលប្រមូលផល

**សកម្មភាព៖**

១. ការបណ្តុះបណ្តាលពីអនាម័យបច្ចេកទេសកែច្នៃនិងថែរក្សាផលផលិតផលជលផល
២. ជួយអន្តរាគមន៍ដើម្បីបង្កើនគុណភាពផលផលិតផលជលផល
៣. ការត្រួតពិនិត្យគុណភាពផលផលិតផលជលផល

## ៤.៧ អភិរក្ស និងសិក្សាស្រាវជ្រាវដើម្បីបង្កើនផលស្តុកជលផល

**សកម្មភាព៖**

១. ការការពារនិងអភិរក្ស អន្លង់ត្រីមេពូជនៅតំបន់ទន្លេមេគង្គលើ
២. ការគ្រប់គ្រងតំបន់ទីជម្រកជលផលសំខាន់ៗ
៣. ការកាត់បន្ថយប្រភេទវារិជាតកំពុងរងគ្រោះថ្នាក់
៤. ការធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងកន្លែងអភិរក្សបឹងទន្លេសាប តាមរយៈការរៀបចំព្រំប្រទល់ច្បាស់លាស់ ការការពារ និងការអប់រំផ្សព្វផ្សាយ

### ៤.៨ ការរៀបចំផែនការខណ្ឌរដ្ឋបាលជលផល និងការគ្រប់គ្រងស្ថិតិជលផល

**សកម្មភាព៖**

១. ការរៀបចំនិងអនុវត្តផែនការខណ្ឌរដ្ឋបាលជលផល

២. ពង្រឹងការប្រមូលស្ថិតិ ការតាមដាននិងវាយតម្លៃជលផល

### ៤.៩ ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យជលផល

**សកម្មភាព៖**

១. ការពង្រឹងសមត្ថភាពធនធានមនុស្សទៅតាមផែនការ/កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យជលផល

## ទិសដៅគោលនយោបាយទី៥-"កំណែទម្រង់ព្រៃឈើ"

### កម្មវិធីទី-៥៖ ការគ្រប់គ្រងធនធានព្រៃឈើ និង សត្វព្រៃ ប្រកបដោយនិរន្តរភាព

### ៥.១. ការកំណត់ព្រំប្រទល់ព្រៃឈើជាតិ ការចាត់ថ្នាក់ និងការចុះបញ្ជិកា

### ៥.១.១ ការកំណត់ព្រំប្រទល់ដែនព្រៃ និងចុះបញ្ជិកា

**សកម្មភាព៖**

១. បង្កភាពងាយស្រួលដល់ដំណើរការកំណត់ព្រំប្រទល់ដែនព្រៃអចិន្ត្រៃយ៍ ជាមួយនឹងផែនទីប្រើប្រាស់ដីធ្លី

២. ធ្វើការសំរបសំរួលជាមួយអាជ្ញាធរពាក់ព័ន្ធ

៣. ការកំណត់ព្រំប្រទល់ដោយមានការចូលរួមពីគ្រប់កំរិត

៤. ចុះបញ្ជីព្រំប្រទល់ដែនព្រៃ

### ៥.១.២ ការចាត់ថ្នាក់ព្រៃឈើតាមមុខងារ

**សកម្មភាព៖**

១. រៀបចំព្រាងការធ្វើចំណាត់ថ្នាក់ព្រៃអចិន្ត្រៃយ៍នៅលើផែនទី

២. ប្រមូលទិន្នន័យពីតំបន់ព្រៃអចិន្ត្រៃយ៍និមួយៗនិងធ្វើការចាត់ថ្នាក់

៣. ធ្វើការកំណត់ព្រំប្រទល់ និងចុះបញ្ជីតំបន់ព្រៃអចិន្ត្រៃយ៍

៤. ធ្វើការតាមដាននិងវាយតម្លៃ

### ៥.២. អភិរក្សនិងអភិវឌ្ឍធនធានព្រៃឈើ និងជីវៈចម្រុះ

### ៥.២.១. ផែនការសកម្មភាពគ្រប់គ្រងព្រៃឈើជាតិ

**សកម្មភាព៖**

១. តួនាទីនិងការបង្កើតនូវក្រុមការងារផែនការគ្រប់គ្រងព្រៃឈើជាតិសារពើភ័ណ្ឌព្រៃឈើជាតិ

២. តាមដាននិងវាយតម្លៃដំណើរការវិវត្តនៃផែនការគ្រប់គ្រងកម្មវិធីព្រៃឈើជាតិ

### ៥.២.២. ការអភិវឌ្ឍ និងអនុវត្តបច្ចេកទេសគ្រប់គ្រងព្រៃផ្តល់ផល

**សកម្មភាព៖**

១. អភិវឌ្ឍន៍ការគ្រប់គ្រងព្រៃឈើប្រដោយនិរន្តរភាពជំរុញការយកចិត្តទុកដាក់ពីទិដ្ឋភាពធម្មជាតិ

២. អភិវឌ្ឍទម្រង់ផ្សេងៗគ្នាសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

៣. ការធ្វើអត្តសញ្ញាណនិងការគ្រប់គ្រងព្រៃគុបដេញថ្លៃប្រចាំឆ្នាំ

៤. ការធ្វើអត្តសញ្ញាណនិងការគ្រប់គ្រងតំបន់សំរាប់ការងារឃុំនិតិសម្បទា

### ៥.២.៣. ពង្រឹងការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

**សកម្មភាព៖**

១. ការធ្វើអត្តសញ្ញាណ និងឱ្យនិយមន័យសម្រាប់ចំណុចអាទិភាពលើការអភិរក្សថ្នាក់ជាតិក្នុងតំបន់អភិរក្ស និងព្រៃការពារ

### ៥.២.៤. ការអភិរក្សនិងអភិវឌ្ឍធនធានសេនេទិច និងប្រភពពូជ

**សកម្មភាព៖**

១. ជំរុញនិងអភិរក្សហ្សែនរបស់ប្រភេទឈើ

### ៥.២.៥. ការដាំដុះដើមឈើ និងការអភិវឌ្ឍចម្ការព្រៃដាំ

**សកម្មភាព៖**

១. បង្កើតការដាំដើមឈើក្នុងគោលបំណងច្រើនយ៉ាង នៅលើតំបន់សមស្របដោយសហការជាមួយសហគមន៍ក្នុងស្រុក អង្គការជាតិនិងអន្តរជាតិ និងក្រុមអ្នកចាប់អារម្មណ៍ផ្សេងទៀត

### ៥.២.៦. ការអភិវឌ្ឍផលិតផលព្រៃឈើ និងពង្រីកទីផ្សារ

**សកម្មភាព៖**

១. ធ្វើការអភិវឌ្ឍនូវប្រព័ន្ធដើម្បីធានានូវយន្តការដែលអាចមាន និងជំរុញផ្នែកបរិស្ថានសម្រាប់ការអភិវឌ្ឍផលិតផលព្រៃឈើក្នុងស្រុក និងទីផ្សារ

២.	ជំរុញលើកទឹកចិត្តការស្រាវជ្រាវនិងអភិវឌ្ឍន៍
៣.	ពង្រឹងក្របខ័ណ្ឌនៃការធានាគុណភាពស្តីពីការកែច្នៃផលិតផលព្រៃឈើនិងទីផ្សារ

### ៥.២.៧. ការអភិវឌ្ឍបច្ចេកទេសកែច្នៃឈើ និងការកែច្នៃផល-អនុផលព្រៃឈើ

**សកម្មភាព៖**

១.	ធ្វើការវិភាគការផ្គត់ផ្គង់ដែលមានសក្តានុពលនៃការកែច្នៃឈើស្របច្បាប់ ក្រោមការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព
២.	ខ្សែចង្វាក់នៃវិញ្ញាបនបត្រសម្រាប់ថៃរក្សាគ្រប់គ្រងឈើ
៣.	ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍផលឈើ

### ៥.២.៨. ការអភិវឌ្ឍប្រព័ន្ធវិញ្ញាបនបត្រព្រៃឈើ

**សកម្មភាព៖**

១.	បង្កើតមជ្ឈមណ្ឌលវិញ្ញាបនបត្រព្រៃឈើក្នុងរដ្ឋបាលព្រៃឈើ
២.	បង្កើតក្រុមការងារថ្នាក់ជាតិស្ថិតនៅក្រោមមជ្ឈមណ្ឌលវិញ្ញាបនបត្រព្រៃឈើ

## ៥.៣. ពង្រឹងច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច

### ៥.៣.១. ការកែទម្រង់ច្បាប់ និងរដ្ឋបាល

**សកម្មភាព៖**

១.	រៀបចំក្រុមការងារធ្វើបទប្បញ្ញត្តិ
២.	បង្កើតក្រុមការងារសម្រាប់ការស៊ើបអង្កេតតាមដាននិងអធិការកិច្ច
៣.	គណៈកម្មាធិការពិនិត្យនិងវាយតម្លៃការងារ និងវិន័យនៅថ្នាក់កណ្តាលនិងមូលដ្ឋាន
៤.	ធ្វើឱ្យប្រសើរឡើងនូវរចនាសម្ព័ន្ធស្ថាប័នរបស់រដ្ឋបាលព្រៃឈើ
៥.	បង្កើននូវសមត្ថភាពមន្ត្រីរបស់រដ្ឋបាលព្រៃឈើ លើការគ្រប់គ្រងជម្លោះទាក់ទិននឹងធនធានធម្មជាតិ
៦.	ធ្វើឱ្យប្រសើរឡើងទំនាក់ទំនងក្នុងរដ្ឋបាលព្រៃឈើ
៧.	អភិបាលកិច្ចគ្រប់គ្រងធនធានព្រៃឈើបានល្អ

### ៥.៣.២. ការពង្រឹងការអនុវត្តច្បាប់ និងការតាមដាននិងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ

**សកម្មភាព៖**

១.	បង្កើតមធ្យោបាយនិងសម្ភារសមស្រប
២.	បង្កើតយន្តការតាមដាននិងរាយការណ៍ប្រកបដោយប្រសិទ្ធភាពចំពោះឧក្រិដ្ឋកម្មព្រៃឈើ

៣. រៀបចំព័ត៌មានឧក្រិដ្ឋកម្មព្រៃឈើដើម្បីរាយការណ៍ជូនរដ្ឋបាលព្រៃឈើ

៤. ធ្វើឱ្យប្រសើរឡើងនូវការសហការតាមព្រំដែន

៥. សហការប្រកបដោយប្រសិទ្ធភាពជាមួយភ្នាក់ងារអនុវត្តច្បាប់ផ្សេងទៀត

៦. ការអនុវត្តឱ្យមានប្រសិទ្ធភាពលើការប្រឆាំងនឹងការចាប់យកការទន្ទ្រានយកដីខុសច្បាប់

### ៥.៤. សហគមន៍ព្រៃឈើជាតិ

#### ៥.៤.១. ការកំណត់តំបន់សក្តានុពល និងការបង្កើតសហគមន៍ព្រៃឈើ

**សកម្មភាព៖**

១. ធ្វើអត្តសញ្ញាណសហគមន៍ព្រៃឈើដែលមានសក្តានុពល និងសម្រួលដល់ការបង្កើត

២. ការកំណត់ព្រំប្រទល់ធ្វើផែនទី បោះបង្គោលស៊ីម៉ង់ និងផ្លាកសញ្ញាសម្រាប់សម្គាល់សហគមន៍ព្រៃឈើ

៣. ការរៀបចំកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ

៤. ការរៀបចំផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ

#### ៥.៤.២. ការអភិវឌ្ឍសហគមន៍ និងការបង្កើនជីវភាព

**សកម្មភាព៖**

១. ឱកាសទីផ្សារសម្រាប់អនុផលព្រៃឈើ (ព័ត៌មានស្តីពីទីផ្សារផលឈើ និងអនុផលព្រៃឈើត្រូវផ្តល់ឱ្យសមាជិកសហគមន៍ព្រៃឈើជាទៀងទាត់ ការស្រាវជ្រាវអំពីអនុផលព្រៃឈើត្រូវបានអនុវត្ត និងចងក្រងឯកសារលទ្ធផលក្នុងសហគមន៍)

២. ផ្តល់នូវបច្ចេកទេសដាំដុះ (សហគមន៍ព្រៃឈើអាចមានសមត្ថភាពបង្កើតថ្នាលបណ្តុះកូនឈើនិងអាចផលិតកូនឈើ សហគមន៍ព្រៃឈើមានចំណេះដឹងអំពីការប្រមូលផលឈើ និងអនុផលព្រៃឈើប្រកបដោយនិរន្តរភាព)

#### ៥.៤.៣. ការផ្តល់សេវាកម្មដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើ

**សកម្មភាព៖**

១. ការកសាងសមត្ថភាពសម្រាប់សមាជិកសហគមន៍ព្រៃឈើ ទទួលបានសេវាកម្មផ្សព្វផ្សាយអំពីច្បាប់ បច្ចេកទេសតៃថ្នៃ ការបង្កើតនិងគ្រប់គ្រងសហគមន៍ព្រៃឈើ

២. ពង្រឹងសមត្ថភាពនិងធ្វើឱ្យថ្មីនូវទិន្នន័យសហគមន៍ព្រៃឈើ

៣. ធ្វើការផ្ទៀងផ្ទាត់និងរៀបចំក្របខ័ណ្ឌច្បាប់ ដើម្បីគាំទ្រដល់ការអនុវត្តតំបន់សហគមន៍ព្រៃឈើ

៤. តាមដាននិងវាយតម្លៃការអនុវត្តសហគមន៍ព្រៃឈើ

### ៥.៥. ការអភិវឌ្ឍសមត្ថភាព និង ការស្រាវជ្រាវ

### ៥.៥.១. ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស

**សកម្មភាព៖**

១. ធ្វើឱ្យប្រសើរឡើងនូវរចនាសម្ព័ន្ធរបស់រដ្ឋបាលព្រៃឈើ

២. ធ្វើការជ្រើសរើសនិងអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលព្រៃឈើ

៣. អភិវឌ្ឍការបណ្តុះបណ្តាលធនធានមនុស្សដើម្បីឆ្លើយតបនឹងតម្រូវការសម្រាប់កម្មវិធីព្រៃឈើជាតិ

៤. ធ្វើការចុះបញ្ជីចំណាត់ថ្នាក់ និងកំណត់ព្រំប្រទល់សម្រាប់ព្រៃឈើជាតិ

៥. គ្រប់គ្រង និងអភិរក្សធនធានព្រៃឈើ

៦. ការអនុវត្តច្បាប់ព្រៃឈើនិងអភិបាលកិច្ច

៧. បណ្តាញគ្រប់គ្រងសហគមន៍ព្រៃឈើជាតិ

### ៥.៥.២. ការអប់រំ និងផ្សព្វផ្សាយសាធារណៈ

**សកម្មភាព៖**

១. ជំរុញការផ្លាស់ប្តូររបស់មនុស្សជំនាន់ក្រោយ ស្តីពីការគ្រប់គ្រងព្រៃឈើ

២. យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងដើម្បីគាំទ្រការអនុវត្តកម្មវិធីព្រៃឈើជាតិ

៣. បង្កើតនូវមជ្ឈមណ្ឌលផ្សព្វផ្សាយព័ត៌មាន

៤. យុទ្ធសាស្ត្រទំនាក់ទំនងរដ្ឋបាលព្រៃឈើកណ្តាលនិងមូលដ្ឋាន

៥. ការគាំទ្រជាពិសេសសម្រាប់សកម្មភាពគ្រប់គ្រងព្រៃឈើ

៦. ស្វែងរកការអនុវត្តគ្រប់គ្រងល្អដើម្បីពង្រីកនូវបទពិសោធន៍ល្អ

### ៥.៥.៣. ការអភិវឌ្ឍសមត្ថភាពសិក្សាស្រាវជ្រាវ

**សកម្មភាព៖**

១. គណៈកម្មាធិការដឹកនាំស្រាវជ្រាវព្រៃឈើជាតិ

២. វិទ្យាស្ថានអភិវឌ្ឍន៍ការស្រាវជ្រាវសត្វព្រៃ

៣. ធ្វើឱ្យប្រសើរឡើងនូវបណ្តាញស្រាវជ្រាវព្រៃឈើ

៤. ស្រាវជ្រាវដើម្បីគាំទ្រការអនុវត្តកម្មវិធីព្រៃឈើជាតិ

### ៥.៦. ហិរញ្ញប្បទានដោយចីរភាពសម្រាប់វិស័យព្រៃឈើ

### ៥.៦.១. ហិរញ្ញប្បទានផ្តល់ដោយរដ្ឋ

**សកម្មភាព៖**

១. គាំទ្រកម្មវិធីក្នុងកម្មវិធីព្រៃឈើជាតិសំដៅបង្កើនថវិការបស់រដ្ឋប្រមាណ៣លាន ដុល្លារអាមេរិក/ឆ្នាំ

### ៥.៦.២. ចំណូលពីវិស័យព្រៃឈើជាតិ

**សកម្មភាព៖**

១. ពង្រឹងបង្កើតនិងប្រមូលចំណូលពីវិស័យព្រៃឈើតាមរយៈការបង្កើតនិងអនុវត្ត អនុក្រឹត្យស្តីការគ្រប់គ្រងចំណូលចំណាយអនុវត្តកម្មវិធីព្រៃឈើជាតិ

### ៥.៦.៣. ចំណូលពីវិស័យឯកជន និងសហគមន៍ព្រៃឈើ

**សកម្មភាព៖**

១. ការលើកទឹកចិត្តវិស័យឯកជនសម្រាប់កម្មវិធីវិនិយោគ

២. តំបន់គោលដៅនៃប្រភពហិរញ្ញប្បទាននៃការបង្កើតថ្មី

## ៦. ផែនការថវិកាសម្រាប់ដំណើរការអនុវត្ត

ដើម្បីសម្រេចទិសដៅគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់អាទិភាពនូវកម្មវិធី/គម្រោងនានា សំដៅធ្វើវិភាជន៍ថវិកាឱ្យបានសមស្រប ដើម្បីគាំទ្រកម្មវិធី/គម្រោងទាំងនោះ សម្រាប់អនុវត្តអំឡុងឆ្នាំ២០០៩-២០១៣ និងបន្ថែមលើនេះទៀត ក្រសួងមានជំនឿជឿជាក់ថា រាជរដ្ឋាភិបាលកម្ពុជានឹងបង្កើនបន្ថែមនូវធនធានថវិកាក្នុងស្រុក ជាមួយនឹងជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុពីសហគមន៍អន្តរជាតិ ដៃគូអភិវឌ្ឍន៍ពីខាងក្រៅ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន និងពិសេសទៀតនោះ គឺការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសហគមន៍កសិករ សំដៅរួមគ្នាជំរុញការអភិវឌ្ឍវិស័យកសិកម្ម ។

ប្រភពហិរញ្ញវត្ថុសំខាន់ៗសម្រាប់ការលើកស្ទួយអភិវឌ្ឍន៍វិស័យកសិកម្ម នឹងបានមកពីថវិកាជាតិនិងជំនួយបរទេស។ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកឡើងនូវកម្មវិធី/គម្រោងអាទិភាពសំខាន់ៗទៅតាមកម្មវិធីតាមវិស័យនិងអនុវិស័យ ដោយមានវិភាជន៍កញ្ចប់ថវិកាសមស្រប ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធី/គម្រោងសម្រាប់ឆ្នាំ២០០៩-២០១៣ ដោយមានថវិកាសរុប **១៨១.៥៥៩.៧៨០** ដុល្លារអាមេរិក ក្នុងនោះថវិកាចំនួន **១០៦.៣៩៣.៩៤០** ដុល្លារអាមេរិក គ្រោងសម្រាប់ការកែលំអសន្តិសុខស្បៀង ការបង្កើនផលិតភាពនិងពិពិធកម្មកសិកម្ម **២៨.៥២១.១៨០** ដុល្លារអាមេរិក គ្រោងសម្រាប់កែលំអលទ្ធភាពទីផ្សារផលិតផលកសិកម្ម **២១.៦២៣.៤៦០** ដុល្លារអាមេរិក សម្រាប់ការកែលំអក្របខ័ណ្ឌស្ថាប័ននិងច្បាប់ **៤.៦៥០០.០០០** ដុល្លារអាមេរិក សម្រាប់កំណែទម្រង់ជលផល និង **២០.៣៧១.២០០** ដុល្លារអាមេរិក សម្រាប់កំណែទម្រង់ព្រៃឈើ និងការគ្រប់គ្រងនូវតំបន់ការពារប្រកបដោយនិរន្តរភាព។

## ឈ. ការពិនិត្យតាមដាន និងវាយតម្លៃ

ទាក់ទងនឹងបទពិសោធន៍ ជាពិសេសការសម្រេចបាននិងការវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០០៦-២០១០ កន្លងមក បានបង្ហាញឱ្យឃើញថា ការពិនិត្យតាមដាន និងវាយតម្លៃគឺជាធាតុដ៏សំខាន់ ដើម្បីធានាដល់ការអនុវត្តគម្រោងសកម្មភាព និងសូចនាករនានាសម្រាប់ផ្ទៀងផ្ទាត់ជាមួយនឹងលទ្ធផលសម្រេចបាន ដែលបានកំណត់យ៉ាងសមស្របនៅក្នុងការធ្វើផែនការ និងការរៀបចំគម្រោងសកម្មភាពនីមួយៗ។ ដូចនេះ ការពិនិត្យតាមដាននិងវាយតម្លៃ គឺជាឧបករណ៍ដ៏ស័ក្តិសិទ្ធិ សំរាប់ផ្ទៀងផ្ទាត់រាល់សូចនាករលទ្ធផល (Outcomes & Outputs) នៅពាក់កណ្តាលអណត្តិ និងពេញអណត្តិនៃការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងមានការឆ្លុះបញ្ចាំងដើម្បីគាំទ្រដល់គោលនយោបាយតាមផ្នែក ក៏ដូចជាគោលនយោបាយថ្នាក់ជាតិ។ ក្រសួងផែនការបានណែនាំឱ្យបញ្ចូលក្ធឡោនសន្ទស្សន៍លទ្ធផល (Outcomes & Output) សម្រាប់ធ្វើការពិនិត្យតាមដាននិងវាយតម្លៃនៅពាក់កណ្តាលអណត្តិ និងពេញអណត្តិនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣។

ទោះបីយ៉ាងណាក៏ដោយ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣ នឹងត្រូវបានបង្ហាញ និងបញ្ជាក់នូវសូចនាករជាច្រើន សំរាប់ធ្វើការផ្ទៀងផ្ទាត់លទ្ធផលនៃការអនុវត្ត។ (លំអិតក្នុងឧបសម្ព័ន្ធ១៖ តារាងសូចនាករសំខាន់ៗ ក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣) ។

ដើម្បីធានាដល់ការអនុវត្តយ៉ាងពេញលេញនូវការពិនិត្យតាមដាននិងវាយតម្លៃ នាយកដ្ឋានផែនការ និងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តសកម្មភាពតាមដាននិងវាយតម្លៃនេះ។ របាយការណ៍លទ្ធផលការងារសម្រាប់គម្រោងទាំងនោះនឹងត្រូវរៀបចំឡើងក្នុងអំឡុងពេលអនុវត្ត និងការវាយតម្លៃក្រោយពេលអនុវត្ត។ បណ្តានាយកដ្ឋានអង្គភាពជំនាញនានាដែលពាក់ពន្ធ័ក្នុងការអនុវត្តផែនការយុទ្ធសាស្រ្តនេះ ត្រូវរាយការណ៍ជូនក្រសួង (នាយកដ្ឋានផែនការនិងស្ថិតិ) ពីលទ្ធផលសម្រេចបានឱ្យបានទៀងទាត់ តាមរយៈការផ្តល់របាយការណ៍ប្រចាំត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ។ របាយការណ៍អនុវត្តនិងសមិទ្ធផលសម្រេចបានក្នុងការអនុវត្តនេះ នឹងត្រូវរៀបចំដោយនាយកដ្ឋានផែនការនិងស្ថិតិ ហើយត្រូវរាយការណ៍ជូនក្រសួងពិនិត្យនិងសម្រេច ។ ផ្អែកលើរបាយការណ៍ខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ នឹងត្រូវធ្វើការបូកសរុប រួចរាយការណ៍ជូនទៅក្រសួងផែនការ ដើម្បីមានជាមូលដ្ឋានរាយការណ៍ជូនរាជរដ្ឋាភិបាលកម្ពុជា។

## ញ. សេចក្តីសន្និដ្ឋាន

ជាការពិណាស់ថា ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០០៩-២០១៣ ដែលបានរៀបចំនេះនឹងត្រូវបានកំណត់ជាត្រីវិស័យក្នុងបេសកកម្មរយៈពេល៥ឆ្នាំ ដែលសកម្មភាពការងារ

ជាច្រើននឹងមានការពាក់ព័ន្ធនៅក្នុងការអនុវត្តដល់ផ្នែកនានាក្នុងគ្រប់វិស័យ និងអនុវិស័យទាំងអស់ នៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងទាមទារឱ្យមានការចូលរួមសហការអនុវត្ត ពីគ្រប់ស្ថាប័នពាក់ព័ន្ធរួមទាំងផ្នែកឯកជនផងដែរ។ ការចូលរួមរបស់ផ្នែកឯកជន ជាពិសេសនៅក្នុងផលិតកម្មកសិកម្មនិងកសិពាណិជ្ជកម្ម គឺមានសារៈសំខាន់ណាស់ក្នុងការរួមចំណែកជំរុញកំណើនក្នុងវិស័យកសិកម្ម ។

រាជរដ្ឋាភិបាលកម្ពុជានឹងបន្តផ្តល់ការគាំទ្របន្ថែមទៀត ដល់ការអភិវឌ្ឍវិស័យកសិកម្ម ដើម្បីធ្វើជាកម្លាំងជំរុញកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ជាមួយនឹងការបង្កើនថវិកាវិនិយោគសាធារណៈ ព្រមទាំងបង្កើនការកៀងគរ ក៏ដូចជាការប្រើប្រាស់ធនធានជំនួយពីបរទេសឱ្យបានច្រើនជាងមុន សំដៅជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍវិស័យកសិកម្មនេះ។

ឯកសារនេះក៏បានបញ្ជាក់ផងដែរនូវចំណុចដែលជាឧបសគ្គចម្បងៗ និងបានលើកឡើងនូវបណ្តាសកម្មភាពទាំងឡាយដើម្បីជំនះនូវឧបសគ្គទាំងនោះ ព្រមទាំងបានបង្ហាញលំអិតអំពីលទ្ធផលរំពឹងទុក ជាពិសេសសូចនាករនិងលទ្ធផល ដែលត្រូវសម្រេចឱ្យបានក្នុងកំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រនេះ និងមធ្យោបាយផ្ទៀងផ្ទាត់នៅក្នុងប្រតិបត្តិការពាក់កណ្តាល និងពេញអាណត្តិនៃគម្រោងផែនការត្រូវអនុវត្ត ដោយបានបង្ហាញផងដែរនូវថវិកាសម្រាប់ដំណើរការប្រតិបត្តិការ និងកាលវិភាគការងារដែលត្រូវសម្រេចឱ្យបានជោគជ័យ ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣ ពិតជាមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការបង្ហាញឱ្យឃើញអំពីទិសដៅនិងសកម្មភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបាននូវលទ្ធផលស្របតាមការចង្អុលណែនាំនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ និងផ្តល់តម្លាភាព និងភាពគួរឱ្យទុកចិត្តបានសំរាប់ដៃគូអភិវឌ្ឍន៍ បណ្តាប្រទេសអ្នកផ្តល់ជំនួយរួមចំណែកផ្តល់ធនធានទាំងបច្ចេកទេសនិងថវិកា ដើម្បីអនុវត្តក្នុងសកម្មភាពអាទិភាព សម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្តេជ្ញាចិត្តខ្ពស់ក្នុងការជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣នេះ ឱ្យទទួលបានលទ្ធផលផ្លែផ្កាជាវិជ្ជមាន ។ កត្តាអវិជ្ជមាននិងឧបសគ្គនានាដែលនឹងអាចរាំងស្ទះ ក្នុងការបង្កើនផលិតភាពនិងពិពិធកម្មកសិកម្ម ពិសេសផលិតកម្មដំណាំស្រូវ គឺអាចជាកត្តាគ្រោះធម្មជាតិដែលនឹងអាចកើតមាន ដូចជា គ្រោះទឹកជំនន់ ភាពរាំងស្ងួត កត្តាបំផ្លិចបំផ្លាញពីសត្វល្អិតចង្រៃ ។ល។ ដែលយើងមិនអាចដឹងមុន ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ឧបសគ្គទាំងនេះនឹងអាចកាត់បន្ថយបាន តាមរយៈការតាំងចិត្តនិងការខិតខំជំនះ ដើម្បីទទួលបានជោគជ័យក្នុងការអភិវឌ្ឍវិស័យកសិកម្មនេះ។

-------------✍📖✍--------------

## *ឧបសម្ព័ន្ធ ១ : តារាងសូចនាករសំខាន់ៗក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (2009-2013)*

### តារាង : សូចនាករសំខាន់ៗ របស់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| សូចនាករសំខាន់ៗ | ឯកតា | ២០០៨ ជាក់ស្តែង | ២០០៩ ប៉ាន់ស្មាន | ២០១០ ព្យាករណ៍ | ២០១១ ព្យាករណ៍ | ២០១២ ព្យាករណ៍ | ២០១៣ ព្យាករណ៍ |
|---|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះដំណាំ (ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម) | ពាន់ហិកតា | ៥៩៦ | ៦៤៥ | ៧៧៤ | ៩៣0 | ១.000 | ១.000 |
| ផ្ទៃដីដាំដុះដំណាំស្រូវ | លានហិកតា | ២,៦១ | ២,៦៣ | ២,៦៥ | ២,៦៥ | ២,៦៥ | ២,៦៥ |
| ទិន្នផលស្រូវ ក្នុងមួយហិកតា | តោន | ២,៧៤ | ២,៧៧ | ២,៨0 | ២,៨៣ | ២,៨៧ | ៣,00 |
| ផលិតកម្មដំណាំស្រូវ | លានតោន | ៧,១៧ | ៧,២៨ | ៧,៤២ | ៧,៥0 | ៧,៦0 | ៧,៩៥ |
| ផ្ទៃដីស្រោចស្រព | ពាន់ហិកតា | ១.១២0 | ១.១៤៥ | ១.១៧0 | ១.១៩៥ | ១.២២0 | ១.២៤៥ |
| កាត់បន្ថយអាត្រាសត្វស្លាប់ | ភាគរយ | ៦,0 | ៥,៥ | ៥,0 | ៤,៥ | ៤,0 | ៣,៥ |
| ការចិញ្ចឹមសត្វគោ–ក្របី | លានក្បាល | ៤,២0 | ៤,២៩ | ៤,៣២ | ៤,៣៨ | ៤,៤៤ | ៤,៥0 |
| ផ្ទៃដីដាំដុះដំណាំកៅស៊ូ | ពាន់ហិកតា | ១១១,៤ | ១២៨,៤ | ១៤៣,៤ | ១៥៨,៤ | ១៧៣,៤ | ១៨៨,៤ |
| ទិន្នផលជ័រ/ ហិកតា | តោន | 0,៩៥ | ១,១0 | ១,១0 | ១,១៥ | ១,២0 | ១,៣0 |
| ផលិតកម្មជ័រស្ងួត | ពាន់តោន | ២៦,៦ | ៣៨,៥ | ៤៩,៥ | ៦៣,៣ | ៧៨,0 | ៩៧,៥ |
| ឡូត៍នេសាទ | គម$^{២}$ | ៤១៥ | ៤១៥ | ៤១៥ | ៤១៥ | ៤១៥ | ៤១៥ |
| ឡូត៍នេសាទ ដែលបានផ្តល់ជូនសហគមន៍នេសាទ | % | ៥៦,៤ | ៥៦,៤ | ៥៦,៤ | ៥៦,៤ | ៥៦,៤ | ៥៦,៤ |
| ផលិតកម្មនេសាទ (ទឹកសាប សមុទ្រ និងវារីវប្បកម្ម) | ពាន់តោន | ៤៧១ | ៥១៥ | ៦១៧ | ៦៦៨ | ៧២៦ | ៧៨៨ |
| ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ | %នៃផ្ទៃដី | ៥៩,00 | ៥៧,៥៩ | ៥៧,៩៩ | ៥៨,៣៩ | ៥៨,៧៩ | ៥៩,១៩ |
| ការដាំដុះឈើឡើងវិញ | ពាន់ហិកតា | ១0,៨១ | ១៨,៩២ | ៧៣ | ៧៣ | ៧៣ | ៧៣ |
| គ្រួសារប្រើប្រាស់អុស–ធ្យូង សម្រាប់ដុត | %គ្រួសារសរុប | ៧៣ | ៦៧ | ៦១ | ៥៩ | ៥៦ | ៥៤ |
| ការបោះបង្គោលព្រំព្រៃឈើ | គម | ៣២១ | ២២៨ | ៤១៣ | ៥00 | ៥00 | ៥00 |
| សហគមន៍ព្រៃឈើ | សហគមន៍ | ១២៤ | ២១0 | ៣00 | ៣៥0 | ៤00 | ៤៥0 |

*<u>ប្រភព</u>៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២00៩-២0១៣*